**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ១០០ MIH / 2014

# ប្រកាស
## ស្តីពី
## ការកំណត់ចាត់តាំងមន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## <u>សម្រេច</u>

**<u>ប្រការ១</u>** ៖ ត្រូវបានកំណត់ចាត់តាំងមន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសមាសភាព ដូចខាងក្រោម ៖

**ក.ថ្នាក់រដ្ឋបាលកណ្តាល**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ឡាំ | គីមឡេង | ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ |
| ២- លោក | ទឹង | សុមិត្ត | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ |
| ៣- លោក | គឹម | ចន្ទតារា | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ |
| ៤- លោក | កែ | សារី | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ |
| ៥- លោក | គង់ | សាំងហេង | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ |
| ៦- លោក | អ៊ុំ | ពៅពិសី | ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| ៧- លោក | វ៉ាន់ | ម៉ៅ | ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ៨- លោក | ងី | ប៉ូលីននារិទ្ធ | ប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខៈ (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីមែលៈ mih.smcabinet@gmail.com

| | | |
|---|---|---|
| ៩- លោក | ម៉េង សេរីវ៉ាត់ | ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ |
| ១០- លោក | សុខ ណារិទ្ធ | អនុប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| ១១- លោក | ម៉ុក កិត្យា | អនុប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| ១២- លោក | សៀ គីមហួន | អនុប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ១៣- លោក | ជ័យ ឃោឡា | អនុប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ១៤- លោក | ខ្លូត ឧស្សាហ៍ | អនុប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ១៥- លោក | សូ ផល្លា | អនុប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |
| ១៦- លោក | នាក់ ធឿង | អនុប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |
| ១៧- លោក | ជូ ប៊ុនសៀង | អនុប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ |
| ១៨- លោក | ម៉ម សេដ្ឋា | អនុប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ |
| ១៩- លោក | គីម កែវម៉ារ៉ា | ប្រធានការិយាល័យប្រព័ន្ធឯកតា និងសហប្រតិបត្តការ នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ២០- លោក | យិន វណ្ណដេត | ប្រធានការិ.ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ២១- លោក | ឈាង យីន | ប្រធានការិ.កិច្ចការនីត្យានុកូលមាត្រាសាស្ត្រ និងទំនាក់ទំនងសាធារណៈនៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ២២- លោក | ប៊ុន បូរ៉ា | ប្រធានការិ. ផែនការ និងទិន្នន័យ នៃនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |
| ២៣- លោក | ប៉ាន់ សុណា | ប្រធានការិ.ឧណ្ហមាត្រាមាត្រាសាស្ត្រ នៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ |
| ២៤- លោក | សុខ ប៊ុនសាយ | ប្រធានការិ.បណ្តុះបណ្តាល និងផ្សព្វផ្សាយ នៃនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| ២៥- លោក | ពូន សំបូរ | ប្រធានការិ. កិច្ចការទូទៅ នៃនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| ២៦- លោក | សេង សុកន្ត | ប្រធានការិ. កិច្ចការច្បាប់ នៃនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| ២៧- លោក | សេង គីមស៊ា | ប្រធានការិ. គម្រោង និងហិរញ្ញកិច្ច នៃនាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ |
| ២៨- លោក | ឯក ណាំហុង | ប្រធានការិ. ត្រួតពិនិត្យបទល្មើសមាត្រាសាស្ត្រ នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ |
| ២៩- លោក | សេង គឹមហេង | ប្រធានការិ. គ្រប់គ្រង និងព័ត៌មាន នៃនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |
| ៣០- លោក | យឹម សុវិជ្ជា | ប្រធានការិ. បច្ចេកវិទ្យាមាត្រាសាស្ត្រ នៃនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |
| ៣១- លោក | អែម សុភ័ស | ប្រធានការិ. កិច្ចការមាត្រាសាស្ត្រឧស្សាហកម្ម នៃនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម |
| ៣២- លោក | តូ ចាន់សេដ្ឋាវុធ | ប្រធានការិ. សរុប និងសហប្រតិបត្តិការមាត្រាសាស្ត្រ នៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ |
| ៣៣- លោក | សូ សំរិន | ប្រធានការិ. មេកានិចមាត្រាសាស្ត្រ នៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ |

៣៤- លោក ស្រឿង វ៉ាន់ធឿន ប្រធានការិ. អគ្គិសនីមាត្រាសាស្ត្រ
នៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ

៣៥- លោក ស្រស់ រស្មី ប្រធានការិ. ទំហំមាត្រាសាស្ត្រ
នៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ

៣៦- លោក វ៉ាន់ ចាន់រ៉ាត់ អនុប្រធានការិ. ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ
នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៣៧- លោកស្រី ហេង លក្ខិណា អនុប្រធានការិ. ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ
នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៣៨- លោកស្រី វ៉ាន សំណាង អនុប្រធានការិ. ត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិតនិងទំនិញ
វេចខ្ចប់នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៣៩- លោកស្រី សាម សំណាង អនុប្រធានការិ.កិច្ចការនីត្យានុកូលមាត្រាសាស្ត្រ និងទំនាក់ទំនង
សាធារណៈនៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៤០- លោក អ៊ឹង សុភាវ័ត្ត អនុប្រធានការិ. ត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញ
វេចខ្ចប់នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៤១- លោក នួន សុជា អនុប្រធានការិ. ត្រួតពិនិត្យបទល្មើសមាត្រាសាស្ត្រ
នៃនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៤២- លោកស្រី អោម វឌ្ឍនា អនុប្រធានការិ. កិច្ចការមាត្រាសាស្ត្រ
នៃនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម

៤៣- លោក ព្រាប ផល្គុណ អនុប្រធានការិ. គ្រប់គ្រង និងព័ត៌មាន
នៃនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម

៤៤- លោក ហួង ឌីណា អនុប្រធានការិ. ផែនការ និងទិន្នន័យ
នៃនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម

៤៥- លោក ដុំ រៀង អនុប្រធានការិ. ទំហំមាត្រាសាស្ត្រ
នៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ

៤៦- លោក ហុង សុខលីដា អនុប្រធានការិ. សរុប និងសហប្រតិបត្តិការមាត្រាសាស្ត្រ
នៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ

**ខ.ថ្នាក់រាជធានី-ខេត្ត**

៤៧- លោក នេត មុនីប៉ុណ្ណកា ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ

៤៨- លោក សុខ រចនា អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ

៤៩- លោកស្រី ជួង ជាលីម អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ

៥០- លោក ពេជ្រ សុគន្ធ មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ

៥១- លោក មៀង វណ្ណរេត ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល

៥២- លោក នួន សំអាង អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល

៥៣- លោក អ៊ឹម វណ្ណៈ អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល

៥៤- លោក នង សីហា មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកណ្តាល

៥៥- លោក សុន ហួត ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ

៥៦- លោក ប៉ែន វេន អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ

៥៧- លោកស្រី ឡឹង សុគុន្ធ អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ

៥៨- លោក ទន់ រិនណា មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ

៥៩- លោកស្រី ហ៊ឹម សុចិន្តា អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ឆ្នាំង

៦០- លោក សុខា សុខុម អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ឆ្នាំង

៦១- លោក សួរ ហុង មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្មនិងសិប្បកម្ម ខេត្តកំពង់ឆ្នាំង

៦២- លោក ជូ ធីរិទ្ធ ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តពោធិ៍សាត់

៦៣- លោក យឿង ថនរិន អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តពោធិ៍សាត់

៦៤- លោក ស ទី មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តពោធិ៍សាត់

៦៥- លោកស្រី គីម សួស្តី ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ធំ

៦៦-លោកស្រី ស៊ីន សុថារី អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ធំ

៦៧- លោក វៀង សុម៉ាន់ អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបាត់ដំបង

៦៨- លោក គង់ សុភ័ក្ត្រ ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបាត់ដំបង

៦៩- លោក ឌុច ចំរ៉ាត អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបាត់ដំបង

៧០- លោក ធឹង វន អនុប្រធានការិយាល័យស្តង់ដានិងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបាត់ដំបង

៧១- លោក អ៊ាវ ហៃ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តរតនៈគីរី

៧២- លោក ពេជ្រ ប៊ុនសែន អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តរតនៈគីរី

៧៣- លោក ញឹម វណ្ណារុន មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តរតនៈគីរី

៧៤- លោក ជួង អ៊ឹម ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តប៉ៃលិន

៧៥- លោក សែម សេង អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ

| | | | |
|---|---|---|---|
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តប៉ៃលិន |
| ៧៦- | លោក | សួន ឌី | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ចាម |
| ៧៧- | លោក | ហេង បូ | អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ចាម |
| ៧៨- | លោក | តូវ សុជាវ៉ា | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តមណ្ឌលគីរី |
| ៧៩- | លោក | សូរ សុវណ្ណារិទ្ធ | ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តមណ្ឌលគីរី |
| ៨០- | លោក | អ៊ឹម មេសា | មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តមណ្ឌលគីរី |
| ៨១- | លោក | សុខ ប៊ុនធឿន | មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តមណ្ឌលគីរី |
| ៨២- | លោក | ជា វុធឡុង | ប្រធានមន្ទីរ ឧស្សាហកម្ម និងសិប្បកម្ម ខេត្តសៀមរាប |
| ៨៣- | លោក | ខាំ ស៊ីម៉ុន | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តសៀមរាប |
| ៨៤- | លោក | អ៊ុំ ណារិទ្ធ | ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តសៀមរាប |
| ៨៥- | លោក | ឡុយ ប៊ុនសៀក | អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តសៀមរាប |
| ៨៦- | លោក | ហ៊ូ គា | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះវិហារ |
| ៨៧- | លោក | កុយ សុខន | ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះវិហារ |
| ៨៨- | លោក | មាស សុគន្ធ | អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះវិហារ |
| ៨៩- | លោក | ឈឹម ធឿន | មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះវិហារ |
| ៩០- | លោក | សំ សុធា | មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះវិហារ |
| ៩១- | លោក | ស៊ាម សេងហំ | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តឧត្តរមានជ័យ |
| ៩២- | លោក | ភិត ផល្លា | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តឧត្តរមានជ័យ |
| ៩៣- | លោក | អ៊ុច អរុណ | ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តឧត្តរមានជ័យ |
| ៩៤- | លោក | ឡុង សុខុម | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង |
| ៩៥- | លោក | សុខ ឡុង | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង |
| ៩៦- | លោក | អ៊ុក សាខន | ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង |
| ៩៧- | លោក | កេត ព្រុង | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តតាកែវ |
| ៩៨- | លោក | ញ៉ែវ សារ៉ែន | ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ |
| | | | នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តតាកែវ |
| ៩៩- | លោក | ខ្លឹម គគីរ | ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកោះកុង |
| ១០០- | លោក | អៀន សាវ៉ាន់ | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកោះកុង |

១០១- លោក ខឹម សីហា ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកោះកុង

១០២- លោក ចេង ញ៉ិន អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកោះកុង

១០៣- លោក យ៉ាន់ ហ៊ិន មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកោះកុង

១០៤- លោក នី ធុន ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តក្រចេះ

១០៥- លោក អ៊ីវ ចាន់សេរី អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តក្រចេះ

១០៦- លោក សួន សុជា មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តក្រចេះ

១០៧- លោក សោម សារ៉ាត អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ

១០៨- លោក ជា ឈាងហុង អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ

១០៩- លោក ផន រតនៈ អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ

១១០- លោក ណុប វីរៈ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកែប

១១១- លោក ណុប ប្រុស ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកែប

១១២- លោក និន សុខស្តី ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្ទឹងត្រែង

១១៣- លោក យឹម សារិន ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្ទឹងត្រែង

១១៤- លោក សោម ស៊ីវុត្ថា ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពត

១១៥- លោក អ៊ូ សុផុន មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពត

១១៦- លោក ធន់ យ៉ុង ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រៃវែង

១១៧- លោក សួង ថន អនុប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រៃវែង

១១៨- លោក ជា សំបូរ មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រៃវែង

១១៩- លោក ឆេង ឈុននី អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តត្បូងឃ្មុំ

១២០- លោក ស្រ៊ុន ចន្នី ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តត្បូងឃ្មុំ

១២១- លោក ញ៉ិល ប៊ុនធឿន ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបន្ទាយមានជ័យ

១២២- លោក ហេង សុភាង អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបន្ទាយមានជ័យ

១២៣- លោក ព្រុំ ឡុងផលា ប្រធានការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបន្ទាយមានជ័យ

១២៤- លោក គីម ចំរើន មន្ត្រីការិយាល័យស្តង់ដា និងមាត្រាសាស្ត្រ
នៃមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបន្ទាយមានជ័យ

**ប្រការ២** ៖ មន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រដូចមាននៅក្នុងប្រការ១ មានភារកិច្ចដូចតទៅ៖

-ជំរុញការផ្សព្វផ្សាយ ណែនាំពីការងារមាត្រាសាស្ត្រ ដល់គ្រប់មូលដ្ឋានជាតិ និងអន្តរជាតិ

-អនុវត្តការងារមាត្រាសាស្ត្រ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រ

-សហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីទប់ស្កាត់បទល្មើសមាត្រាសាស្ត្រ

-អនុវត្តទណ្ឌកម្មព្រមាន និងពិន័យអន្តរការណ៍ ដែលមានចែងក្នុងច្បាប់។

**ប្រការ៣** ៖ ប្រកាសលេខ ៧៩២ ឧរថ.មមជ.ប្រក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតក្រុមការងារមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤** ៖ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាន ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល** ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ « *ដើម្បីជូនជ្រាប* »
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ៣៣៧ MIH / 2015

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៣១/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសរួមលេខ ៧១៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពី ការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៨១ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- បានឃើញប្រកាសលេខ ១៧៥ ឧរថ.ម.ម.ជ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពី ការបង្កើតគណៈកម្មាធិការបច្ចេកទេសជំនាញមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១** ៖ ត្រូវបានបង្កើតគណៈកម្មាធិការវាយតម្លៃទទួលស្គាល់ជំនាញមាត្រាសាស្ត្រនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- លោកជំទាវ ឡាយ ណារីន | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម លឹម គង់ | អនុរដ្ឋលេខាធិការ | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣- ឯកឧត្តម | ឡាំ | គឹមឡេង | ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- លោក | ទឹង | សុមិត្ត | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ៥- លោក | គឹម | ចន្ទតារា | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ៦- លោក | កែ | សារី | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ៧- លោក | គង់ | សាំងហេង | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ៨- លោក | អ៊ុំ | ពៅពិសី | ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ | សមាជិក |
| ៩- លោក | ម៉េង | សេរីរ៉ាត់ | ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ | សមាជិក |
| ១០- លោក | ងី | ប៉ូលីននារិទ្ធ | ប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម | សមាជិក |
| ១១- លោក | វ៉ាន់ | ម៉ៅ | ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ | សមាជិក |
| ១២- លោក | សុខ | ណារិទ្ធ | អនុប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ | សមាជិក |
| ១៣- លោក | ឈូ | ចំរើន | មន្ត្រី | សមាជិក |

**ប្រការ២៖** គណៈកម្មាធិការនេះ មានភារកិច្ចដូចតទៅ៖

- រៀបចំ និងអនុវត្តគោលនយោបាយជំនាញមាត្រាសាស្ត្រ
- ជំរុញឱ្យមានការរៀបចំ បណ្តុះបណ្តាលជំនាញមាត្រាសាស្ត្រ
- ពិនិត្យ និងសម្រេចលើសមត្ថភាពជំនាញដល់រូបវន្តបុគ្គល
- ទំនាក់ទំនង និងស្វែងរកកិច្ចគាំទ្រពីអង្គការជាតិ និងអន្តរជាតិ។

**ប្រការ៣៖** នីតិវិធី និងបែបបទនៃការវាយតម្លៃសមត្ថភាពជំនាញមាត្រាសាស្ត្រ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៤៖** ប្រកាសលេខ ១៧៥ ឧថ.ម.ម.ជ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពី ការបង្កើតគណៈកម្មាធិការបច្ចេកទេសជំនាញមាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវបានចាត់ទុកជានិរាករណ៍។

**ប្រការ៥៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាន គ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត រូបវន្តបុគ្គលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី-ខេត្ត
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ

លេខ 316 ... ថ្ងៃទី 27 ខែកក្កដា ឆ្នាំ 2015 ម៉ោង 10:47 នាទី ព្រឹក

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៦៣៤ MIH / 2015

# ប្រកាស
## ស្តីពី
## ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត
## ជូនមន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្ត លើការផ្តល់សេវាសាធារណៈ
- យោងប្រកាសអន្តរក្រសួងលេខ ៣៩៥ MIH / 2014 ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការគ្រប់គ្រងនិងប្រើប្រាស់ថវិកាចំណូលពីការអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យារបស់ភាគីជួលទីតាំងអចលនទ្រព្យ
- យោងប្រកាសរួមលេខ ៧១៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងប្រកាសរួមលេខ ៧១៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្ត ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**ប្រការ១៖** ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់ឧបត្ថម្ភជូនមន្ត្រីរាជការ ដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀតលើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ២៖** ការផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានផ្ដល់ជូនដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្ដល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្ដាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** អនុញ្ញាតឱ្យរដ្ឋបាលកណ្ដាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្ត ដោយកាត់យកពីប្រាក់ចំណូលដែលប្រមូលបាន ផ្អែកតាមសមាមាត្រដែលកំណត់ដោយប្រកាសរួមលេខ ៧១៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់រង្វាន់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកជាប្រាក់បុរេប្រទានដែលបានបើកផ្ដល់ដោយថវិកាជាតិ។

**ប្រការ៤៖** ការផ្ដល់ប្រាក់រង្វាន់ជូនរដ្ឋបាលកណ្ដាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបែងចែកដូចខាងក្រោម៖

**១.ថ្នាក់រដ្ឋបាលកណ្ដាល ៖**

ក-ចំណូលពីកម្រៃសេវាសាធារណៈ:

**ក១-ចំណូលពីការចេញវិញ្ញាបនបត្រអនុលោមផលិតផល និងវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ៖**

-បង់ចូលថវិកាជាតិចំនួន ២០% នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១% នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ៧៩% នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖

+៣០% ប្រគល់ជូនរដ្ឋលេខាធិការ/ចំណូលក្រសួង សម្រាប់ផ្ដល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់នៅក្នុងទីស្ដីការក្រសួង

+៧០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ក២-ចំណូលពីការធ្វើតេស្តវិភាគ មីក្រូជីវសាស្ត្រ រូប-គីមីសាស្ត្រ ការចុះយក ឬការទទួល និងចាត់បញ្ជូនសំណាកគំរូផលិតផល នៅតាមរាជធានី ខេត្ត ដែលជាការងាររបស់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា នៃវិទ្យាស្ថានស្តង់ដារកម្ពុជា៖**

-បង់ចូលថវិកាជាតិចំនួន ២០% នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១%នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ៧៩% នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖

+៣០% ប្រគល់ជូនរដ្ឋលេខាធិការ/ចំណូលក្រសួង សម្រាប់ផ្ដល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់នៅក្នុងទីស្ដីការក្រសួង

+៧០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ក៣-ចំណូលពីការធ្វើព្យាសកម្ម អនុម័តគំរូ តេស្ត វិភាគ ត្រួតពិនិត្យផ្ទៀងផ្ទាត់ប្រភេទឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ទំនិញវេចខ្ចប់ ដែលជាការងាររបស់មន្ទីរពិសោធន៍មាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ៖**

-បង់ចូលថវិកាជាតិចំនួន ២០% នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១%នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ៧៩% នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖

+៤០% ប្រគល់ជូនរដ្ឋលេខាធិការ/ចំណូលក្រសួង សម្រាប់ផ្ដល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់នៅក្នុងទីស្ដីការក្រសួង

+៦០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ក៤-ចំពោះចំណូលពីសេវាសាធារណៈ ក្រៅពីចំណុច ក១ ក២ និងក៣ ខាងលើ**

-បង់ចូលថវិកាជាតិចំនួន ៥០% នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១% នៃប្រាក់ចំណូលដែលប្រមូលបាន

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ៤៩% នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖
+៧០% ប្រគល់ជូនរដ្ឋទេយ្យករចំណូលក្រសួង សម្រាប់ផ្ដល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់នៅក្នុងទីស្តីការក្រសួង
+៣០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល

ខ-ចំណូលពីការពិន័យអន្តរការណ៍ជាប្រាក់ និងពិន័យរដ្ឋបាល

-បង់ចូលថវិកាជាតិចំនួន ៥០% នៃប្រាក់ចំណូលដែលប្រមូលបាន
-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១% នៃប្រាក់ចំណូលដែលប្រមូលបាន
-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ៤៩% នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖
+៥០% ប្រគល់ជូនរដ្ឋទេយ្យករចំណូលក្រសួង សម្រាប់ផ្ដល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់នៅក្នុងទីស្តីការក្រសួង
+៥០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

គ-ចំណូលពីការអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យារបស់តាតីជួលទីតាំងអចលនទ្រព្យក្នុងចន្លោះសមាមាត្រពី 0,២%-0,៥% នៃប្រាក់ចំណេញពិតប្រចាំឆ្នាំ ដែលមានចែងក្នុងកិច្ចសន្យាជួល ៖ ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្មចំនួន ១០០% នៃប្រាក់ចំណូលដែលប្រមូលបានដោយចែកជា ១២ខែ សម្រាប់ផ្ដល់ជារង្វាន់លើកទឹកចិត្ត ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ក្នុងទីស្តីការក្រសួង បន្ថែមទៅលើប្រាក់រង្វាន់លើកទឹកចិត្តពីការផ្ដល់សេវាសាធារណៈ។

## ២.ថ្នាក់មន្ទីរជំនាញរាជធានី ខេត្ត ៖

ក-ចំណូលពីសេវាសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ៖
-បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងប្រកាសរួមលេខ ៧១៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥
-ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ចំណូលដែលប្រមូលបាន
-ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងប្រកាសរួមលេខ ៧១៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ក្នុងនោះ ៖
+៧០% ប្រគល់ជូនរដ្ឋទេយ្យករចំណូលមន្ទីរ សម្រាប់ផ្ដល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីរាជការទាំងអស់នៅក្នុងមន្ទីរ
+៣០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

ខ-ចំពោះប្រភេទសេវាណាដែលមន្ទីរជំនាញរាជធានី ខេត្ត ទទួលបានការធ្វើប្រតិភូកម្មមុខងារឱ្យបំពេញភារកិច្ចណាមួយជួសក្រសួង ៖
-បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១ ភ្ជាប់នឹងប្រកាសរួមលេខ ៧១៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥
-ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ១% នៃប្រាក់ចំណូលដែលប្រមូលបាន
-ចំពោះប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបែងចែកដូចខាងក្រោម៖
ខ១-ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្តចំនួន ៨០% ក្នុងនោះ ៖
+៧០% ប្រគល់ជូនរដ្ឋទេយ្យករចំណូលមន្ទីរ សម្រាប់ផ្ដល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីរាជការទាំងអស់នៅក្នុងមន្ទីរ
+៣០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល

ខ២-ជូនមកអង្គភាពជំនាញទទួលបន្ទុកថ្នាក់រដ្ឋបាលកណ្ដាលចំនួន ២០% ក្នុងនោះ ៖

+៥០% ប្រគល់ជូនរដ្ឋទេយ្យករចំណូលក្រសួង សម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់នៅក្នុងទីស្តីការក្រសួង

+៥០% សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**៣.គោលការណ៍បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ៖**

ក-ប្រាក់រង្វាន់លើកទឹកចិត្តសរុប

ប្រាក់រង្វាន់លើកទឹកចិត្តដែលប្រមូលបានទាំងអស់ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នឹងធ្វើការបែងចែកជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ តាមខែនីមួយៗ ដោយឈរលើគោលការណ៍សមធម៌ ដែលត្រូវបានប្រគល់ជូនជាកញ្ចប់ដល់គ្រប់អង្គភាពក្រោមឱវាទក្រសួង។

ខ-ប្រាក់រង្វាន់លើកទឹកចិត្តរបស់អង្គភាព

**ខ១-ថ្នាក់រដ្ឋបាលកណ្តាល ៖** គ្រប់អង្គភាពក្រោមឱវាទក្រសួង ក្រោយពីទទួលបានកញ្ចប់ប្រាក់រង្វាន់លើកទឹកចិត្តពីនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុហើយនោះ ត្រូវធ្វើការបែងចែកជូនមន្ត្រីរាជការក្រោមឱវាទតាមគោលការណ៍កំណត់របស់ក្រសួង។ អង្គភាពនីមួយៗ ត្រូវធ្វើរបាយការណ៍នៃការចំណាយមកនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ត្រឹមថ្ងៃទី០៥ នៃខែបន្ទាប់ ដើម្បីធ្វើរបាយការណ៍បូកសរុបទូទាត់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមាន៖ (១.ការចំណាយសម្រាប់ពង្រឹងយន្តការប្រមូលចំណូល) (២.ការចំណាយសម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការ)។

**ខ២-ថ្នាក់មន្ទីរជំនាញរាជធានី ខេត្ត ៖** ត្រូវធ្វើការបែងចែកជូនមន្ត្រីរាជការក្រោមឱវាទតាមគោលការណ៍កំណត់របស់ក្រសួង ហើយត្រូវធ្វើរបាយការណ៍នៃការចំណាយមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម(នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ) ត្រឹមថ្ងៃទី០៥ នៃខែបន្ទាប់ ដើម្បីធ្វើរបាយការណ៍បូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមាន៖ ១.ការចំណាយសម្រាប់ពង្រឹងយន្តការប្រមូលចំណូល ២.ការចំណាយសម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការ។

**ប្រការ៥៖** គោលការណ៍នៃការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តខាងលើនេះ អាចនឹងប្រែប្រួលទៅតាមការចាំបាច់របស់ក្រសួង ដោយអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៦៖** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥ តទៅ។

**ប្រការ៧៖** ប្រកាសលេខ ០៧១ MIH / 2014 ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលកណ្តាល នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គនាយិកា អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ គ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**



**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- ដូចប្រការ ៨ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១២៣ MIH / 2015

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ

-បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញប្រកាសលេខ ៤១៥ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងស្លាកសញ្ញាទំនិញផលិត និងទំនិញវេចខ្ចប់

-បានឃើញប្រកាសលេខ ៤១២ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ

-បានឃើញប្រកាសលេខ ៤១៣ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងមិនស្វ័យប្រវត្តិ

-យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ត្រូវបានធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដូចខាងក្រោម៖



4

ក- ការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ៖

- ជញ្ជីងមិនស្វ័យប្រវត្តិ ដែលមានសមត្ថភាពត្រឹម១០០០(មួយពាន់)គីឡូក្រាមចុះក្រោម
- ជញ្ជីងសម្រាប់ថ្លឹងវត្ថុមានតម្លៃ ដូចជា មាស ប្រាក់ ប្លាទីន ត្បូងពេជ្រ...
- ដៃបាញ់ប្រេងនៅតាមស្ថានីយ៍ ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈ និងឧស្ម័ន
- ឧបករណ៍វាស់ប្រេងឥន្ធនៈ ដែលប្រើកែវក្រិតវ៉ែ។

ខ- ការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់ ដែលបានផលិត និងចរាចរនៅលើទីផ្សារក្នុងភូមិសាស្ត្រ រាជធានី ខេត្ត។

**ប្រការ២.-**

មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត មានភារកិច្ចអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ព្រមទាំងលក្ខខណ្ឌ និងបទដ្ឋានបច្ចេកទេស ដែលបានកំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយត្រូវមានកាតព្វកិច្ចធ្វើរបាយការណ៍ជូនមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិតាមការតម្រូវ។

**ប្រការ៣.-**

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានសិទ្ធិចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើការបំពេញមុខងារដែលបានធ្វើប្រតិភូកម្មជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ដូចមានចែងក្នុងប្រការ១ ខាងលើ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

2015/804/Prakas on transferring Job of Metrology /KM/SST

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០២០ MIH / 2015

# ប្រកាស
## ស្ដីពី
## ការកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់សីតុណ្ហភាព

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជា ណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៤/១២៩៩ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកំណត់ស្តង់ដាគោលជាតិសីតុណ្ហភាព
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៨០ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ .–**

ត្រូវបានកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់សីតុណ្ហភាព ដែលត្រូវរក្សាទុកនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) មានអត្តសញ្ញាណ ដូចខាងក្រោម ៖

លេខសម្គាល់ : ០២៧១
គំរូលេខ : ៥៦៩៩
ឯកតា : អង្សាសេ ($^{o}C$)
សមត្ថភាពវាស់ : -២០០$^{o}C$ ដល់ +៦៦០$^{o}C$
ផលិតនៅ : ប្រទេសអាមេរិក
វត្ថុគំរូ : ស្តង់ដារសីតុណ្ហភាពដែលមានសំបកកញ្ចក់ពិសេសរេស៊ីស្តង់ធ្វើពីប្លាទីន

អត្តសញ្ញាណ នៃស្តង់ដារបន្ទាប់សីតុណ្ហភាព មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២ .–**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាន ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៥
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចម ប្រសិទ្ធ

កន្លែងទទួល ៖
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី ខេត្ត
- ដូចប្រការ២
- ឯកសារ កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

## ឧបសម្ព័ន្ធ

នៃប្រកាសលេខ ០៧០ MIH/2015 ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៥

## ស្ដីពីស្តង់ដាចន្លាប់សីតុណ្ហភាព



ប្រអប់សម្រាប់ថែរក្សាស្ដង់ដាចន្លាប់សីតុណ្ហភាពពេលបញ្ជូនទៅធ្វើព្យាសកម្ម



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៦៥ MIH / 2015

# ប្រកាស
## ស្តីពី
## ការកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់ គីឡូក្រាម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៤/៩៩០ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកំណត់ស្តង់ដារគោលជាតិគីឡូក្រាម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៨០ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ត្រូវបានកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់គីឡូក្រាម ដែលត្រូវរក្សាទុកនៅនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) មានអត្តសញ្ញាណ ដូចខាងក្រោម ៖

| | | |
|---|---|---|
| លេខសម្គាល់ | : | ២៣៣០២០៤ |
| ទម្ងន់ | : | ១ (មួយ) គីឡូក្រាម |
| ផលិតនៅ | : | ប្រទេសអាឡឺម៉ង់ |
| ចំណាត់ថ្នាក់ | : | អឺសូន្យ (E0) |
| វត្ថុគំរូ | : | សំលោហធាតុពិសេសដែលមិនច្រេះ |

អត្តសញ្ញាណនៃស្តង់ដារបន្ទាប់ គីឡូក្រាម មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាន ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចម ប្រសិទ្ធ

**កន្លែងទទួល ៖**
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី ខេត្ត
- ដូចប្រការ២
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

នៃប្រកាសលេខ ៩៦៩ MIH/2015 ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៥

**ស្តីពីការកំណត់ទទួលស្គាល់ស្តង់ដាបន្ទាប់ គីឡូក្រាម**

**ស្តង់ដាបន្ទាប់គីឡូក្រាម ទម្ងន់ ១ គ.ក្រ ថ្នាក់ E0**



**ប្រអប់សម្រាប់ថែរក្សាស្តង់ដាបន្ទាប់គីឡូក្រាមពេលបញ្ជូនទៅធ្វើព្យាសកម្ម**



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

Ministry of Industry & Handicraft

លេខៈ ០១៨ MIH / 2015

# ប្រកាស

## ស្ដីពី

## ការកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់លីត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៤/១២៩៨ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីការកំណត់ស្តង់ដាគោលជាតិលីត្រ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ១៨០ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ .–**

ត្រូវបានកំណត់ទទួលស្គាល់ស្តង់ដារបន្ទាប់ លីត្រ ដែលត្រូវរក្សាទុកនៅនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) មានអត្តសញ្ញាណ ដូចខាងក្រោម ៖

| | | |
|---|---|---|
| លេខសម្គាល់ | : | ៧៨១/២០០៤ |
| ចំណុះ | : | ៥ (ប្រាំ) លីត្រ |
| ផលិតនៅ | : | ប្រទេសអាឡឺម៉ង់ |
| វត្ថុធាតុ | : | ដុំក្រិតធ្វើពីសំណោហធាតុពិសេសដែលមិនច្រេះ |

អត្តសញ្ញាណនៃស្តង់ដារបន្ទាប់ លីត្រ មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២ .–**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាន ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៥

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចម ប្រសិទ្ធ

**កន្លែងទទួល ៖**
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី ខេត្ត
- ដូចប្រការ២
- ឯកសារ កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៤៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

# ឧបសម្ព័ន្ធ

នៃប្រកាសលេខ ០១៨ MIH/2015 ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៥

## ស្ដីពីការកំណត់ស្តង់ដាបន្ទាប់លីត្រ

## ស្តង់ដាបន្ទាប់លីត្រ ចំណុះ ៥ លីត្រ



លេខសម្គាល់/Serial No.: 781/2004

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៤១៥ MIH / 2014

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងស្លាកសញ្ញា ទំនិញផលិត និងទំនិញវេចខ្ចប់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៧៨ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.** ប្រកាសនេះមានគោលដៅកំណត់ពីបទប្បញ្ញត្តិបច្ចេកទេសដើម្បីប្រើប្រាស់ជាយន្តការក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់ ធ្វើឲ្យកាន់តែសុក្រិតនូវបរិមាណនៃទំនិញ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

ទាំងនោះ ស្របតាមបទប្បញ្ញត្តិជាធរមាន ធានាភាពយុត្តិធម៌ក្នុងសកម្មភាពពាណិជ្ជកម្ម និង ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ទំនិញ។

**ប្រការ២..** កំណត់និយមន័យវាក្យស័ព្ទបច្ចេកទេសប្រើប្រាស់ក្នុងបទប្បញ្ញត្តិបច្ចេកទេស មានដូចតទៅ៖

- **ទំហំឡូត៍** សំដៅដល់បរិមាណផលិតផល ទំនិញផលិត ឬទំនិញវេចខ្ចប់ដែលផលិតបាននៅក្នុងខ្សែសង្វាក់ផលិតកម្មក្នុងរយៈពេលមួយកំណត់។
- **ឡូត៍ត្រួតពិនិត្យ** សំដៅដល់បរិមាណផលិតផលទំនិញផលិត ឬទំនិញវេចខ្ចប់ដែលផលិតនៅពេលជាមួយគ្នាក្នុងលក្ខខណ្ឌដូចគ្នាតាមគំរូអនុម័តសម្រាប់កំណត់ការយល់ព្រម ឬមិនយល់ព្រមនៅពេលត្រួតពិនិត្យផ្ទៀងផ្ទាត់។
- **បរិមាណសន្មត** (Nominal Quantity - Qn) សំដៅដល់បរិមាណផលិតផលក្នុងកញ្ចប់ដែលបានបញ្ជាក់លើស្លាកសញ្ញាដោយអ្នកផលិត ឬអ្នកវេចខ្ចប់ស្របតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់។
- **បរិមាណពិត** (Actual Quantity - Qc) សំដៅដល់បរិមាណផលិតផលដែលបានពីការវាស់វាល់ ថ្លឹង ឬរាប់ជាក់ស្តែងដោយមន្ត្រីត្រួតពិនិត្យ។
- **បរិមាណសុទ្ធ** (Net Quantity) សំដៅដល់បរិមាណផលិតផលដែលមិនគិតពីសំបក និងសម្ភារវេចខ្ចប់ដទៃទៀត។
- **ផលិតផលទំនិញវេចខ្ចប់** សំដៅដល់ផលិតផល ឬទំនិញដែលបានរៀបចំដាក់ស្រេចបាច់ក្នុងសម្ភារវេចខ្ចប់តាមវិធីសាស្ត្រណាមួយដែលបរិមាណរបស់វាត្រូវបានកំណត់ និងបានបញ្ជាក់លើស្លាកសញ្ញាមុននឹងបញ្ចេញលក់ ហើយដែលគេមិនអាចផ្លាស់ប្តូរ ឬកែប្រែខុសពីភាពដើមឡើយ។
- **ទំនិញផលិត** សំដៅដល់ផលិតផល ទំនិញដែលបានផលិតតាមវិធីសាស្ត្រណាមួយដែលទំហំរបស់វាត្រូវបានកំណត់ និងបានបញ្ជាក់លើស្លាកសញ្ញាមុននឹងបញ្ចេញលក់ ហើយដែលគេមិនអាចផ្លាស់ប្តូរ ឬកែប្រែខុសពីភាពដើមឡើយ។
- **ទម្ងន់សំបក ឬកញ្ចប់** (Tare) សំដៅដល់ទម្ងន់សំបក ឬកញ្ចប់ដែលប្រើប្រាស់សម្រាប់វេចខ្ចប់ផលិតផលសម្រេច ហើយទម្ងន់សំបក ឬកញ្ចប់នោះត្រូវបានដកចេញក្រោយពីប្រើប្រាស់ផលិតផលសម្រេចរួច។
- **សម្ភារវេចខ្ចប់** (Packing Material) សំដៅដល់សម្ភារទាំងឡាយណាដែលយកមកប្រើប្រាស់វេចខ្ចប់ទំនិញផ្សេងៗ។
- **ផលិតផលទំនិញវេចខ្ចប់មិនសមស្រប** សំដៅដល់ផលិតផលទំនិញវេចខ្ចប់ដែលមានលំអៀងអវិជ្ជមានធំជាងលំអៀងអនុញ្ញាត។
- **គំរូចៃដន្យ** (Random Sampling) សំដៅដល់ការចាប់យកគំរូផលិតផលទំនិញវេចខ្ចប់ដោយចៃដន្យក្នុងឡូត៍ត្រួតពិនិត្យ (គំរូដែលជ្រើសរើសត្រូវមានប្រូបាប៊ីលីតេដូចគ្នា)។
- **គំរូផលិតផលទំនិញវេចខ្ចប់** សំដៅដល់ផលិតផលទំនិញដែលយកចេញពីឡូត៍ត្រួតពិនិត្យ ដើម្បីធ្វើជាទិន្នន័យសម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការវាយតម្លៃឡូត៍ត្រួតពិនិត្យ។

- **លំអៀងអនុញ្ញាត** (T) សំដៅដល់លំអៀងនៃបរិមាណផលិតផល អនុញ្ញាតស្របតាមឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ។
- **លំអៀងកញ្ចប់នីមួយៗ** (Individual Packaged Error) សំដៅដល់លំអៀងនៃបរិមាណផលិតផលក្នុងកញ្ចប់នីមួយៗ ។
- **ស្លាក** (Label) សំដៅដល់សញ្ញាផ្សេងៗសម្រាប់សម្គាល់ផលិតផលទំនិញវេចខ្ចប់ ឬទំនិញផលិត។
- **ស្តង់ដារប្រតិបត្តិ** សំដៅដល់ស្តង់ដារទី៣ ដែលភាពត្រឹមត្រូវរបស់វាត្រូវបានព្យាសកម្មដោយស្តង់ដារបន្ទាប់ ឬស្តង់ដារកម្រិតខ្ពស់ជាង។
- **បុគ្គល** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គល។
- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

**ប្រការ៣.** ការងារត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងស្លាកសញ្ញាទំនិញផលិត ឬទំនិញវេចខ្ចប់ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

ក. ចំពោះបរិមាណពិត (Qc) ជាទូទៅមិនត្រូវតិចជាងបរិមាណសន្មត (Qn) ឡើយ។

ខ. ចំពោះការបញ្ជាក់ពីទម្ងន់ និងចំណុះ៖

- ក្នុងករណីផលិតផល ទំនិញវេចខ្ចប់ ដែលមានលំអៀងអវិជ្ជមានធំជាងលំអៀងអនុញ្ញាតក្នុងតារាងទី១ នៃឧបសម្ព័ន្ធទី១ នឹងត្រូវបានអនុញ្ញាតផ្ទៀងផ្ទាត់ក្នុងឧបសម្ព័ន្ធទី២។
- មិនអនុញ្ញាតឲ្យផលិតផល ទំនិញវេចខ្ចប់ណាមានលំអៀងអវិជ្ជមានធំជាងពីរដងនៃលំអៀងដែលអនុញ្ញាតក្នុងតារាងទី១ នៃឧបសម្ព័ន្ធទី១ ឡើយ។
- ចំពោះផលិតផលជាល្បាយវត្ថុរាវ (Drained Weight Products) មិនអនុញ្ញាតឲ្យផលិតផលទំនិញវេចខ្ចប់ណាមួយមានលំអៀងអវិជ្ជមានធំជាងបីដងនៃលំអៀងអនុញ្ញាតក្នុងតារាងទី១ នៃឧបសម្ព័ន្ធទី១ ឡើយ។

គ. ចំពោះខ្នាតប្រវែងលំអៀងអវិជ្ជមានមិនអាចធំជាង២% នៃប្រវែងសន្មត ( Qn) និងចំពោះខ្នាតផ្ទៃក្រឡា លំអៀងអវិជ្ជមានមិនអាចធំជាង៣% នៃផ្ទៃក្រឡាសន្មតឡើយ។

ឃ. ការប្រកាសផលិតផលទំនិញវេចខ្ចប់ដែលបរិមាណសន្មតកំណត់តាមឯកតាជារាយ៖

- បរិមាណផលិតផលទំនិញវេចខ្ចប់ដែលមានរហូតដល់ ៥០ឯកតារាយក្នុងកញ្ចប់បរិមាណពិតមិនត្រូវតិចជាងបរិមាណសន្មតឡើយ។
- បរិមាណផលិតផលទំនិញវេចខ្ចប់ក្នុងកញ្ចប់ដែលមានបរិមាណពិតលើសពី៥០ឯកតារាយ លំអៀងអវិជ្ជមានក្នុងកញ្ចប់នីមួយៗ មិនត្រូវតិចជាងតម្លៃមធ្យមនៃបរិមាណសន្មតឡើយ ហើយលំអៀងអវិជ្ជមាននេះអាចអនុញ្ញាត បានតែ០១(មួយ)ឯកតារាយក្នុងរាល់១០០ឯកតារាយ។

- លក្ខខណ្ឌសីតុណ្ហភាពក្នុងបន្ទប់ត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវកំណត់ ២០°C ± ១.៥°C ក្នុងរយៈពេលមួយម៉ោង និង២០°C ± ២.០°C ក្នុងរយៈពេលជប់ពីរម៉ោង។ ចំពោះផលិតផលដែលប្រកាសជាខ្នាតចំណុះ ទោះជានៅពេលវេចខ្ចប់នៅសីតុណ្ហភាពណាក៏ដោយ ក្នុងពេលអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ គឺត្រូវធ្វើនៅសីតុណ្ហភាព២០°C។ លក្ខខណ្ឌសីតុណ្ហភាពនេះមិនអនុវត្តចំពោះផលិតផលប្រេងកាត ផលិតផលក្លាសេ និងផលិតផលបង្កកដែលបរិមាណរបស់វាបញ្ជាក់ជាខ្នាតចំណុះដែរ។

**ប្រការ៤..** រាល់ទំនិញផលិត និងទំនិញវេចខ្ចប់សម្រាប់លក់ និងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុលោមតាមលក្ខខណ្ឌដូចតទៅ៖

ក.លក្ខខណ្ឌបង្ហាញតាមស្លាកសញ្ញាផលិតផលទំនិញផលិត និងទំនិញវេចខ្ចប់ត្រូវកំណត់ដូចតទៅ៖

- អត្តសញ្ញាណនៃផលិតផល
- នាមករណ៍ និងអាសយដ្ឋានផលិតកម្ម អាជីវកម្ម អ្នកវេចខ្ចប់ អ្នកនាំចូល ឬអ្នកចែកចាយ
- បរិមាណសន្មតត្រូវអនុលោមតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ និងត្រូវធ្វើ ឬរៀបចំឡើងតាមការបញ្ជាក់ជាលក្ខណៈដើមនៃគំរូដែលបានអនុម័តពីទម្ងន់ ឬវង្វាស់វង្វាល់។

ខ. ផលិតផលទំនិញវេចខ្ចប់ដែលជាវត្ថុរាវត្រូវបញ្ជាក់បរិមាណសន្មត និងផលិតផលវេចខ្ចប់ផ្សេងទៀតដែលមិនមែនជាវត្ថុរាវត្រូវបញ្ជាក់ទម្ងន់សន្មត ឬឯកតារាយ។

គ.ទំហំតួអក្សរ និងតួលេខនៃបរិមាណសន្មត់ត្រូវគោរពតាមទំហំខ្នាតដូចមានក្នុងតារាងទី៥ នៃឧបសម្ព័ន្ធទី១។

ឃ.ឯកតា និងនិមិត្តសញ្ញាប្រើប្រាស់សម្រាប់បញ្ជាក់បរិមាណសន្មតនៃផលិតផលទំនិញផលិត និងទំនិញវេចខ្ចប់ត្រូវគោរពតាមប្រព័ន្ធឯកតានិមិត្តសញ្ញាមានក្នុងតារាងទី៦ និងទី៧នៃឧបសម្ព័ន្ធទី១។

**ប្រការ៥..** ការបង្ហាញអំពីបរិមាណសន្មតទំនិញវេចខ្ចប់ដែលមានល្បាយជាវត្ថុរាវ (Drained Weight) ត្រូវអនុលោមតាមឧបសម្ព័ន្ធទី៣។

**ប្រការ៦..** ការបញ្ជាក់បរិមាណផលិតផលទំនិញផលិត ឬទំនិញវេចខ្ចប់មានបរិមាណតិចជាង ៥g ឬ៥ml មិនតម្រូវឲ្យធ្វើការប្រកាសទេ តែក្នុងករណីប្រកាសបរិមាណមធ្យមនៃផលិតផលទំនិញផលិត ឬទំនិញវេចខ្ចប់ ត្រូវស្មើ ឬលើសបរិមាណសន្មត។

**ប្រការ៧..** ការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ផលិតករត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណផលិតផលទំនិញវេចខ្ចប់តាមគំរូអនុម័តរបស់ខ្លួនជាប្រចាំ។

- ផលិតករត្រូវធ្វើ និងរក្សារបាយការណ៍ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណសន្មតនៃផលិតផលរបស់ខ្លួនហើយត្រូវផ្តល់របាយការណ៍នោះជូនមន្ត្រីត្រួតពិនិត្យនៅពេលដែលមានតម្រូវការ។
- ផលិតករ អាជីវករត្រូវបង្កលក្ខណៈងាយស្រួលចំពោះមន្ត្រីត្រួតពិនិត្យក្នុងពេលបំពេញភារកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់។
- មន្ត្រីនីត្យានុកូលមាត្រាសាស្ត្រ ជាមន្ត្រីត្រួតពិនិត្យត្រូវមានឯកសណ្ឋាន និងលិខិតបញ្ជាបេសកកម្មត្រឹមត្រូវ មានសិទ្ធិចូលក្នុងរោងចក្រ សហគ្រាស ផលិតកម្ម អាជីវកម្ម ដើម្បីបំពេញការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលម៉ោងធ្វើការ ស្របតាមលក្ខខណ្ឌទំនិញវេចខ្ចប់ដែលបានចែងក្នុងច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ជំពូកទី៨ មាត្រា៣៣។
- ការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់តាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងកន្លែងលក់ដូរផ្សេងៗត្រូវអនុវត្តដោយអនុលោមតាមការកំណត់ដូចខាងក្រោម៖
    - ប្រភេទទំនិញផលិត និងទំនិញវេចខ្ចប់
    - ប្រព័ន្ធគុណភាពនៃខ្សែសង្វាក់ផលិតកម្ម
    - លទ្ធផលត្រួតពិនិត្យផ្ទៀងផ្ទាត់
    - ហានិភ័យនៃផលិតផល។

ករណីផលិតផលទំនិញផលិត និងទំនិញវេចខ្ចប់ដែលបានអនុលោមតាមលក្ខខណ្ឌខាងលើទាំងស្រុង ការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវធ្វើឡើង ០១(មួយ) ឆ្នាំម្តង ហើយបើមិនអនុលោមតាមលក្ខខណ្ឌណាមួយដូចខាងលើ ការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវធ្វើឡើង ០២(ពីរ)ដង ឬច្រើនដងក្នុងមួយឆ្នាំទៅតាមស្ថានភាពជាក់ស្តែង។

**ប្រការ៨..** ការស្រង់គំរូផលិតផលទំនិញផលិត និងទំនិញវេចខ្ចប់ សម្រាប់ត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖
- ចំពោះឡូត៍ត្រួតពិនិត្យច្រើនដែលមិនបង្ហាញពីភាពខុសគ្នា គឺត្រូវសន្មតថាវាដូចគ្នា
- ការស្រង់គំរូផលិតផលទំនិញវេចខ្ចប់ សម្រាប់ត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវធ្វើដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- ផលិតផលទំនិញផលិត ឬទំនិញវេចខ្ចប់សម្រាប់យកមកធ្វើគំរូ គឺត្រូវជ្រើសរើសដោយចៃដន្យ។

**ប្រការ៩..** រាល់ទំនិញផលិត និងផលិតផលទំនិញវេចខ្ចប់ដែលផលិតក្នុងព្រះរាជាណាចក្រកម្ពុជា និងនាំចូលពីបរទេសពាក់ព័ន្ធនឹងផ្នែកមាត្រាសាស្ត្រ ត្រូវស្ថិតក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិត្រូវជូនដំណឹងជាសាធារណៈ ដោយកំណត់ពេលវេលា និងទីកន្លែងដែលត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ ហើយមន្ត្រីត្រួតពិនិត្យត្រូវប្រើប្រាស់ស្តង់ដារប្រតិបត្តិដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

**ប្រការ១០**. រាល់ទំនិញផលិតដែលជាលោហធាតុ និងត្បូងមានតម្លៃ ការលក់ និងការដាក់តាំងសម្រាប់លក់ត្រូវមានការបញ្ជាក់អំពីបរិមាណទម្ងន់សុទ្ធ លើទំនិញផលិតទាំងនោះទៅតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

**ប្រការ១១**. បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២**. ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី.១៩....ខែឧសភា.ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**__កន្លែងទទួល__ ៖**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត

«__ដើម្បីជូនជ្រាប__»

- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត

«__ដើម្បីសហការអនុវត្ត__»

- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

**តារាងទី១**: លំអៀងអនុញ្ញាត (T)

| បរិមាណសន្មតនៃផលិតផល (Qn) ក្រាម (g) ឬមីលីលីត្រ (ml) | លំអៀងអនុញ្ញាត | |
|---|---|---|
| | ភាគរយនៃ Qn | ក្រាម(g) ឬមីលីលីត្រ (ml) |
| ៥ ដល់ ៥០ | ៩.០ | ---- |
| ៥០ ដល់ ១០០ | ---- | ៤.៥ |
| ១០០ ដល់ ២០០ | ៤.៥ | ---- |
| ២០០ ដល់ ៣០០ | ---- | ៩.០ |
| ៣០០ ដល់ ៥០០ | ៣.០ | ---- |
| ៥០០ ដល់ ១០០០ | ---- | ១៥.០ |
| ១០០០ ដល់ ១០០០០ | ១.៥ | ---- |
| ១០០០០ ដល់ ១៥០០០ | ---- | ១៥០ |
| ១៥០០០ ដល់ ៥០០០០ | ១ | ---- |

**សម្គាល់**: ក្នុងតារាងទី១តម្លៃលំអៀងអនុញ្ញាតបានបង្ហាញជាភាគរយហើយការគណនាជាខ្នាតទម្ងន់ ឬចំណុះ ត្រូវធ្វើការតំឡើង១ភាគ១០នៃក្រាម ឬមីលីលីត្រ។

**តារាងទី២**: បរិមាណសន្មតនៃផលិតផល (Qn) ជាប្រវែង

| បរិមាណសន្មតនៃផលិតផល (Qn) ជាប្រវែង | ភាគរយនៃ (Qn) |
|---|---|
| Qn ≤ ៥m | ពុំមានលំអៀងអនុញ្ញាត (T) |
| Qn ≥ ៥m | ២ |

**តារាងទី៣**: បរិមាណសន្ទតនៃផលិតផល (Qn) ជាក្រឡាផ្ទៃ

| បរិមាណសន្ទតនៃផលិតផល (Qn) ជាក្រឡាផ្ទៃ | ភាគរយនៃ (Qn) |
|---|---|
| គ្រប់ Qn | ៣ |

**តារាងទី៤**: បរិមាណសន្ទតនៃផលិតផល (Qn) ជាចំនួន

| បរិមាណសន្ទតនៃផលិតផល (Qn) ជាចំនួន | ភាគរយនៃ (Qn) |
|---|---|
| Qn ≤ ៥០ | ពុំមានលំអៀងអនុញ្ញាត (T) |
| Qn ≥ ៥០ | ១ |

**តារាងទី៥**: កម្ពស់អប្បបរមានៃតួលេខ និងតួអក្សរ

| បរិមាណសន្ទត ក្រាម (g) ឬមីលីលីត្រ (ml) | កម្ពស់អប្បបរមានៃតួលេខ និងតួអក្សរ មីលីម៉ែត្រ (mm) |
|---|---|
| Qn ≤ ៥០ | ២ |
| ៥០ ≤ Qn ≤ ២០០ | ៣ |
| ២០០ ≤ Qn ≤ ១០០០ | ៤ |
| Qn ≥ ១០០០ | ៦ |

**សម្គាល់**: ចំពោះបរិមាណសន្ទតជាឯកតារាយ (រាប់ចំនួនបាន) ជាប្រវែង និងជាឯកតាផ្ទៃក្រលាកម្ពស់អប្បបរមានៃតួលេខ និងតួអក្សរគឺ២មីលីម៉ែត្រ (2mm)។

**តារាងទី៦:** ឯកតារង្វាស់រង្វាល់ និងនិមិត្តសញ្ញា

| ឯកតា | និមិត្តសញ្ញា |
|---|---|
| - មីលីក្រាម (milligram) | mg |
| - ក្រាម (gram) | g |
| - គីឡូក្រាម(kilog ram) | kg |
| - តោន (tonne) | t |
| - លីត្រ (litre) | L or l |
| - មីលីលីត្រ (millilitre) | mL or ml |
| - មីក្រូម៉ែត្រ (micrometre) | µm |
| - មីលីម៉ែត្រ (millimetre) | mm |
| - សង់ទីម៉ែត្រ (centimetre) | cm |
| - ដេស៊ីម៉ែត្រ (decimetre) | dm |
| - ម៉ែត្រ (metre) | m |
| - មីលីម៉ែត្រការ៉េ (square millimetre) | $mm^2$ |
| - សង់ទីម៉ែត្រការ៉េ (square centimetre) | $cm^2$ |
| - ម៉ែត្រការ៉េ (square metre) | $m^2$ |
| - សង់ទីម៉ែត្រគូប (cubic centimetre) | $cm^3$ |
| - ដេស៊ីម៉ែត្រគូប (cubic decimetre) | $dm^3$ |
| - ម៉ែត្រគូប (cubic metre) | $m^3$ |

**តារាងទី៧**: ឯកតា

| ប្រភេទនៃរង្វាស់រង្វាល់ | បរិមាណសន្មតនៃផលិតផល (*q*) = (Qn) | ឯកតា |
|---|---|---|
| ចំណុះ (វត្ថុរាវ) | *q* < ១០០០ ml | mL (ml) |
| | ១០០០ml ≤ *q* | L (l) |
| ចំណុះ-គូប (វត្ថុរឹង) | *q* ≤ ១០០០$cm^3$ (១$dm^3$) | $cm^3$, mL (ml) |
| | ១$dm^3$ < *q* < ១០០០ $dm^3$ | $dm^3$, L (l) |
| | ១០០០$dm^3$ ≤ *q* | $m^3$ |
| ទម្ងន់ ឬម៉ាស | *q* < ១g | Mg |
| | ១g ≤ *q* < ១០០០g | g |
| | ១០០០g ≤ *q* | kg |
| ប្រវែង | *q* < ១mm | mm |
| | ១mm ≤ *q* ≤ ១០០cm | mm ឬ cm |
| | ១០០cm ≤ *q* | m |
| ក្រលាផ្ទៃ | *q* < ១០០$cm^2$ (១$dm^2$) | $mm^2$ ឬ $cm^2$ |
| | ១$dm^2$ ≤ *q* < ១០០$dm^2$ (១$m^2$) | $dm^2$ |
| | ១$m^2$ ≤ *q* | $m^2$ |

**តារាងទី៨**: ភាពត្រឹមត្រូវនៃការប្រើប្រាស់ស្តង់ដារប្រតិបត្តិផ្នែកឧបករណ៍ទម្ងន់ សម្រាប់មន្ត្រីត្រួតពិនិត្យទំនិញផលិត និងទំនិញវេចខ្ចប់

| ទម្ងន់សរុបក្នុងកញ្ចប់ជាក្រាម (g) | ប្រទ្បោះក្រិត (d) ជាក្រាម (g) |
|---|---|
| តិចជាង២៥ | ០.០១ |
| ពី២៥ដល់តិចជាង១០០០ | ០.១ |
| ពី១០០០ដល់តិចជាង៥០០០ | ១.០ |
| ពី៥០០០និងច្រើនជាង | ២.០ |

**តារាងទី៩**: លក្ខខណ្ឌសមស្របនៃការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រសម្រាប់អ្នកវេចខ្ចប់

| បរិមាណសន្ទុតជាក្រាម (g) ឬមីលីលីត្រ (ml) | ប្រឡោះក្រិត (d) ជាក្រាម (g) |
|---|---|
| តិចជាង១០ | ០.១ |
| ពី១០ដល់តិចជាង៥០ | ០.២ |
| ពី៥០ដល់តិចជាង១៥០ | ០.៥ |
| ពី ១៥០ដល់តិចជាង ៥០០ | ១.០ |
| ពី៥០០ដល់តិចជាង២៥០០ | ២.០ |
| ពី២៥០០និងច្រើនជាង | ៥.០ |

# ឧបសម្ព័ន្ធទី២

## ១-ចំនួនគំរូសម្រាប់យកមកត្រួតពិនិត្យផ្ទៀងផ្ទាត់

| ទំហំឡូត៍ត្រួតពិនិត្យ<br>L | ចំនួនគំរូ<br>n | ចំនួនអនុញ្ញាត<br>c | មេគុណកែតម្រូវ<br>k |
|---|---|---|---|
| ១០០ដល់៥០០ | ៥០ | ៣ | ០.៣៧៩ |
| ៥០១ដល់៣២០០ | ៨០ | ៥ | ០.២៩៥ |
| ច្រើនជាង៣២០០ | ១២៥ | ៧ | ០.២៣៨ |

$\overline{X_0} = \overline{X_i} + ks$ (s គឺជាគំលាតស្តង់ដារនៃ $X_i$)

$\overline{X_0}$ គឺជាតម្លៃមធ្យមកំណៃ

$\overline{X_i}$ គឺជាតម្លៃមធ្យមនៃ $X_i$

$X_i$ គឺជាចំនួនគំរូ

## ២-តេស្តសរុប

ចំពោះទំហំឡូត៍ត្រួតពិនិត្យដែលមានបរិមាណតិចជាង១០០ ការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវធ្វើ ១០០%។ បរិមាណផលិតផលទំនិញវេចខ្ចប់សមស្របមិនត្រូវលើសពី២.៥%ទេ។

## ៣-តេស្តពិសេស

| ទំហំឡូត៍ត្រួតពិនិត្យ<br>L | ទំហំគំរូ<br>n | ចំនួនអនុញ្ញាត<br>c | មេគុណកែតម្រូវ<br>k |
|---|---|---|---|
| ស្មើ ឬច្រើនជាង១០០តិចតួច | ២០ | ១ | ០.៦៤០ |

## ៤-គម្រោងស្រង់គំរូផលិតផលទំនិញវេចខ្ចប់ដែលបរិមាណសន្ទត់បញ្ជាក់ជាឯកតាប្រវែង ផ្ទៃក្រឡា និងឯកតាជារាយ

| ទំហំឡូត៍ត្រួតពិនិត្យ L | ទំហំគំរូ n | ចំនួនអនុញ្ញាត c | មេគុណកែតម្រូវ a |
|---|---|---|---|
| ២៦ដល់៥០ | ៣ | ០ | ១.០០ |
| ៥១ដល់ ១៥០ | ៥ | ០ | ០.៣៥ |
| ១៥១ដល់៥០០ | ៨ | ១ | ០.២០ |
| ៥០១ដល់៣២០០ | ១៣ | ១ | ០.១៥ |
| ៣២០១និងច្រើនជាង | ២០ | ១ | ០.១០ |

$\overline{X_0} = \overline{X_i} + aR$ (Rគឺជាគំលាតរវាង $X_{i\,max}$ និង $X_{i\,min}$)

$\overline{X_0}$ គឺជាតម្លៃមធ្យមកំណែ

$\overline{X_i}$ គឺជាតម្លៃមធ្យមនៃ $X_i$

$X_i$ គឺជាចំនួនគំរូ

## ៥- លំអៀងអវិជ្ជមាននៃផលិតផលទំនិញវេចខ្ចប់មិនដូចគ្នា

| បរិមាណសន្ទត (Qn) ជាក្រាម (g) | លំអៀងអវិជ្ជមានដែលអនុញ្ញាតជាក្រាម (g) |
|---|---|
| រហូតដល់៥០០ | ២.០ |
| ពី៥០១ដល់២០០០ | ៥.០ |
| ពី២០០១ដល់១០០០០ | ១០.០ |

## ឧបសម្ព័ន្ធទី៣

### របៀបរបបកំណត់បញ្ជាក់អំពីបរិមាណសុទ្ធផលិតផលទំនិញវេចខ្ចប់ ដែលមានក្នុងល្បាយវត្ថុរាវ

- **លទ្ធភាពទី១**

ផលិតផលទំនិញវេចខ្ចប់ដែលផ្សំឡើងជាល្បាយ ដោយវត្ថុធាតុពីរប្រភេទខុសគ្នាក្រោយការប្រើប្រាស់រួចវត្ថុធាតុមួយក្លាយទៅជាកាកសំណល់។ ឧទាហរណ៍ៈ គ្រសក់ត្រាំផ្សំដោយវត្ថុធាតុរឹងគឺគ្រសក់ និងវត្ថុធាតុរាវគឺទឹកជ្រក់គ្រសក់។

ការត្រួតពិនិត្យបរិមាណសុទ្ធនៃផលិតផលទំនិញវេចខ្ចប់នេះ ប្រព្រឹត្តទៅលើតែបរិមាណនៃសមាសភាពរឹងគឺទម្ងន់គ្រសក់។

- **លទ្ធភាពទី២**

ផលិតផលទំនិញវេចខ្ចប់ ដែលផ្សំឡើងដោយវត្ថុធាតុច្រើនមុខមានប្រភេទរឹង និងប្រភេទរាវក្រោយពីការប្រើប្រាស់រួចមិនមានប្រភេទណាចាត់ទុកជាកាកសំណល់ទេ។ ឧទាហរណ៍ៈ មៀនកំប៉ុងដែលផ្សំដោយផ្លែមៀន និងទឹកផ្អែម។

ការត្រួតពិនិត្យបរិមាណសុទ្ធនៃផលិតផលទំនិញវេចខ្ចប់នេះ ប្រព្រឹត្តទៅលើបរិមាណសុទ្ធសរុបនៃវត្ថុធាតុទាំងពីរប្រភេទ។

- **លទ្ធភាពទី៣**

ផលិតផលទំនិញវេចខ្ចប់ដែលផ្សំឡើងដោយវត្ថុធាតុច្រើនមុខមានប្រភេទ រឹង និងប្រភេទរាវ ប៉ុន្តែយើងមិនអាចកំណត់បានថាជាកាកសំណល់ ឬមិនមែនជាកាកសំណល់។ ដូចនេះសមាសភាពនីមួយៗត្រូវបញ្ជាក់នៅលើស្លាកសញ្ញានៃផលិតផលទំនិញវេចខ្ចប់នោះ។

ការត្រួតពិនិត្យបរិមាណសុទ្ធនៃផលិតផលទំនិញវេចខ្ចប់នេះប្រព្រឹត្តទៅលើបរិមាណដែលបានបញ្ជាក់នៅលើស្លាកសញ្ញានៃផលិតផលទំនិញវេចខ្ចប់។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៤១៤ MIH / 2014

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់ស៊ីទែន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៧៨ MIH/ 2014 ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.** ប្រកាសនេះមានគោលដៅ កំណត់ពីបទប្បញ្ញត្តិបច្ចេកទេសដើម្បីប្រើប្រាស់ជាយន្តការក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ស៊ីទែនផ្ទុកចំណុះវត្ថុរាវ ជានាភាពយុត្តិធម៌ក្នុងសកម្មភាពពាណិជ្ជកម្ម ក្នុង



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

គោលបំណងឲ្យការធ្វើពាណិជ្ជកម្ម ឬអាជីវកម្មផ្សេងៗមានភាពត្រឹមត្រូវ សុចរិត ធានាផល ប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់។

**ប្រការ២.** កំណត់និយមន័យវាក្យស័ព្ទបច្ចេកទេសប្រើប្រាស់ក្នុងបទប្បញ្ញត្តិបច្ចេកទេសមានដូចតទៅ ៖

- **ស៊ីទែន** (Road -Rail Tanker) សំដៅដល់ឧបករណ៍ទាំងឡាយណាដែលប្រើសម្រាប់ផ្ទុក ចំណុះវត្ថុរាវដែលមានក្រិតបរិមាណជាក់លាក់ ហើយតម្លើងភ្ជាប់ទៅនឹងគ្រប់មធ្យោបាយ ដឹកជញ្ជូន។
- **ចំណុះពិត** (True Volume - $V_t$) សំដៅដល់ចំណុះកំណត់ដែលបង្ហាញនៅលើស៊ីទែននៅ តាមឃ្លប់នីមួយៗ។
- **ចំណុះបង្ហាញ** (Indicated Volume - $V_i$) សំដៅដល់ចំណុះដែលបង្ហាញបរិមាណជាក់ ស្តែងក្នុងពេលវាស់ដោយស្តង់ដារប្រតិបត្តិតាមឃ្លប់នីមួយៗ។
- **លំអៀង** (Error) សំដៅដល់ផលដករវាងចំណុះបង្ហាញ និងចំណុះពិត។
- **នីវ៉ូ** (Level) សំដៅដល់កម្រិតផ្ទៃលើវត្ថុរាវក្នុងឃ្លប់នីមួយៗ។
- **ចំណុចគោលលើ** (Reference Point Top - RPT) សំដៅដល់ចំណុចគោលផ្នែកខាងលើ នៃស៊ីទែន។
- **ចំណុចគោលបាត** (Reference Point Bottom - RPB) សំដៅដល់ចំណុចគោលបាត របស់ស៊ីទែន។
- **កម្ពស់ស៊ីទែន** (Hight - H) សំដៅដល់ប្រវែងអ័ក្សឈរពីចំណុចគោលបាត (RPB) មក ចំណុចគោលផ្នែកខាងលើ(RPT) នៃស៊ីទែន។
- **កម្ពស់វត្ថុរាវ** (Liquid Height - h) សំដៅដល់ដល់ប្រវែងអ័ក្សឈរពីនីវ៉ូវត្ថុរាវដល់ចំណុចគោល បាត (RPB) នៃស៊ីទែន។
- **កម្ពស់យូឡាយ** (Ullage height - C) សំដៅដល់ប្រវែងអ័ក្សឈរពីនីវ៉ូមកដល់ចំណុច គោលលើ (RPT) នៃស៊ីទែន ។
- **ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង** សំដៅដល់ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើ ឧបករណ៍មាត្រាសាស្ត្រថ្មី ឬដែលបានជួសជុលរួច មុនពេលដាក់ឲ្យប្រើប្រាស់។
- **ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់** សំដៅដល់បណ្តាប្រភេទនៃការត្រួត ពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរួច ហើយ និងកំពុងប្រើប្រាស់។
- **ស្តង់ដារប្រតិបត្តិ** សំដៅដល់ស្តង់ដារថ្នាក់ទី៣ ដែលភាពត្រឹមត្រូវរបស់វាត្រូវបានព្យាសកម្ម ដោយស្តង់ដារបន្ទាប់ ឬស្តង់ដារកម្រិតខ្ពស់ជាង។
- **បុគ្គល** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គល។
- **មន្ត្រីត្រួតពិនិត្យ**
សំដៅដល់មន្ត្រីមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។ ៜ

**ប្រការ៣..** ស៊ីទែនផ្ទុកចំណុះវត្ថុរាវទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងចរាចរធ្វើពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ឬមុនពេលដាក់ឲ្យប្រើប្រាស់ ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និង/ឬត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ មន្ត្រីត្រួតពិនិត្យត្រូវប្រើប្រាស់ស្តង់ដារប្រតិបត្តិធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ទៅតាមវិធីសាស្ត្រដែលកំណត់ដោយប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រ។

**ប្រការ៤..** មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិត្រូវធ្វើសេចក្តីជូនដំណឹង កំណត់ពេលវេលា និងទីកន្លែងក្នុងការអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ស៊ីទែនផ្ទុកចំណុះរាវ។

**ប្រការ៥..** - ស៊ីទែនផ្ទុកចំណុះវត្ថុរាវដែលកាន់កាប់ ឬប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងបច្ចេកទេសពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ត្រូវធ្វើឡើង ០១(មួយ)ដង ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ។

- មុនពេលអស់សុពលភាពយ៉ាងតិច ០១(មួយ) ខែ បុគ្គលដែលកាប់កាប់ប្រើប្រាស់ស៊ីទែនផ្ទុកវត្ថុរាវក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ត្រូវស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិដើម្បីអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញការកិច្ចរបស់មន្ត្រីត្រួតពិនិត្យស្របទៅតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

**ប្រការ៦..** មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិត្រូវចាត់បញ្ជូនមន្ត្រីចុះធ្វើអធិការកិច្ច ដោយត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងករណីមានពាក្យបណ្តឹង ឬការតវ៉ា ឬការសង្ស័យពីភាពមិនប្រក្រតីនៃស៊ីទែនផ្ទុកវត្ថុរាវ ។

**ប្រការ៧..** ត្រូវបានអនុវត្តចំពោះស៊ីទែនដែលមានចំណាត់ថ្នាក់ និងផ្ទុកប្រភេទសារជាតុដូចខាងក្រោម៖

| ចំណាត់ថ្នាក់ស៊ីទែន( Accuracy Class ) | ប្រភេទសារជាតុដែលត្រូវផ្ទុក |
|---|---|
| ០,៥ | -ស៊ីទែនសម្រាប់ផ្ទុកវត្ថុរាវដែលមានភាពស្អិតមិនលើសពី ២០ MPa.s នៅសីតុណ្ហភាពដំណើរការ<br>-ស៊ីទែនសម្រាប់ផ្ទុកទឹកដោះគោ, ស្រាបៀរ និងសារជាតុពពុះផ្សេងទៀត<br>-ស៊ីទែនសម្រាប់ផ្ទុកប្រេងឥន្ធនៈសម្រាប់យន្តហោះ |
| ១,០ | -ស៊ីទែនសម្រាប់ផ្ទុកហ្គាសនៅសីតុណ្ហភាពស្មើ ឬធំជាង -១០ ° C |
| ១,៥ | -ស៊ីទែនសម្រាប់ផ្ទុក កាបូនឌីអុកស៊ីត Carbon Dioxide<br>-ស៊ីទែនសម្រាប់ផ្ទុកហ្គាសនៅសីតុណ្ហភាពតូចជាង -១០ ° C |
| ២,៥ | -ស៊ីទែនសម្រាប់ផ្ទុក សារជាតុត្រជាក់ Cryogenic |

**ប្រការ៨..** ការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវអនុវត្តតាមគោលការណ៍ និង បទប្បញ្ញត្តិបច្ចេកទេសដូចខាងក្រោម៖

ក. ការត្រួតពិនិត្យដោយភ្នែកធម្មតា ត្រូវផ្ទៀងផ្ទាត់នូវរាល់ចំណុចទាំងឡាយដូចតទៅ៖

- ប្រមូលព័ត៌មានពីតារាងស្លាកព័ត៌មាន
- មើលស្ថានភាពស៊ីទែនផ្នែកខាងមុខ និងខាងក្រោយ
- នីវ៉ូរបស់រថយន្ត
- ចំនួនឃ្លុប
- ពាណិជ្ជនាម
- ប្រភេទស៊ីទែន
- លេខកូត
- វិញ្ញាបនបត្រអនុម័តគំរូ ឬព្យាសកម្ម

ខ. ត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពរស់របស់ស៊ីទែន ( Sensitive test )

គ. ត្រួតពិនិត្យផ្ទៀងផ្ទាត់ចំណុះស៊ីទែនដោយរកកម្រិតលំអៀង ( Instrument Error test )

ឃ.ត្រួតពិនិត្យផ្ទៀងផ្ទាត់ការលិចជ្រាបរបស់ស៊ីទែន ( Leak test )

ង. ត្រួតពិនិត្យផ្ទៀងផ្ទាត់ការបង្ហូរអស់ពីបាតស៊ីទែន ( Drainage test )

**ប្រការ៩..** កម្រិតលំអៀងអនុញ្ញាតនៃស៊ីទែនដែលធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់មានដូចខាងក្រោម៖

**១. កម្រិតលំអៀងអនុញ្ញាតចំពោះការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង៖**

| ប្រភេទស៊ីទែន | ចំណាត់ថ្នាក់ និងកម្រិតលំអៀងអនុញ្ញាតអតិបរមា | | | |
|---|---|---|---|---|
| | **០,៥** | **១,០** | **១,៥** | **២,៥** |
| ស៊ីទែនវាស់ដោយអេឡិចត្រូនិច | ± ០,៥% | ± ១,០% | ± ១,៥% | ± ២,៥% |
| ស៊ីទែនដឹកជញ្ជូន | ± ០,៣% | ± ០,៥% | ± ១,០% | ± ១,៥% |

**២. កម្រិតលំអៀងអនុញ្ញាតចំពោះការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់៖**

| ប្រភេទស៊ីទែន | ចំណាត់ថ្នាក់ និងកម្រិតលំអៀងអនុញ្ញាតអតិបរមា | | | |
|---|---|---|---|---|
| | ០,៥ | ១,០ | ១,៥ | ២,៥ |
| ស៊ីទែនវាស់ដោយអេឡិចត្រូនិច | ± ០,៧៥% | ± ១,០% | ± ១,៥% | ± ២,៥% |
| ស៊ីទែនដឹកជញ្ជូន | ± ០,៥% | ± ០,៥% | ± ១,០% | ± ១,៥% |

**ប្រការ១០..** បន្ទាប់ពីត្រួតពិនិត្យផ្ទៀងផ្ទាត់ឃើញកម្រិតលំអៀងអនុញ្ញាតអនុលោមតាម ប្រការ៩ ខាងលើ មន្ត្រីត្រួតពិនិត្យត្រូវដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើស៊ីទែន និងការគាបសំណ ( seal )

លើនីវ៉ូតាមឃ្លប់នីមួយៗបញ្ជាក់ពីភាពត្រឹមត្រូវ និងជាការធានាមិនឲ្យមានការកែបន្លំក្រោយពីការត្រួតពិនិត្យផ្ទៀងផ្ទាត់រួចហើយ។

**ប្រការ១១..** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២..** ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨... ខែ ឧសភា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u>** ៖
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត

«ដើម្បីជូនជ្រាប»

- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត

«ដើម្បីសហការអនុវត្ត»

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៤១៧ MIH / 2014

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិបច្ចេកទេសក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងមិនស្វ័យប្រវត្តិ
(Non Automatic Weighing Instrument)

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៧៨ MIH/ 2014 ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១..** ប្រកាសនេះមានគោលដៅ កំណត់ពីបទប្បញ្ញត្តិបច្ចេកទេសដើម្បីប្រើប្រាស់ជាយន្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងដំណើរការមិនស្វ័យប្រវត្តិ ធានាភាពយុត្តិធម៌ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម សំដៅឲ្យការធ្វើពាណិជ្ជកម្ម សេវាកម្ម ឬអាជីវកម្មផ្សេងៗមានភាពត្រឹមត្រូវ សុចរិត



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

ជានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ព្រមទាំងធ្វើឲ្យកាន់តែសុក្រិតនូវបរិមាណទំនិញផលិត និងទំនិញវេចខ្ចប់ដែលវាស់វាល់ដោយជញ្ជីងទាំងអស់នោះ។

**ប្រការ២.** កំណត់និយមន័យវាក្យស័ព្ទបច្ចេកទេសប្រើប្រាស់ក្នុងបទប្បញ្ញត្តិបច្ចេកទេស មានដូចតទៅ៖

- **ជញ្ជីង** សំដៅដល់ឧបករណ៍សម្រាប់ថ្លឹងទម្ងន់ដាក់លាក់របស់វត្ថុរឹង រាវ និងឧស្ម័នដោយប្រៀបធៀបជាមួយដែនទំនាញផែនដី។
- **ជញ្ជីងមិនស្វ័យប្រវត្តិ** (NAWI) សំដៅដល់ជញ្ជីងដែលដំណើរការដោយមានអ្នកប្រតិបត្តិ។
- **ជញ្ជីងមានក្រិត** (Graduated) សំដៅដល់ជញ្ជីងដែលបង្ហាញលទ្ធផលផ្ទាល់នូវទម្ងន់ជាលេខ។
- **ជញ្ជីងមិនមានក្រិត** (Non-graduated) សំដៅដល់ជញ្ជីងដែលមិនមានក្រិតបង្ហាញជាលេខ។
- **ជញ្ជីងបង្ហាញលេខដោយខ្លួនឯង** (Self indicating) សំដៅដល់ជញ្ជីងដែលបង្ហាញលេខដោយខ្លួនឯងមិនមានអ្នកប្រតិបត្តិ។
- **ជញ្ជីងបង្ហាញលេខពាក់កណ្ដាល** (Semi-Self indicating) សំដៅដល់ជញ្ជីងដែលបង្ហាញលេខដោយខ្លួនឯងមានអ្នកប្រតិបត្តិផ្លាស់ប្តូរប្រឡោះដែលអាចថ្លឹងបាន។
- **ជញ្ជីងមិនបង្ហាញលេខដោយខ្លួនឯង** (Non-Self indicating) សំដៅដល់ជញ្ជីងដែលមានទីតាំងលំនឹងត្រូវបានដំណើរការដោយមានអ្នកប្រតិបត្តិ។
- **ទម្ងន់អតិបរិមា** (Maximum capacity) សំដៅដល់ទម្ងន់ដែលអាចថ្លឹងធំបំផុតដោយមិនរាប់បញ្ចូលការកំណត់សំបក។
- **ទម្ងន់អប្បបរិមា** (Minimum capacity) សំដៅដល់ទម្ងន់ដែលអាចថ្លឹងតូចបំផុត។
- **ចន្លោះក្រិត** (Actual scale interval - d) សំដៅដល់តម្លៃនៃទម្ងន់ដែលជាផលសងរវាងតម្លៃដែលបង្ហាញបន្តបន្ទាប់គ្នា។
- **ផ្ទៀងផ្ទាត់ចន្លោះក្រិត** (Verification scale interval - e) សំដៅដល់តម្លៃនៃទម្ងន់ប្រើសម្រាប់បែងចែកចំណាត់ និងការត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីង។
- **ចំនួនផ្ទៀងផ្ទាត់ចន្លោះក្រិត** (Number of verification scale interval - n) សំដៅដល់ផលធៀបរវាងទម្ងន់អតិបរិមា និងតម្លៃផ្ទៀងផ្ទាត់ចន្លោះក្រិត។
- **លំអៀង** (Error) សំដៅដល់លទ្ធផលដែលបានដោយផលដករវាងទម្ងន់បង្ហាញ និងទម្ងន់ពិត។
- **កំរិតលំអៀងអនុញ្ញាតអតិបរិមា** (MPE) សំដៅដល់ដែនកំណត់នៃលំអៀងដែលអនុញ្ញាតដោយលិខិតបទដ្ឋានគតិយុត្តនានា។
- **ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង** សំដៅដល់ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រថ្មី ឬដែលបានជួសជុលរួចមុនពេលដាក់ឲ្យប្រើប្រាស់។
- **ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់** សំដៅដល់បណ្ដាប្រភេទនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរួច ហើយនិងកំពុងប្រើប្រាស់។
- **ស្តង់ដារប្រតិបត្តិ** សំដៅដល់ស្តង់ដារថ្នាក់ទី៣ ដែលភាពត្រឹមត្រូវរបស់វាត្រូវបានព្យាសកម្មដោយស្តង់ដារបន្ទាប់ ឬស្តង់ដារកម្រិតខ្ពស់ជាង។



2

- **បុគ្គល** សំដៅដល់និតិបុគ្គល ឬរូបវន្តបុគ្គល។
- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

**ប្រការ៣.** ជញ្ជីងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងចរាចរធ្វើពាណិជ្ជកម្ម អាជីកម្ម ឬក្រោយពីជួសជុលកែតម្រូវរួចមុនពេលដាក់ឲ្យប្រើប្រាស់ ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និង/ឬត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ មន្ត្រីត្រួតពិនិត្យត្រូវប្រើប្រាស់ស្តង់ដាប្រតិបត្តិធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ទៅតាមវិធីសាស្ត្រដែលកំណត់ដោយប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**ប្រការ៤.** មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវធ្វើសេចក្តីជូនដំណឹងកំណត់ពេលវេលា និងទីកន្លែងក្នុងការអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីង។

**ប្រការ៥.** - ជញ្ជីងដែលកាន់កាប់ ឬប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ឲ្យបានត្រឹមត្រូវតាមកាលកំណត់ពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ត្រូវធ្វើឡើង ១(មួយ) ដង ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ។

- មុនពេលអស់សុពលភាពយ៉ាងតិច ០១(មួយ) ខែ បុគ្គលដែលកាប់កាប់ប្រើប្រាស់ជញ្ជីងក្នុងការធ្វើពាណិជ្ជកម្ម សេវាកម្ម អាជីវកម្ម ត្រូវស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិដើម្បីអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យស្របទៅតាមច្បាប់ស្តីពីមាត្រាសាស្ត្រ និងលក្ខខណ្ឌតម្រូវនានាដែលពាក់ពន្ធ័នឹងបច្ចេកទេស។

**ប្រការ៦.** មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវចាត់បញ្ជូនមន្ត្រីចុះធ្វើអធិការកិច្ច ដោយត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងករណីមានពាក្យបណ្តឹង ការតវ៉ា ឬការសង្ស័យពីភាពមិនប្រក្រតីនៃជញ្ជីង ។

**ប្រការ៧.** បទប្បញ្ញត្តិបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់នេះ ត្រូវបានអនុវត្តចំពោះជញ្ជីងដែលបានកំណត់ចំណាត់ថ្នាក់នៃភាពត្រឹមត្រូវ (Accuracy Class) ដូចខាងក្រោម៖

- ចំណាត់ថ្នាក់ទី១ (Accuracy class 1) ដែលមាននិមិត្តសញ្ញា (I)
- ចំណាត់ថ្នាក់ទី២ (Accuracy class 2) ដែលមាននិមិត្តសញ្ញា (II)
- ចំណាត់ថ្នាក់ទី៣ (Accuracy class 3) ដែលមាននិមិត្តសញ្ញា (III)
- ចំណាត់ថ្នាក់ទី៤ (Accuracy class 4) ដែលមាននិមិត្តសញ្ញា (IIII) ។ ៚

ការកំណត់ចំណាត់ថ្នាក់របស់ជញ្ជីងតាមចំនួនផ្ទៀងផ្ទាត់ចន្លោះក្រិតដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ផ្ទៀងផ្ទាត់ចន្លោះក្រិត e | ចំនួនផ្ទៀងផ្ទាត់ចន្លោះក្រិត n = Max/e | | ទម្ងន់ថ្លឹងតូចបំផុត |
|---|---|---|---|---|
| | | តូចបំផុត | ធំបំផុត | |
| ថ្នាក់ទី១ | 0.001 g ≤e | 50 000 | - | 100 e |
| ថ្នាក់ទី២ | 0.001 g≤ e ≤ 0.05g<br>0.1 g≤ e | 100<br>5 000 | 100 000<br>100 000 | 20 e<br>50 e |
| ថ្នាក់ទី៣ | 0.1 g≤ e ≤ 2g<br>5 g≤ e | 100<br>500 | 10 000<br>10 000 | 20 e<br>20 e |
| ថ្នាក់ទី៤ | 5 g≤ e | 100 | 1 000 | 10 e |

**ប្រការ៨..** ការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវអនុវត្តតាមគោលការណ៍ និងបទប្បញ្ញត្តិបច្ចេកទេសដូចខាងក្រោម៖

ក. ការកំណត់អត្តសញ្ញាណជញ្ជីង

១- ឯកតាទម្ងន់ជា មីលីក្រាម, ក្រាម, គីឡូក្រាម និងតោន (mg, g, kg, t)

២- ចំណាត់ថ្នាក់នៃភាពត្រឹមត្រូវ

៣- ចំនួនផ្ទៀងផ្ទាត់ចន្លោះក្រិត

៤- ពាណិជ្ជនាម ឬម៉ាក

៥- ឆ្នាំផលិត និងលេខសេរី

៦- ទម្ងន់ថ្លឹងធំបំផុត និងតូចបំផុត

៧- លេខអនុម័តគំរូ ឬព្យាសកម្ម

ខ. លក្ខខណ្ឌនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងមាន ០៦ (ប្រាំមួយ) ដំណាក់កាលដូចតទៅ

១. ការកំណត់ត្រង់ចំណុចសូន្យ (Zero Setting)

២. ការកំណត់សំបក (Tare Setting Accuracy)

៣. ការផ្ទៀងផ្ទាត់តាមទីតាំង (Eccentricity test)

៤. ការផ្ទៀងផ្ទាត់ដដែល (Repeatability test)

៥. ការផ្ទៀងផ្ទាត់រំញោច (Discrimination test)

៦. ការផ្ទៀងផ្ទាត់ដោយការថ្លឹង (Weighing performance test) ⸗

**ប្រការ៩..** កម្រិតលំអៀងអនុញ្ញាតអតិបរិមានៃភាពត្រឹមត្រូវរបស់ជញ្ជីង ( Maximum Permissible Error ) សម្រាប់ការផ្ទៀងផ្ទាត់លើកដំបូងត្រូវបានកំណត់ដូចតារាងខាងក្រោម៖

| កម្រិតលំអៀង | m ជាកន្សោមចំនួនផ្ទៀងផ្ទាត់ចន្លោះក្រិត, e | | | |
|---|---|---|---|---|
| អនុញ្ញាត | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ |
| ±0.5e<br>±1.0e<br>±1.5e | 0≤ m ≤ 50 000<br>50 000 < m ≤ 200 000<br>200 000 < m | 0≤ m ≤ 5 000<br>5 000 < m ≤ 20 000<br>20 000 < m ≤ 100 000 | 0≤ m ≤ 500<br>500 < m ≤ 2000<br>2000 < m ≤ 10 000 | 0≤ m ≤ 50<br>50 < m ≤ 200<br>200 < m ≤ 1000 |

ចំពោះកម្រិតលំអៀងអនុញ្ញាតអតិបរមាសម្រាប់ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់គឺ ០២(ពីរ)ដងនៃកម្រិតលំអៀងអនុញ្ញាតអតិបរមាសម្រាប់ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង។

**ប្រការ១០..** បន្ទាប់ពីត្រួតពិនិត្យផ្ទៀងផ្ទាត់ឃើញកម្រិតលំអៀងអនុលោមតាម ប្រការ៩ ខាងលើមន្ត្រីត្រួតពិនិត្យត្រូវបិទសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើជញ្ជីង និងកឹបសៀល (seal) លើជញ្ជីងនីមួយៗ បញ្ជាក់ពីភាពត្រឹមត្រូវ និងជាការធានាមិនឲ្យមានការកែបន្លំក្រោយពីការត្រួតពិនិត្យផ្ទៀងផ្ទាត់រួចហើយ។

**ប្រការ១១..** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២..** ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩.. ខែ ឧសភា.. ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ចម_ប្រសិទ្ធ

**កន្លែងទទួល ៖**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត

  "ដើម្បីជូនជ្រាប"
- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត

  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៤១៥ MIH / 2014

# ប្រកាស
# ស្តីពី
# សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៧៨ MIH/ 20141ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១..** សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ សម្រាប់បិទភ្ជាប់លើឧបករណ៍មាត្រាសាស្ត្រលើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង ឬក្នុងពេលប្រើប្រាស់ដែលអនុលោមតាមការតម្រូវនៃបទប្បញ្ញត្តិបច្ចេកទេស និងច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា មានលំនាំស្រដៀង LOGO របស់



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ហើយមានបញ្ជាក់ពាក្យ ដំបូង ឆ្នាំ បញ្ជាក់ពីការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ និងអត្តលេខសម្គាល់នៃការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង ឬក្នុងពេលប្រើប្រាស់។ ទំហំសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ អាចតូច ឬធំបាន ដោយត្រូវសមាមាត្រទៅនឹងគំរូដែលបង្ហាញនៅក្នុងឧបសម្ព័ន្ធទី១ និងទី២។

**ប្រការ២.-** សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្ររបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មានពីរប្រភេទគឺៈ សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និងសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ ដូចមានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃប្រកាសនេះ។

សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ ប្រើសម្រាប់បិទភ្ជាប់លើឧបករណ៍មាត្រាសាស្ត្រទាំងអស់រួមមាន ឧបករណ៍មាត្រាសាស្ត្រនាំចូល ផលិត ជួសជុល កែតម្រូវរួច ដាក់លក់ ឬដាក់តាំងសម្រាប់លក់ និងកំពុងប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងវិស័យផ្សេងៗទៀត ជាការបញ្ជាក់ពីភាពត្រឹមត្រូវតាមការតម្រូវនៃបទប្បញ្ញត្តិបច្ចេកទេស និងច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ក្នុងគោលបំណងឲ្យការធ្វើពាណិជ្ជកម្ម ឬអាជីវកម្មផ្សេងៗ មានភាពយុត្តិធម៌ ត្រឹមត្រូវ សុចរិត ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ផលិតផល ទំនិញ សេវាកម្ម និងគ្រប់គ្រង ធ្វើឲ្យមានជំនឿ និងទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ព្រមទាំងធ្វើឲ្យកាន់តែសុក្រិតនូវបរិមាណ ទំនិញផលិត និងទំនិញវេចខ្ចប់ដែលវាស់វាល់ដោយឧបករណ៍មាត្រាសាស្ត្រទាំងអស់នោះ។

**ប្រការ៣.-** រាល់ឧបករណ៍មាត្រាសាស្ត្រថ្មី និងបន្ទាប់ពីការជួសជុល ឬកែតម្រូវរួច អាចលក់ ឬដាក់តាំងសម្រាប់លក់ និងអាចកាន់កាប់ដើម្បីប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងវិស័យផ្សេងៗទៀតបាន លុះត្រាតែឧបករណ៍ទាំងនោះមានការបញ្ជាក់ពីការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និងមានសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរបស់មន្ត្រីត្រួតពិនិត្យនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**ប្រការ៤.-** រាល់ឧបករណ៍មាត្រាសាស្ត្រ ដែលប្រើប្រាស់ក្នុងវិស័យដូចខាងក្រោមៈ

- ឧបករណ៍មាត្រាសាស្ត្រដាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យសុខភាពសាធារណៈ
- ឧបករណ៍មាត្រាសាស្ត្រដាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យសេវាកម្មប្រៃសណីយ៍
- ឧបករណ៍មាត្រាសាស្ត្រដាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យអគ្គីសនី ប្រេងឧស្ម័ន និងទឹក
- ឧបករណ៍មាត្រាសាស្ត្រដាក់លាក់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម វិស្វកម្ម ឬវិស័យផ្សេងៗទៀត ឧបករណ៍មាត្រាសាស្ត្រដែលបានរៀបរាប់ខាងលើនេះអាចកាន់កាប់ដើម្បីប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម បានលុះត្រាតែគោរពតាមលក្ខខណ្ឌដូចខាងក្រោមៈ

ក. ត្រូវមានការបញ្ជាក់ពីការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និងបិទសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរបស់មន្ត្រីត្រួតពិនិត្យនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ចំពោះឧបករណ៍មាត្រាសាស្ត្រថ្មីដែលនឹងត្រូវយកមកប្រើប្រាស់ ឬឧបករណ៍មាត្រាសាស្ត្រដែល

# ឧបសម្ព័ន្ធ២

## សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់




រូបភាព ២ - សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់

**សម្គាល់ :**

- YYYY : ឆ្នាំបញ្ជាក់ពីការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់
- XXXX : អត្តលេខសម្គាល់នៃសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់
- ម.ម.ជ : មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- NMC : National Metrology Center

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៤១១ MIH / 2014

# ប្រកាស
## ស្តីពី
## បទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់កុងទ័រចែកចាយប្រេងឥន្ធនៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៧៨ MIH/ 2014ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.** ប្រកាសនេះមានគោលដៅ កំណត់ពីបទប្បញ្ញត្តិបច្ចេកទេសដើម្បីប្រើប្រាស់ជាយន្តការក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់កុងទ័រប្រេងឥន្ធនៈ ជានាភាពយុត្តិធម៌ក្នុងសកម្មភាពពាណិជ្ជកម្ម សេវាកម្ម


ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: ( ៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: ( ៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

ទើបជួសជុល ឬកែតម្រូវរួច និងគោរពតាមលក្ខខណ្ឌនៃប្រកាសស្តីពីនីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ។

ខ. ត្រូវមានការបញ្ជាក់ពីការត្រួតពិនិត្យក្នុងពេលប្រើប្រាស់ និងបិទសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ ដោយមន្ត្រីត្រួតពិនិត្យនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**ប្រការ៥..** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦..** ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម-ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត

"ដើម្បីសហការអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ១

## សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង




រូបភាព ១ - សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង

សម្គាល់ :

ជំបូជ : ជាសញ្ញាបញ្ជាក់ពីការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង

XXXX : អត្តលេខសម្គាល់នៃសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង

ម.ម.ជ : មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

NMC : National Metrology Center

អាជីវកម្ម សំដៅឲ្យការធ្វើពាណិជ្ជកម្ម សេវាកម្ម ឬអាជីវកម្មផ្សេងៗមានភាពត្រឹមត្រូវ សុចរិត ជានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់។

**ប្រការ២..** កំណត់និយមន័យវាក្យស័ព្ទបច្ចេកទេសប្រើប្រាស់ក្នុងបទប្បញ្ញត្តិបច្ចេកទេសនេះ មានដូចតទៅៈ

- **កុងទ័រប្រេង** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលប្រើប្រាស់សម្រាប់វាស់វាល់បរិមាណចំណុះប្រេងឥន្ធនៈដែលហូរឆ្លងកាត់។
- **ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង** សំដៅដល់ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រថ្មី ឬដែលបានជួសជុលរួចមុនពេលដាក់ឲ្យប្រើប្រាស់។
- **ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់** សំដៅដល់បណ្តាប្រភេទនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរួចហើយ និងកំពុងប្រើប្រាស់។
- **ស្តង់ដារប្រតិបត្តិ** សំដៅដល់ស្តង់ដារថ្នាក់ទី៣ដែលភាពត្រឹមត្រូវរបស់វាត្រូវបានព្យាសកម្មដោយស្តង់ដារបន្ទាប់ ឬស្តង់ដារកម្រិតខ្ពស់ជាង។
- **បុគ្គល** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គល។
- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីមានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

**ប្រការ៣..** កុងទ័រចែកចាយប្រេងឥន្ធនៈទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងចរាចរធ្វើពាណិជ្ជកម្ម សេវាកម្ម អាជីវកម្ម ឬក្រោយពីជួសជុលកែតម្រូវរួច មុនពេលដាក់ឲ្យប្រើប្រាស់ ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និង/ឬ ត្រួតពិនិត្យក្នុងពេលប្រើប្រាស់ដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ មន្ត្រីត្រួតពិនិត្យត្រូវប្រើប្រាស់ស្តង់ដារប្រតិបត្តិ ធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ទៅតាមនីតិវិធីសាស្ត្រដែលកំណត់ដោយប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**ប្រការ៤..** មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវធ្វើសេចក្តីជូនដំណឹង កំណត់ពេលវេលា និងទីកន្លែងក្នុងការអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់កុងទ័រចែកចាយប្រេងឥន្ធនៈ។

**ប្រការ៥..** - កុងទ័រចែកចាយប្រេងឥន្ធនៈដែលកាន់កាប់ ឬប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងបច្ចេកទេសពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ត្រូវធ្វើឡើង ០១(មួយ)ដង ក្នុងរយៈពេល០១(មួយ)ឆ្នាំ។

- មុនពេលអស់សុពលភាពយ៉ាងតិច ០១(មួយ)ខែ បុគ្គលដែលកាប់កាប់ ប្រើប្រាស់កុងទ័រចែកចាយប្រេងឥន្ធនៈក្នុងការធ្វើពាណិជ្ជកម្ម អាជីវកម្ម សេវាកម្ម ត្រូវស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិដើម្បីអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យស្របទៅតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

**ប្រការ៦.** មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវចាត់បញ្ជូនមន្ត្រីចុះធ្វើអធិការកិច្ចដោយត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងករណីមានពាក្យបណ្តឹង ឬការតវ៉ា ឬការសង្ស័យពីភាពមិនប្រក្រតីនៃកុងទ័រចែកចាយប្រេងឥន្ធនៈ ។

**ប្រការ៧.** ប្រភេទកុងទ័រប្រេងឥន្ធនៈចែកជាពីរប្រភេទសំខាន់ៗគឺ ៖

- កុងទ័រចែកចាយប្រេងឥន្ធនៈដំឡើងតាមស្ថានីយ៍ប្រេងឥន្ធនៈ ឬស្ថានីយ៍រង និងកន្លែងចែកចាយផ្សេងទៀត
- កុងទ័រចែកចាយប្រេងឥន្ធនៈ (Flow meter ) ដែលមានអង្កត់ផ្ចិតទុយោលើសពី ២៥មម។

**ប្រការ៨.** ការត្រួតពិនិត្យផ្ទៀងផ្ទាត់ត្រូវអនុលោមតាមគោលការណ៍ និងបទប្បញ្ញត្តិបច្ចេកទេសដូចខាងក្រោមៈ

១. ការត្រួតពិនិត្យដោយភ្នែកចម្បតាត្រូវផ្ទៀងផ្ទាត់នូវរាល់ចំណុចដូចតទៅ ៖

- ស្រង់ព័ត៌មានពីតារាងលើស្លាកព័ត៌មាន
- ប្រព័ន្ធការពារសុវត្ថិភាព
- ប្រព័ន្ធគ្រឿងបង្គុំរបស់កុងទ័រចែកចាយប្រេងឥន្ធនៈ
- ឈ្មោះពាណិជ្ជនាម
- មើលវិញ្ញាបនបត្រអនុម័តគំរូ ឬវិញ្ញាបនបត្រព្យាសកម្ម

២. លក្ខខណ្ឌនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់របស់កុងទ័រចែកចាយប្រេងឥន្ធនៈមានពីរវិធីសាស្ត្រៈ

ក. ការត្រួតពិនិត្យផ្ទៀងផ្ទាត់របស់កុងទ័រចែកចាយប្រេងឥន្ធនៈដោយវិធីវាស់ចំណុះ៖

- លក្ខខណ្ឌនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់គឺដោយលំហូរធំ និងលំហូរតូច
- ការគណនារកកម្រិតលំអៀង៖

លំហូរតូច $E = [(I-Q)/Q] \times 100$ ដែល $Q = Q_S - e$

លំហូរធំ $E = [(I-Q)/Q] \times 100$ ដែល $Q = Q_L - e$

<u>ដែល</u>

E - ជាកម្រិតលំអៀងគិតជា ភាគរយ (%)

I - ជាចំណុះដែលបង្ហាញដោយកុងទ័រចែកចាយប្រេងឥន្ធនៈគិតជា លីត្រ(L)

$Q_s$ - ជាចំណុះដែលបង្ហាញដោយធុងគំរូនៃលំហូរតូចគិតជា លីត្រ(L)

$Q_L$ - ជាចំណុះដែលបង្ហាញដោយធុងគំរូនៃលំហូរធំគិតជា លីត្រ(L)

e - ជាកម្រិតលំអៀងរបស់ធុងគំរូគិតជា លីត្រ(L)

Q - ជាចំណុះពិតគិតជា លីត្រ(L)

ខ. ការត្រួតពិនិត្យផ្ទៀងផ្ទាត់របស់កុងទ័រចែកចាយប្រេងឥន្ធនៈដោយវិធីថ្លឹង៖

- លក្ខខណ្ឌនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់គឺដោយលំហូរធំ និងលំហូរតូច
- ជញ្ជីងគំរូ និងដង់ស៊ីតេគំរូប្រើសម្រាប់ថ្លឹង និងវាស់ដង់ស៊ីតេរបស់ប្រភេទប្រេង
- ការគណនារកកម្រិតលំអៀង៖

លំហូរតូច $E = [(I-Q)/Q] \times 100$ ដែល $Q = (W_2-W_1)/(d-0.0011)$

លំហូរធំ $E = [(I-Q)/Q] \times 100$ ដែល $Q = (W_2-W_1)/(d-0.0011)$

<u>ដែល</u>

E - ជាកម្រិតលំអៀងគិតជា ភាគរយ (%)

I - ជាចំណុះដែលបង្ហាញដោយកុងទ័រចែកចាយប្រេងឥន្ធនៈគិតជា លីត្រ(L)

$W_1$ - ជាទំងន់ធុងទទេដែលបង្ហាញដោយជញ្ជីងគំរូគិតជា គីឡូក្រាម(kg)

$W_2$ - ជាទំងន់ធុងមានប្រេងដែលបង្ហាញដោយជញ្ជីងគំរូគិតជា គីឡូក្រាម(kg)

d - ជាដង់ស៊ីតេរបស់ប្រេងដែលអានដោយដង់ស៊ីតេម៉ែត្រគំរូ

Q - ជាចំណុះពិតគិតជា លីត្រ(L)

**ប្រការ៩..** កម្រិតលំអៀងអនុញ្ញាតអតិបរមា សម្រាប់ការត្រួតពិនិត្យផ្ទៀងផ្ទាត់កុងទ័រចែកចាយប្រេងឥន្ធនៈ មានដូចខាងក្រោម៖

- កម្រិតលំអៀងអនុញ្ញាតសម្រាប់ការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងគឺ ± 0.៥%
- កម្រិតលំអៀងអនុញ្ញាតចំពោះការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់គឺ ± ១%។

**ប្រការ១០..** បន្ទាប់ពីត្រួតពិនិត្យផ្ទៀងផ្ទាត់ឃើញកម្រិតលំអៀងអនុលោមតាម ប្រការ៩ ខាងលើ មន្ត្រីត្រួតពិនិត្យ ត្រូវដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើម៉ាស៊ីននៃកុងទ័រចែកចាយប្រេងឥន្ធនៈ និងកឹបសៀល (seal) លើម៉ាស៊ីនបូមនីមួយៗបញ្ជាក់ពីភាពត្រឹមត្រូវ និងជាការធានាមិនឲ្យមានការកែបន្លំក្រោយពីការត្រួតពិនិត្យផ្ទៀងផ្ទាត់រួចហើយ។

**ប្រការ១១..** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២..** ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

ចម-ប្រសិទ្ធ

**<u>កន្លែងទទួល</u>៖**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត

«ដើម្បីជូនជ្រាប»

- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត

«ដើម្បីសហការអនុវត្ត»

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៥១៧ MIH / 2014

# ប្រ កា ស
## ស្តីពី
## នីតិវិធី និងបែបបទនៃការស្នើសុំនាំចូលឧបករណ៍មាត្រាសាស្ត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៨១ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## ស ម្រេ ច

**ប្រការ១._**

ប្រកាសនេះ មានគោលដៅកំណត់ យន្តការ និងវិធានគ្រប់គ្រងការនាំចូលឧបករណ៍មាត្រាសាស្ត្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២._**

ប្រកាសនេះមានគោលបំណង ៖

- ធានាឱ្យការធ្វើពាណិជ្ជកម្ម សេវាកម្ម មានភាពយុត្តិធម៌ និងត្រឹមត្រូវ
- ជំរុញឱ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ស្របតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)២៣ ២១១ ៧៣៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

- ធ្វើឱ្យមានជំនឿចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីធានាសុខភាព សុវត្ថិភាព និងបរិស្ថាន។

**ប្រការ៣.**_

ប្រកាសនេះ មានវិសាលភាពអនុវត្តលើបុគ្គលដែលនាំចូលឧបករណ៍មាត្រាសាស្ត្រ សម្រាប់សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្ម និង/ឬ វិស័យផ្សេងទៀត ដោយអនុលោមតាមច្បាប់ស្តីពីមាត្រាសាស្ត្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.**_

វាក្យស័ព្ទសំខាន់ៗ ប្រើសម្រាប់ក្នុងប្រកាសនេះ មានដូចតទៅ ៖

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបម្រើឱ្យវិស័យមាត្រាសាស្ត្រ។

**ពាណិជ្ជកម្ម** សំដៅដល់ ទំនាក់ទំនង ឬ កិច្ចសន្យា កិច្ចព្រមព្រៀង ការលក់ ការទិញ យោងតាមមាត្រា១៩ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ និងរាប់បញ្ចូលទាំងការវេចខ្ចប់ទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**អ្នកស្នើសុំ** សំដៅដល់ បុគ្គលដែលចុះហត្ថលេខាលើពាក្យស្នើសុំ។

**អ្នកនាំចូល** សំដៅដល់ បុគ្គលដែលបានអនុញ្ញាតឱ្យនាំចូលនូវឧបករណ៍មាត្រាសាស្ត្រ។

**បុគ្គល** សំដៅដល់ នីតិបុគ្គល ឬ រូបវន្តបុគ្គល។

**ពាក្យស្នើសុំ** សំដៅដល់ ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ជាសំណើផ្លូវការដោយលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំ ដើម្បីទទួលបាននូវសិទ្ធិលើការនាំចូលឧបករណ៍មាត្រាសាស្ត្រ ដូចមានទម្រង់ដែលកំណត់ក្នុងប្រកាសនេះ។

**លិខិតអនុញ្ញាត** សំដៅដល់ លិខិតគតិយុត្តដែលអនុញ្ញាតឱ្យបុគ្គលដែលនាំចូល ឬ មានបំណងនាំចូលឧបករណ៍មាត្រាសាស្ត្រ ជាលាយលក្ខណ៍អក្សរដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ឯកសារតម្រូវ** សំដៅដល់ ឯកសារពាក់ព័ន្ធនានាដែលតម្រូវឱ្យមានភាពអនុលោមជាមួយលក្ខខណ្ឌដែលបានកំណត់ក្នុងប្រកាសនេះ ។

**មន្ត្រីមានសមត្ថកិច្ច** សំដៅដល់ មន្ត្រីរាជការរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**នាយកដ្ឋានទទួលបន្ទុក** សំដៅដល់ នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**រដ្ឋមន្ត្រី** សំដៅដល់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥.**_

រាល់ឧបករណ៍មាត្រាសាស្ត្រ អាចអនុញ្ញាតឱ្យនាំចូល សម្រាប់សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្ម និង/ឬ វិស័យផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់ស្តីពីមាត្រាសាស្ត្រ ត្រូវមានលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៦.**_

រាល់នាំចូលឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទស្នើសុំ នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម រៀងរាល់ម៉ោងនៃថ្ងៃធ្វើការ។

ឯកសារតម្រូវរួមមាន ៖

១. ពាក្យស្នើសុំ

២. សម្រង់ព័ត៌មាន ឬ រូបភាពនៃគំរូឧបករណ៍មាត្រាសាស្ត្រដែលត្រូវនាំចូល

៣. បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រដែលត្រូវនាំចូល។

**ប្រការ៧.**_

លក្ខខណ្ឌនៃឧបករណ៍មាត្រាសាស្ត្រ ដែលត្រូវអនុញ្ញាតឱ្យនាំចូលគឺ ៖

- មានភាពត្រឹមត្រូវ និងសមមូល ឬស្របទៅតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ
- មានការបង្ហាញសមត្ថភាព អប្បបរមា និងអតិបរមា អំពីទម្ងន់ និង/ឬ រង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រនោះ និង/ឬ ពាណិជ្ជនាម ឬ អាសយដ្ឋានផលិត។

**ប្រការ៨.-**

ក្រោយពីមន្ត្រីមានសមត្ថកិច្ចនៃនាយកដ្ឋានទទួលបន្ទុក បានពិនិត្យវាយតម្លៃលើពាក្យស្នើសុំតាមបែបបទ និងនីតិវិធីដូចមានចែងក្នុងប្រការ៦នៃប្រកាសនេះរួចរាល់ហើយ ក្រសួងត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួន ទៅអ្នកស្នើសុំក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃយ៉ាងយូរនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលទទួលបានពាក្យស្នើសុំ។

ក្នុងករណីមិនយល់ព្រមតាមការស្នើសុំ ក្រសួងត្រូវឆ្លើយតបទៅអ្នកស្នើសុំ ដោយបញ្ជាក់ពីមូលហេតុឱ្យបានត្រឹមត្រូវ។

លិខិតអនុញ្ញាតនេះមានសុពលភាព ៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខា។

**ប្រការ៩.-**

រាល់ការផ្ទេរ ការលក់នូវលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ត្រូវមានការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ក្នុងករណីមានការពន្យារពេលនាំចូល អ្នកនាំចូលត្រូវធ្វើលិខិតស្នើសុំបន្តសុពលភាពជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបាន ៣០ (សាមសិប)ថ្ងៃ មុនថ្ងៃផុតសុពលភាពនៃលិខិតអនុញ្ញាតនេះ។

**ប្រការ១០.-**

នៅពេលឧបករណ៍មាត្រាសាស្ត្រ បាននាំចូលមកដល់កម្ពុជា (ទីកន្លែងស្តុក) អ្នកនាំចូលត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកក្រសួង ដើម្បីស្នើសុំមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យអង្កេតជាក់ស្តែង។

**ប្រការ១១.-**

ប្រកាសលេខ ១៤១ ឧវថ.មមជ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពី នីតិវិធី និងបែបបទនៃការស្នើសុំលិខិតអនុញ្ញាតការនាំចូលឧបករណ៍មាត្រាសាស្ត្រ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ គ្រប់អង្គភាពក្រោមឱវាទក្រសួង និងរូបវន្តបុគ្គល នីតិបុគ្គលដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

« *ដើម្បីជូនជ្រាប* »

- ដូចប្រការ១២

« *ដើម្បីអនុវត្ត* »

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៥៣១ ឧ.ក.ប.ក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងឧបករណ៍មាត្រាសាស្ត្រ ផ្នែកចំណុះ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

~~-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤~~
ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញ ប្រកាសលេខ ១៩៤ បល.ប្រក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានមាត្រាសាស្ត្រ

-ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## សម្រេច

**ប្រការ១ :** ឧបករណ៍មាត្រាសាស្ត្រផ្នែកចំណុះនៃវត្ថុរាវ ត្រូវបានកំណត់តាមចំណុះជា ១លីត្រ ៥លីត្រ ១០លីត្រ ២០លីត្រ និងចំណុះពហុគុណ-អនុពហុគុណនៃឧបករណ៍មាត្រាសាស្ត្រផ្នែកចំណុះនៃវត្ថុរាវដទៃទៀត ។

**ប្រការ៥ :** ,ការធ្វើព្យាសកម្មខ្នាតមាត្រាសាស្ត្រផ្នែកចំណុះនៃវត្ថុរាវ ត្រូវអនុវត្តតាមលក្ខខណ្ឌ ដូចតទៅ÷

<u>ក-ការធ្វើព្យាសកម្ម</u>

-សីតុណ្ហភាពជាគោល សំរាប់ធ្វើព្យាសកម្ម ចំពោះឧបករណ៍ខ្នាតមាត្រាសាស្ត្រផ្នែកចំណុះនៃវត្ថុរាវ គឺ ២០ អង្សាសែលស៊ីស ។

-ការក្រិតចំណុះ ត្រូវអនុវត្តតាមការចាក់ចូលឬការចាក់ចេញនៃវិធីវាល់ចំណុះ ឬតាមវិធីថ្លឹង ។

-ការកំណត់ចំណុះនៃការព្យាសកម្ម ឧបករណ៍ខ្នាតមាត្រាសាស្ត្រ ផ្នែកចំណុះនៃវត្ថុរាវត្រូវប្រើរយៈពេល ៣០ វិនាទី សំរាប់បង្ហូរបង្ហើយចុងក្រោយនៃវត្ថុរាវ ។

<u>ខ-កំរិតលំអៀង</u>

-កំរិតលំអៀងសំរាប់ឧបករណ៍ខ្នាតមាត្រាសាស្ត្រផ្នែកចំណុះនៃវត្ថុរាវ មិនអោយលើស ±0,1 % នៃបរិមាណកំណត់ ។ ចំពោះការត្រួតពិនិត្យបំរើការក្នុងសកម្មភាពសេវាកម្ម កំរិតលំអៀងដែលអនុញ្ញាតក្នុងចន្លោះ ±0,5 % នៃបរិមាណកំណត់ ។

**ប្រការ៦ :** អង្គភាពសមត្ថកិច្ចមាត្រាសាស្ត្រ គ្រប់អង្គភាពពាក់ព័ន្ធ គ្រប់សមាសភាពសេដ្ឋកិច្ច ផលិតកម្ម-អាជីវកម្មមានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួន តាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

<u>ចម្លងជូន:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង-ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

" <u>ដើម្បីជ្រាបជាពត៌មាន</u> "

-ដូចប្រការ៦

" <u>ដើម្បីមុខការនិងអនុវត្ត</u> "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

**linistry of Industry, Mines and Energy**

លេខ: ៧១០ ឧ.ក.ម.ជ.ប្រក.

# ប្រកាស

## ស្តីពី

## ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាម៉ពល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សេចក្តីជូនដំណឹងលេខ ១៣២៤ ឧវថ.ម.ម.ជ.សជណ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការអនុវត្តន៍ច្បាប់មាត្រាសាស្ត្រកម្ពុជា
- យោងតម្រូវការការងារចាំបាច់ផ្នែកមាត្រាសាស្ត្រ ។

## សម្រេច

**ប្រការ១ :** បង្កើតពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា សម្រាប់បញ្ជាក់ពីភាពត្រឹមត្រូវក្នុងការប្រើប្រាស់ និងទទួលសេវាគ្រប់គ្រងពី ម.ម.ជ ស្របតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។ ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា មានទំហំ ខ្នាតជាច្រើន ត្រូវបានរៀងរចនា សម្រាប់បិទភ្ជាប់ ឬ បោះពុម្ព ដោយអនុលោមទៅតាមទំហំ ប្រភេទឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងវេចខ្ចប់ ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

**ប្រការ២:** ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាត្រូវបានកំណត់សម្គាល់ទំហំខ្នាតតូចឬធំបាន ដោយត្រូវសមាមាត្រទៅនឹងគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១និង បញ្ជាក់អត្ថន័យដូចតទៅ:

ពមក : ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាប្រើ (FONT LIMON S2)

**MTC : Metrology Trademark of Cambodia** ប្រើ **(FONT Times New Roman)**

**00X** : លេខកូដចុះបញ្ជីក្រុមហ៊ុន ឬប្រកាសបង្កើតរោងចក្រ សិប្បកម្ម ឬចុះបញ្ជីសិប្បកម្ម

**00M** : លេខរៀងចុះបញ្ជីពាណិជ្ជសញ្ញាមាត្រាសាស្ត្រ

**YY** : ថ្ងៃ ខែ ឆ្នាំ ចុះបញ្ជីពាណិជ្ជសញ្ញាមាត្រាសាស្ត្រ

ផ្ទៃពាណិជ្ជសញ្ញាមាត្រាសាស្ត្រ មានពណ៌ស រង្វង់ព័ទ្ធជុំវិញពណ៌ខៀវពីរជាន់ និងប្រអប់រាងចតុកោណកែង សម្រាប់សម្គាល់សញ្ញាចុះបញ្ជីដែលមានលំនាំអក្សរភាត់ **MTC: 00X/00M/YY** ។

MTC: 00X/00M/YY

**ប្រការ៣**: ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម ដែលផលិត នាំចូល ដំឡើង ប្រើប្រាស់ ជួសជុល ថែទាំ និងអាចលក់ ឬ ដាក់តាំងលក់បាននូវឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និង វេចខ្ចប់ ឬ អនុញ្ញាតឲ្យប្រើប្រាស់ កាន់កាប់ក្នុងសកម្មភាព ពាណិជ្ជកម្ម និង វិស័យផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវតែមកធ្វើការស្នើសុំវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ ដើម្បីទទួលបានសិទ្ធិស្នើសុំអាជ្ញាប័ណ្ណប្រើប្រាស់ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

**ប្រការ៤**: រាល់ប្រកាស ឬ សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥**: ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០១១

ឧបនាយករដ្ឋមន្ត្រី

ស៊ុយ សែម

<u>**ចម្លងជូន:**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន សេនាធិការ ក្រសួង ឧ.រ.ថ
- គ្រប់នាយកដ្ឋាន សេនាធិការ ក្រសួង ឧ.រ.ថ
  "ដើម្បីជូនជ្រាប"
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា




មាត្រដ្ឋាន: ១/១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**

លេខ : ៤១០ ឧរថ.មមជ.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ លើឧបករណ៍មាត្រាសាស្ត្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បកចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ៧៣៩ ឧរថ.មមជ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ស្តីពីសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- ពិនិត្យតម្រូវការការងារចាំបាច់ផ្នែកនីត្យានុកូលមាត្រាសាស្ត្រ

## សម្រេច

**ប្រការ១ :** រាល់ឧបករណ៍មាត្រាសាស្ត្រដែលនាំចូល កំពុងប្រើប្រាស់ ផលិត ផ្គុំ ឬ កែតម្រូវរួច ត្រូវដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ថាបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់ពីមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល និងមានភាពត្រឹមត្រូវតាមច្បាប់ ប្រកាស និង បទបញ្ញាបច្ចេកទេស ដើម្បីទប់ស្កាត់ការក្លែងបន្លំ ក្នុងសកម្មភាពពាណិជ្ជកម្មអាជីវកម្ម។

**ប្រការ២ :** ការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រមានពីរប្រភេទគឺ

ក.សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង ត្រូវដាក់នៅលើឧបករណ៍មាត្រាសាស្ត្រដែលទើបតែ នាំចូល ផលិត ជួសជុល ឬ កែតម្រូវរួច បញ្ជាក់ពីភាពត្រឹមត្រូវតាមប្រកាស និង បទបញ្ញាបច្ចេកទេស ដោយមន្ត្រីត្រួតពិនិត្យ របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ទៅតាមវិធីសាស្ត្រ និង នីតិវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ

ខ.សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ត្រូវដាក់នៅលើឧបករណ៍មាត្រាសាស្ត្រដែលកំពុងប្រើប្រាស់ ក្នុងសកម្មភាពពាណិជ្ជកម្ម ដែលពិនិត្យផ្ទៀងផ្ទាត់ឃើញមានភាពត្រឹមត្រូវតាមប្រកាស និង បទបញ្ញាបច្ចេកទេស ដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ទៅតាមវិធីសាស្ត្រ និង នីតិវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ យ៉ាងត្រឹមត្រូវ និងដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរួចហើយ ។

**ប្រការ៣ :** រាល់អ្នកនាំចូល អ្នកផលិត អ្នកជួសជុលឬកែតម្រូវ ឧបករណ៍មាត្រាសាស្ត្រត្រូវធ្វើការស្នើសុំដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងនិងបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

- ផ្ញើលិខិតស្នើសុំធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ មកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិយ៉ាងយូរ៣០ថ្ងៃក្រោយពីឧបករណ៍មាត្រា-សាស្ត្របាន នាំចូល ផលិត ជួសជុល ឬកែតម្រូវរួច
- ផ្តល់គំរូឧបករណ៍មាត្រាសាស្ត្រ ដែលត្រូវធ្វើការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង
- ភ្ជាប់ជាមួយនូវបញ្ជីឈ្មោះឧបករណ៍ដែលបញ្ជាក់អំពីចំនួនពិតប្រាកដ សមត្ថភាព ឬ អានុភាពឧបករណ៍មាត្រាសាស្ត្រដែលស្នើសុំធ្វើការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង
- ភ្ជាប់ជាមួយនូវឯកសារបច្ចេកទេសពាក់ព័ន្ធនឹងឧបករណ៍មាត្រាសាស្ត្រដែលស្នើសុំធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង (វិញ្ញាបនបត្រអនុម័តគំរូ)
- បង់កម្រៃសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង
- បង្កលក្ខណៈសមស្របដើម្បីឲ្យមន្ត្រីត្រួតពិនិត្យមានលទ្ធភាពធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជូន។

**ប្រការ៤ :** រាល់ការស្នើសុំដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមៈ

- ត្រូវស្នើសុំធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិឲ្យបានមុន ៣០ថ្ងៃ នៃថ្ងៃផុតសុពលភាពដែលបានកំណត់នៅក្នុង វិញ្ញាបនបត្រត្រួតពិនិត្យផ្ទៀងផ្ទាត់

- បង់កម្រៃសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់
- បង្កលក្ខណៈសមស្របដើម្បីឲ្យមន្ត្រីត្រួតពិនិត្យមានលទ្ធភាពធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជូន។

**ប្រការ៥ :** ការផ្តល់ជូននូវការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ គឺធ្វើឡើងក្រោយពេលពិនិត្យឃើញថា ឧបករណ៍មាត្រាសាស្ត្រនោះមានលក្ខណៈត្រឹមត្រូវតាមប្រកាស បទបញ្ញាបច្ចេកទេស និងគំរូអនុម័តដែលបានកំណត់។

**ប្រការ៦ :** ក្នុងករណីដែលរូបវន្តបុគ្គល ឬ នីតិបុគ្គលមានបំណងក្នុងការផ្លាស់ប្តូរ ឬ កែតម្រូវលើឧបករណ៍មាត្រាសាស្ត្រណាមួយដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់រួចហើយត្រូវជូនដំណឹងទៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិជាមុន។

**ប្រការ៧ :** រាល់ការធ្វើពាណិជ្ជកម្មឬសេវាកម្មទាំងអស់ដែលប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រទោះ ជាតាមមធ្យោបាយណាក៏ដោយអាចអនុញ្ញាតទៅបានលុះត្រាតែ ឧបករណ៍មាត្រាសាស្ត្រទាំងនោះមានដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងនិង សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ដែលធ្វើឡើងដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ប្រការ៨ :** ជនណាដែលក្លែងបន្លំ ឬ ផ្លាស់ប្តូរលើការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រសម្រាប់ប្រើប្រាស់ ជាផលប្រយោជន៍ផ្ទាល់ខ្លួន ឬអង្គភាពរបស់ខ្លួន នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៩ :** រាល់ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១០:** ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានី ភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១១

រដ្ឋមន្ត្រី

ស៊ុយ សែម

<u>កន្លែងទទួល ៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់អគ្គនាយកដ្ឋាន-នាយកដ្ឋានក្រោមឱវាទក្រសួង ឧរថ
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ: ០៧៣ ឧរ៉ថ.ឋបស.ប្រក

# ប្រកាស

## ស្តីពី

## សមមូលនៃប្រព័ន្ធឯកតាទម្ងន់ ផ្នែកលោហធាតុមានតម្លៃ

## រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី មាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៨៥៨ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- ពិនិត្យតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-** ប្រកាសនេះមានគោលដៅកំណត់យន្តការ និងវិធានគ្រប់គ្រងលើការប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា និងការប្រើប្រាស់ប្រព័ន្ធជាតិ ក្រៅពីប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ចំពោះលោហធាតុមានតម្លៃ ។

**ប្រការ ២.-** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលធ្វើពាណិជ្ជកម្ម អាជីវកម្ម ឧស្សាហកម្ម ពាក់ព័ន្ធនឹងលោហធាតុមានតម្លៃ (មាស ប្រាក់ ប្លាទីន ។ល។) ត្រូវតែគោរព និងប្រើប្រាស់ប្រព័ន្ធឯកតាមាត្រាសាស្ត្រ



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax : 855-23-428263

ជាតិស្របច្បាប់ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃច្បាប់ ស្តីពី មាត្រាសាស្ត្រកម្ពុជា ។

ករណី រូបវន្តបុគ្គល ឬ នីតិបុគ្គលមានបំណងប្រើប្រាស់ប្រព័ន្ធឯកតាទម្ងន់ ផ្នែកលោហធាតុមានតម្លៃ ក្រៅពីប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ត្រូវស្នើសុំលិខិតអនុញ្ញាតពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ប្រការ ៣.-** សមមូលលើឯកតាទម្ងន់ ផ្នែកលោហធាតុមានតម្លៃ មានដូចខាងក្រោមនេះ៖

| ល.រ | រាយនាមប្រព័ន្ធឯកតា | តម្លៃសមមូល |
|---|---|---|
| ១. | លី | ០,០៣៧៥ g (ក្រាម) |
| ២. | ហ៊ុន | ០,៣៧៥ g (ក្រាម) |
| ៣. | ជី | ៣,៧៥ g (ក្រាម) |
| ៤. | ដំឡឹង | ៣៧,៥ g (ក្រាម) |

**ប្រការ ៤.-** អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋាននីតិកម្ម មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ ៥.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រី**

**ស៊ុយ សែម**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ធនាគារជាតិនៃកម្ពុជា
- គ្រប់ក្រសួង - ស្ថាប័នជំនាញពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់សាលារាជធានី - ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋានសេនាធិការ និងថ្នាក់ស្មើ នៃក្រសួងឧរថ
- គ្រប់សហគ្រាសសាធារណៈចំណុះក្រសួងឧរថ
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី - ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១៣៥៤ ឧ.រ.ថ.ម.ម.ជ.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធី និងបែបបទនៃការស្នើសុំអាជ្ញាប័ណ្ណ ផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បកចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៧៣៩ ឧរថ.មមជ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ ស្តីពីសញ្ញាមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៨៦១ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
- បានឃើញប្រកាសលេខ ៨៥៩ឧរថ.ម.ម.ជ.ប្រក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ


៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៨៦៨០៦៣

- បានឃើញប្រកាសលេខ ៨៦០ ឧរថ.ម.ម.ជ.ប្រក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១១ ស្ដីពីនីតិវិធីនៃការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រ
- បានឃើញសេចក្ដីជូនដំណឹងលេខ ១៣២៤ឧរថ.ម.ម.ជ.សជណ ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១១ ស្ដីពីការអនុវត្តច្បាប់មាត្រាសាស្ត្រកម្ពុជា
- ពិនិត្យតាមតម្រូវការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១** ; ប្រកាសនេះ មានគោលដៅកំណត់យន្តការ និង វិធានគ្រប់គ្រងការផលិត និង ជួសជុលឧបករណ៍មាត្រាសាស្ត្រក្នុងព្រះរាជាណាចក្រកម្ពុជា និង ក្នុងគោលបំណង:

- ធានាឲ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌និងត្រឹមត្រូវ
- បង្កឲ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ មានភាពត្រឹមត្រូវសុចរិត
- ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និង អ្នកប្រើប្រាស់ ផលិតផលទំនិញ និង សេវាកម្ម
- ធានាធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពទំនិញ ផលិតផល សេវាកម្ម និង គ្រប់គ្រង
- កំណត់អត្តសញ្ញាណ និង លុបបំបាត់របាំងបច្ចេកទេស ដើម្បីឲ្យមានសុខដុមនីយកម្ម ក្នុងសកម្មភាពពាណិជ្ជកម្ម លើវិស័យនីត្យានុកូលមាត្រាសាស្ត្រ
- ធ្វើឲ្យមានជំនឿ និង ទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាពពាណិជ្ជកម្ម និង វិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និង បរិស្ថាន
- សម្រួលការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ បច្ចេកទេសដើម្បីភាពរីកចម្រើននៃសេដ្ឋកិច្ច។

**ប្រការ ២** : វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងប្រកាសនេះ :

**មាត្រាសាស្ត្រ** សំដៅដល់ វិទ្យាសាស្ត្រ និង ការគ្រប់គ្រងទម្ងន់និងរង្វាស់រង្វាល់។

**នាយកដ្ឋានទទួលបន្ទុក** សំដៅដល់ នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ។

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ទម្ងន់ និង រង្វាស់រង្វាល់ដែលបំរើឲ្យវិស័យមាត្រាសាស្ត្រ។

**បរិក្ខារ** សំដៅដល់ សម្ភារៈសម្រាប់ថ្លឹង ឬវាស់វាល់ ឬគ្រឿងផ្សំសម្រាប់ឧបករណ៍មាត្រាសាស្ត្រ។

**ឧបករណ៍វាស់វាល់** សំដៅដល់ ឧបករណ៍មាត្រាសាស្ត្រសម្រាប់ប្រើប្រាស់រកបរិមាណនៃប្រព័ន្ធឯកតាចំណុះវត្ថុរាវ ប្រវែង សម្ពាធ សំឡេង ពន្លឺ ថាមពល។ល។

**បុគ្គល** សំដៅដល់ នីតិបុគ្គល ឬ រូបវន្តបុគ្គល។

**មន្ត្រីត្រួតពិនិត្យ** សំដៅដល់មន្ត្រីមានសមត្ថកិច្ចរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

**ការផលិត** សំដៅដល់ ការកែច្នៃវត្ថុធាតុដើមឲ្យទៅជាផលិតផលសម្រេចដោយប្រើប្រាស់បច្ចេកវិជ្ជានៅក្នុងរោងចក្រ ឬ សិប្បកម្ម។

**ការជួសជុល** សំដៅដល់ ការធ្វើឲ្យដូចដើមវិញនូវឧបករណ៍មាត្រាសាស្ត្រដែលមានខូចខាតទ្រង់ទ្រាយដើម មិនដំណើរការឬ ធ្វើឲ្យថ្មីនូវឧបករណ៍ចាស់។

**ពាក្យស្នើសុំ** សំដៅដល់ ពាក្យស្នើសុំអាជ្ញាប័ណ្ណផលិត ឬ ជួសជុល ដែលជាសំណើផ្លូវការជាលាយលក្ខណ៍អក្សរបញ្ជូនមកនាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដោយផ្ទាល់ ឬ តាមរយៈសាខាមជ្ឈមណ្ឌលមាត្រាសាស្ត្រ (ម.ម.ជ) រាជធានី-ខេត្ត។ ពាក្យស្នើសុំរួមមាន ឯកសារតម្រូវទាំងអស់ដែលមានចែងសម្រាប់ប្រភេទនៃប្រកាសអាជ្ញាប័ណ្ណផលិត និង ជួសជុល ឧបករណ៍មាត្រាសាស្ត្រ។

**អាជ្ញាប័ណ្ណ** សំដៅដល់ អាជ្ញាប័ណ្ណផលិត ឬ អាជ្ញាប័ណ្ណជួសជុល។

**អាជ្ញាប័ណ្ណផលិត** សំដៅដល់ ការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិថា ម្ចាស់រោងចក្រសិប្បកម្មបានទទួលសិទ្ធិស្របច្បាប់ក្នុងកិច្ចដំណើរកាផលិតឧបករណ៍មាត្រា-សាស្ត្រ។

**អាជ្ញាប័ណ្ណជួសជុល** សំដៅដល់ ការទទួលស្គាល់ជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិថា ម្ចាស់រោងចក្រ សិប្បកម្មបានទទួលសិទ្ធិស្របច្បាប់ក្នុងដំណើរកាជួសជុលឧបករណ៍មាត្រា-សាស្ត្រ។

**ឯកសារតម្រូវ** សំដៅដល់ ឯកសារតម្រូវឲ្យមានភាពអនុលោមដែលកំណត់ដោយ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដើម្បីទទួលបានការអនុញ្ញាតណាមួយយោងតាមប្រកាសនេះ។

**អនុម័តគំរូ** សំដៅដល់ការអនុម័តលើគំរូជាក់លាក់ណាមួយនៃឧបករណ៍មាត្រាសាស្ត្រសម្រាប់ដាក់ឲ្យប្រើប្រាស់ បន្ទាប់ពីបានសាកល្បងឧបករណ៍មួយ ឬ ច្រើនស្របតាមការតម្រូវដែលបានកំណត់។

**គំនូសបច្ចេកទេស** សំដៅដល់ គំនូសបង្ហាញនៃឧបករណ៍មាត្រាសាស្ត្រជាបីគំហើញ បញ្ឈរ ផ្តេក និងពុះចំពីលើដោយមានបញ្ជាក់ពីទំហំ រូបរាង ខ្នាតរបស់ឧបករណ៍មាត្រាសាស្ត្រដែលស្នើសុំផលិត ឬ ជួសជុលទៅតាមបច្ចេកទេសដែលបានកំណត់ហើយគំនូសនេះត្រូវគូស និង បញ្ជាក់ដោយអ្នកបច្ចេកទេសដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ ពិសេសពាក់ព័ន្ធនឹងជំនាញមេកានិច។

**គំរូឧបករណ៍** សំដៅដល់ សំណាកគំរូឧបករណ៍មាត្រាសាស្ត្រ ដែលមានរូបរាង ទ្រង់ទ្រាយ ទំហំ ខ្នាត និងយកមកតំកល់ទុកជាគំរូក្រោយការផលិត។

**ប្រកាសអនុញ្ញាតបង្កើតរោងចក្រនិងសិប្បកម្ម** សំដៅដល់ ការអនុញ្ញាតជាលាយលក្ខណ៍អក្សរមានសុពលភាពអចិន្ត្រៃយ៍ដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់បង្កើតរោងចក្រថ្មី ឬ សិប្បកម្មថ្មី ដែលតម្រូវឲ្យសុំច្បាប់រួមទាំងលក្ខខណ្ឌលម្អិតនានា ដែលចែងក្នុងប្រកាសអនុញ្ញាតនោះ។ ក្នុងករណីរោងចក្រ សិប្បកម្ម ផលិត និង/ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រ ក្រោយពេលបញ្ចប់ការសាងសង់រួចរាល់រោងចក្រ សិប្បកម្មត្រូវមានអាជ្ញាប័ណ្ណផលិត និង/ឬ ជួសជុល មួយទៀត មុននឹងចាប់ផ្តើមប្រតិបត្តិការដំបូង។

**វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ** សំដៅដល់ ការចុះឈ្មោះក្រុមហ៊ុនរោងចក្រ សហគ្រាស សិប្បកម្ម អង្គភាពផ្សេងៗ ក្នុងបញ្ជីមាត្រាសាស្ត្រជាលាយលក្ខណ៍អក្សរដោយមជ្ឈមណ្ឌលមាត្រា-សាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានសុពលភាព ៣ (បី) ឆ្នាំ សម្រាប់យកទៅ

ប្រើប្រាស់ ទៅតាមច្បាប់ដែលអាចប្រើបាននិងបញ្ជាក់ថាអង្គភាពសេដ្ឋកិច្ចខាងលើនេះបានធ្វើពាណិជ្ជកម្ម អាជីវកម្ម ឬ សេវាកម្មពាក់ព័ន្ធនឹងផ្នែកមាត្រាសាស្ត្រ។

**អ្នកស្នើសុំ** សំដៅដល់ បុគ្គលដែលចុះហត្ថលេខាលើលិខិតស្នើសុំអនុលោមតាមប្រកាសនេះ។ អ្នកស្នើសុំទាំងអស់មានសេរីភាពក្នុងការជួលភ្នាក់ងារជាភាគីទីបីតាមជម្រើសរបស់ខ្លួនដើម្បីដាក់និងដំណើរការដាក់ពាក្យស្នើសុំ។

**ប្រការ ៣ :** រាល់ការស្នើសុំអាជ្ញាប័ណ្ណផលិតឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទតាមទម្រង់កំណត់ដោយ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ រាល់ការស្នើសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

ក.ពាក្យស្នើសុំ

ខ.ប្រកាសអនុញ្ញាតបង្កើតរោងចក្រ សិប្បកម្ម ឬ ចុះបញ្ជីសិប្បកម្ម

គ.វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ

ឃ.បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រដែលនឹងត្រូវធ្វើការស្នើសុំផលិត

ង.វិញ្ញាបនបត្រអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រដែលត្រូវផលិត

ច.របាយការណ៍វាយតម្លៃរបស់មន្ត្រីបច្ចេកទេស មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដល់ទីកន្លែងរោងចក្រ/សិប្បកម្ម

(អ្នកស្នើសុំត្រូវជូនដំណឹងដល់មន្ត្រីបច្ចេកទេស មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ចុះពិនិត្យអង្កេតស្ថានភាព ទីកន្លែង ផលិត ក្រោយពីបំពេញបែបបទខាងលើរួច)។

**ប្រការ ៤ :** រាល់ការស្នើសុំអាជ្ញាប័ណ្ណជួសជុលឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទតាមទម្រង់កំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។ រាល់ការស្នើសុំត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម:

ក.ពាក្យស្នើសុំ

ខ.ប្រកាសអនុញ្ញាតបង្កើតរោងចក្រ/សិប្បកម្មឬចុះបញ្ជីសិប្បកម្ម(បើមាន)

គ.វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ

ឃ.បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រដែលត្រូវស្នើសុំជួសជុល

ង.របាយការណ៍វាយតម្លៃរបស់មន្ត្រីបច្ចេកទេស មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដល់ទីកន្លែងរោងចក្រ សិប្បកម្ម

(អ្នកស្នើសុំត្រូវជូនដំណឹងដល់មន្ត្រីបច្ចេកទេសមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ចុះពិនិត្យអង្កេតស្ថានភាព ទីកន្លែង ជួសជុលក្រោយពីបំពេញបែបបទខាងលើរួច)។

**ប្រការ ៥ :** អ្នកស្នើសុំត្រូវបំពេញពាក្យស្នើសុំអាជ្ញាប័ណ្ណផលិត និង/ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រដែលអាចទំនាក់ទំនងរកបានដូចខាងក្រោម:

ក. នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ(ម.ម.ជ) នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ខ. នៅសាខា ម.ម.ជ នៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត។

គ.តាមរយៈ វិបសាយ (Website):www.nmc.mime.gov.kh ឬ

អ៊ីមែល(E-mail): dlegalm.nmc@gmail.com

**ប្រការ ៦** : ក្រោយពីបានទទួលពាក្យស្នើសុំស្របតាម ប្រការ៣ និង/ឬ ប្រការ៤ ប្រសិនបើពិនិត្យឃើញថា បានបំពេញតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និង បាន អនុវត្តទៅតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា នោះមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិត្រូវឆ្លើយតបដល់ អ្នកស្នើសុំក្នុងរយៈពេល ៩ (ប្រាំបួន) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរដោយគិតចាប់ពីថ្ងៃបានទទួល ពាក្យស្នើសុំ ។

អាជ្ញាប័ណ្ណដែលផ្តល់ឲ្យដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានវិសាលភាពដូចមាន ចែងក្នុងជំពូកទី៩ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងគោរពតាមលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធ ។

**ប្រការ ៧** : អាជ្ញាប័ណ្ណ

ក. ផ្តល់ឲ្យចំពោះអ្នកផលិត ឬ អ្នកជួសជុលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការ កំណត់នៃលក្ខខណ្ឌតម្រូវ

ខ. មានសុពលភាពក្នុងរយៈពេល ៣(បី) ឆ្នាំ សម្រាប់អាជ្ញាប័ណ្ណផលិត ឬ ជួសជុល

គ. ផុតសុពលភាពនៅពេលអ្នកផលិត ឬ អ្នកជួសជុលមានការផ្លាស់ប្តូរបទដ្ឋានបច្ចេកទេស ទីកន្លែង និង ពង្រីកបន្ថែមទៅលើមុខផលិតផល

ឃ. អាចត្រូវបានផ្តល់ឲ្យសារជាថ្មី ដោយអ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើសំណើទៅមជ្ឈមណ្ឌល មាត្រាសាស្ត្រជាតិឲ្យបាន ៣០ (សាមសិប)ថ្ងៃ មុនថ្ងៃផុតកំណត់សុពលភាពរបស់ អាជ្ញាប័ណ្ណ

ង. មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អាចផ្តល់អាជ្ញាប័ណ្ណលើកទី២ (ទុតិយតា) ឲ្យអ្នកកាន់ អាជ្ញាប័ណ្ណ នៅពេលដែលបានបង្ហាញហេតុផលសមរម្យថាអាជ្ញាប័ណ្ណត្រូវបានខូច រហែក ឬ បាត់បង់។

**ប្រការ ៨** : ឧបករណ៍មាត្រាសាស្ត្រដែលផលិតបាន ជួសជុល ឬ កែតម្រូវរួចទាំងអស់ ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និង ត្រូវមានដាក់សញ្ញា ត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងជាការកំណត់មុននឹងលក់ ចែកចាយ ឬដាក់តាំងសម្រាប់លក់ និងកាន់កាប់ សម្រាប់ប្រើប្រាស់ធ្វើពាណិជ្ជកម្ម អាជីវកម្ម ឬ សេវាកម្ម។

**ប្រការ៩** : អ្នកកាន់អាជ្ញាប័ណ្ណ:

ក. ត្រូវធានាថា ឧបករណ៍មាត្រាសាស្ត្រដែលផលិត ឬជួសជុល បានអនុលោមតាមច្បាប់ លិខិតបទដ្ឋាន គតិយុត្តនានា

ខ. ត្រូវបង្កើត រៀបចំប្រព័ន្ធធានាសុក្រិតភាពនៃផលិតផល

គ. មិនត្រូវផ្ទេរការដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងលើឧបករណ៍មាត្រាសាស្ត្រពីមួយ ទៅមួយផ្សេងទៀតឡើយ

ឃ. ត្រូវដាក់ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាលើឧបករណ៍មាត្រាសាស្ត្រជាការកំណត់មុននឹង ដាក់តាំងលក់ ឬ កាន់កាប់ ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម

ង. ត្រូវបង្កលក្ខណៈងាយស្រួល ដល់ការបំពេញភារកិច្ចរបស់មន្ត្រីមានសមត្ថកិច្ចមជ្ឈមណ្ឌល

មាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។

**ប្រការ ១០ :** អាជ្ញាប័ណ្ណ អាចត្រូវបានព្យួរទុកក្នុងរយៈ ពេលមួយ មិនលើសពីបីខែក្នុងមួយលើកប្រសិនបើៈ

ក. មិនបានប្រតិបត្តិតាមប្រការ ៨ នៃប្រកាសនេះ

ខ. ប្រើប្រាស់អាជ្ញាប័ណ្ណ ឬ អនុវត្តមិនបានត្រឹមត្រូវហើយមិនបានចាត់វិធានការដោះស្រាយ ឬ កែតម្រូវឲ្យទាន់ពេលវេលា តាមការកំណត់របស់មន្ត្រីត្រួតពិនិត្យ ឬមន្ត្រីមានសមត្ថកិច្ចរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

គ. រំលោភទៅនឹងបទប្បញ្ញត្តិណាមួយនៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ប្រកាស ឬបទបញ្ជាបច្ចេកទេសពាក់ព័ន្ធ ។

**ប្រការ ១១ :** អាជ្ញាប័ណ្ណ អាចត្រូវបានដកហូតនៅពេលដែលបានរកឃើញថា អ្នកកាន់អាជ្ញាប័ណ្ណៈ

ក. មិនបានប្រតិបត្តិទៅតាមប្រការ ៩ នៃប្រកាសនេះ

ខ.បានប្រព្រឹត្តកំហុសដូចគ្នាទៅនឹងកំហុសដែលនាំឲ្យមានការព្យួរទុកលើកមុន។

**ប្រការ ១២ :** នៅពេលអាជ្ញាប័ណ្ណត្រូវបានព្យួរទុក ឬដកហូត អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថាឧបករណ៍មាត្រាសាស្ត្រនោះមានអាជ្ញាប័ណ្ណទេ ហើយត្រូវតែផ្អាកភ្លាមនូវសកម្មភាពផលិត ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រនោះ។

**ប្រការ ១៣ :** ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណមិនបានអនុវត្តតាមប្រការ ១២ ខាងលើ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មានសិទ្ធិលុបចោលអាជ្ញាប័ណ្ណជាស្វ័យប្រវត្តិ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ចដើម្បីរឹបអូសឧបករណ៍មាត្រាសាស្ត្រដែលបានផលិត ឬ ជួសជុល ក្នុងរយៈពេលព្យួរទុក ឬ ដកហូត ទុកជាសម្បត្តិរដ្ឋ។

**ប្រការ ១៤ :** នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណ មានបំណងឈប់ដំណើរការផលិត និង ជួសជុល ហើយជាមួយគ្នានោះដែរ មានបំណងបោះបង់ចោលអាជ្ញាប័ណ្ណរបស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណមិនបានជូនដំណឹងមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិទេនោះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលទោសតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ គ្មានការសងវិញ ទាំងស្រុង ឬចំណែកណាមួយ នៃកម្រៃអាជ្ញាប័ណ្ណដែលបានបង់នោះឡើយ ។ ការបោះបង់ចោល អាជ្ញាប័ណ្ណត្រូវចាត់ទុកថាជាការបញ្ឈប់ដំណើរសេវាកម្មលើការផលិត ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រ ចាប់ពីថ្ងៃចុងក្រោយបង្អស់នៃខែដែលបានទទួលសេចក្តីសម្រេចជាផ្លូវការរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

**ប្រការ ១៥ :** ក្នុងករណីមានការកំណត់គំរូថ្មីមួយ ឬមានការកែប្រែគំរូនៃការចេញអាជ្ញាប័ណ្ណ អ្នកកាន់អាជ្ញាប័ណ្ណដែលមានបំណងអនុវត្តតាមគំរូថ្មី ឬគំរូដែលមានការកែប្រែនោះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណគំរូថ្មី ។ បន្ទាប់ពីបានដាក់ពាក្យស្នើសុំរួច អ្នកកាន់អាជ្ញាប័ណ្ណអាចបន្តដំណើរការរបស់ខ្លួននៅក្រោមអាជ្ញាប័ណ្ណ និងគំរូចាស់ក្នុងរយៈពេលមួយដែលបានកំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មិនលើសពីមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃគំរូថ្មី ។

**ប្រការ ១៦** : ការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាប័ណ្ណផលិត និង ផ្គុំសផុលឧបករណ៍មាត្រាសាស្ត្រ អ្នកកាន់កាប់អាជ្ញាប័ណ្ណ និង អ្នកទទួលសិទ្ធិកាន់កាប់បន្តត្រូវមកទំនាក់ទំនងធ្វើការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាប័ណ្ណនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ អ្នកទទួលសិទ្ធិថ្មីត្រូវដំណើរការផលិត ឬ ផ្គុំសផុលឧបករណ៍មាត្រាសាស្ត្រ ដោយគោរពតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងអាជ្ញាប័ណ្ណ និងកិច្ចព្រមព្រៀងដែលនៅមានសុពលភាពជាធរមាន។

**ប្រការ ១៧** : ការព្រមាន និង ពិន័យអន្តរការណ៍ដែលមានចែងក្នុងប្រកាសនេះត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិត្រូវបញ្ជូនសំណុំរឿងទៅតុលាការ។

**ប្រការ ១៨** : រាល់ប្រកាស និង សេចក្តីសម្រេចទាំងឡាយណា ដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៩** : អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាននីតិកម្ម ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ និង ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ។

**ប្រការ២០** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី...១៨...ខែ...កុម្ភៈ...ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

ស៊ុយ សែម

*កន្លែងទទួល :*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង ឧរថ
- គ្រប់សហគ្រាសសាធារណៈចំណុះក្រសួងឧរថ
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
- ដូចប្រការ១៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ១៤០ ឧ.រ.ថ.ព.ស.ម.ព.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធី និងបែបបទនៃការអនុម័តគំរូ ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៨០៩/ ០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ. បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញប្រកាសលេខ ៨៦២ ឧរថ. បល. ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានមន្ទីរពិសោធន៍មាត្រាសាស្ត្រ
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣២៤ ឧរថ ម.ម.ជ សជណ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- ពិនិត្យតាមតម្រូវការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ១ :** នីតិវិធី និងបែបបទ នៃការអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ មានគោលបំណងកំណត់យន្តការ វិធានគ្រប់គ្រង និងតំលៃវាយតម្លៃលើគំរូ ជាក់លាក់រាល់ការផលិត ការនាំចូល ការដំឡើងឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់


៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ធានាចំពោះការក្លែងបន្លំ អត្តសញ្ញាណ ប្រភេទ ទម្រង់ រូបរាង ទំហំ ខ្នាត ក្នុងសកម្មភាព ឧស្សាហកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ស្របតាមច្បាប់ ដែលបានកំណត់ ។

**ប្រការ២ :** វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមានដូចតទៅ ៖

**មាត្រាសាស្ត្រ** សំដៅដល់ វិទ្យាសាស្ត្រ និងការគ្រប់គ្រងទម្ងន់ និងរង្វាស់រង្វាល់ ។

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ ដែលបម្រើឲ្យវិស័យមាត្រាសាស្ត្រ ។

**អ្នកនាំចូល** សំដៅដល់ បុគ្គលដែលបានអនុញ្ញាតឲ្យនាំចូល នូវឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ ។

**អ្នកផលិត** សំដៅដល់បុគ្គល ដែលផលិតឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និង សំបកវេចខ្ចប់ ។

**បុគ្គល** សំដៅដល់ នីតិបុគ្គល ឬរូបវន្តបុគ្គល ។

**ការដំឡើង** សំដៅដល់ ការផ្សំផ្គុំ នូវគ្រឿងម៉ាស៊ីនបរិក្ខារ ទៅតាមប្រព័ន្ធមេកានិច និង/ឬអេឡិចត្រូនិច ដើម្បីឲ្យឧបករណ៍មាត្រាសាស្ត្រ មានលក្ខណៈគ្រប់គ្រាន់សម្រាប់បំពេញតួនាទីរបស់វា ។

**បរិក្ខារ** សំដៅដល់ សម្ភារៈសម្រាប់ថ្លឹង ឬវាស់វាល់ ឬគ្រឿងផ្សំសម្រាប់ឧបករណ៍មាត្រាសាស្ត្រ។

**គំរូឧបករណ៍** សំដៅដល់ ផលិតផលសម្រេចឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ដែលមាន រូបរាង ទ្រង់ទ្រាយ ទំហំខ្នាតច្បាស់លាស់ ទៅតាមគំនូសបច្ចេកទេស សម្រាប់ត្រួតពិនិត្យ ធ្វើតេស្ត វិភាគ ក្នុងនីតិវិធីដំណើរការអនុម័ត និងតម្កល់ទុកជាគំរូ ។

**គំនូសបច្ចេកទេស** សំដៅដល់ គំនូសបង្ហាញ នៃឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ ជាបីគំហើញ បញ្ឈរ ផ្តេក និងពុះចំពីលើដោយមានបញ្ជាក់ពី រូបរាង ទំហំខ្នាតរបស់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ ទៅតាមគំរូ ដែលស្នើសុំអនុម័ត ហើយគំនូសនេះត្រូវគូស និងបញ្ជាក់ដោយអ្នកបច្ចេកទេស ដែលមានបរិញ្ញាបត្រ ឬសញ្ញាបត្រ ដែលមានតម្លៃស្មើ ពិសេសពាក់ព័ន្ធនឹងជំនាញមេកានិច ។

**សំបកវេចខ្ចប់** សំដៅដល់ វត្ថុសម្រាប់ផ្ទុក ច្រក វេច ផលិតផលសម្រេច ជាការធានានូវគុណភាព សុវត្ថិភាព សោភណភាព ក្នុងការដឹកជញ្ជូន ថែរក្សា លក់ ឬដាក់តាំង និងមានសរសេរពីអត្តសញ្ញាណ ការណែនាំ និងបញ្ជាក់ផ្សេងៗ ជាពិសេសបញ្ជាក់ នូវបរិមាណសុទ្ធ និងដាក់ប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ របស់ផលិតផលសម្រេចនោះ ។

**ទំនិញផលិត** សំដៅដល់ ផលិតផលទំនិញ ដែលមិនមានសំបកវេចខ្ចប់ និងអាចដឹកជញ្ជូនចរាចរលក់ ដោយគ្រាន់តែបញ្ជាក់បរិមាណសុទ្ធ និងប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ។

**ការអនុម័តគំរូ** សំដៅដល់ ការអនុម័តលើគំរូដាក់ណាមួយ នៃឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ សម្រាប់ដាក់ឲ្យប្រើប្រាស់ បន្ទាប់ពីបានសាកល្បងគំរូមួយ ឬច្រើនស្របតាមការតម្រូវដែលបានកំណត់ ។

**ពាក្យស្នើសុំអនុម័តគំរូ** សំដៅដល់ពាក្យស្នើសុំវិញ្ញាបនបត្រអនុម័តគំរូ ដែលជាសំណើផ្លូវការ

ជាលាយលក្ខណ៍អក្សរ បញ្ជូនមកនាយកដ្ឋានមន្ទីរពិសោធន៍មាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ។

**វិញ្ញាបនបត្រអនុម័តគំរូ** សំដៅដល់ លិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិដែលមានសុពលភាព៣ (បី)ឆ្នាំ លើការអនុម័តគំរូឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិតពុម្ព និងសំបកវេចខ្ចប់ ដូចមានទម្រង់កំណត់ដោយ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ** សំដៅដល់ ការចុះឈ្មោះក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម អង្គភាពផ្សេងៗក្នុងបញ្ជីមាត្រាសាស្ត្រជាលាយលក្ខណ៍អក្សរ ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានសុពលភាព៣(បី)ឆ្នាំ សម្រាប់យកទៅប្រើប្រាស់ទៅតាមច្បាប់ ដែលអាចប្រើបាន និងបញ្ជាក់ថាអង្គភាពសេដ្ឋកិច្ចខាងលើនេះបានធ្វើពាណិជ្ជកម្ម អាជីវកម្ម ឬសេវាកម្មពាក់ព័ន្ធនឹងមាត្រាសាស្ត្រ ។

**មន្ត្រីត្រួតពិនិត្យ** សំដៅដល់ មន្ត្រីដែលមានសមត្ថកិច្ច ដែលកំណត់ដោយច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ។

**ប្រការ៣ :** ការអនុម័តគំរូជាសមត្ថកិច្ច របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អនុលោមទៅតាមបទបញ្ជាបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រដែលមាននាយកដ្ឋានមន្ទីរពិសោធន៍មាត្រាសាស្ត្រជាសេនាធិការ ។

**ប្រការ៤ :** រាល់ការស្នើសុំការអនុម័តគំរូ ត្រូវដាក់សំណើនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដោយបំពេញពាក្យស្នើសុំអនុម័ត ដូចមានទម្រង់ពាក្យស្នើសុំ កំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិតាមលក្ខខណ្ឌដូចខាងក្រោម៖

- ពាក្យស្នើសុំអនុម័តគំរូ
- វិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រ(ច្បាប់ចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម)
- បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រ ឬទំនិញផលិត ឬពុម្ព ឬសំបកវេចខ្ចប់ ដែលខ្លួនមានបំណងផលិត ឬនាំចូល ឬ/និងកាន់កាប់ប្រើប្រាស់
- គំនូសបច្ចេកទេស និង/ឬគំរូឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិតពុម្ព និងសំបកវេចខ្ចប់។

**ប្រការ៥ :** ចាប់ពីបានទទួលពាក្យស្នើសុំ ស្របតាមប្រការ៤ខាងលើ ប្រសិនបើនាយកដ្ឋានមន្ទីរពិសោធន៍មាត្រាសាស្ត្រ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ បានធ្វើការពិនិត្យ ព្យាសកម្ម ធ្វើតេស្ត វិភាគ ឃើញលទ្ធផលពិតប្រាកដ ដែលសមស្របតាមលក្ខខណ្ឌ កំណត់រួចហើយ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នឹងផ្តល់វិញ្ញាបនបត្រអនុម័តគំរូ យ៉ាងយូរ ៩ (ប្រាំបួន)ថ្ងៃ ក្រោយពីលទ្ធផលព្យាសកម្ម តេស្ត វិភាគ វិជ្ជមាន ដល់អ្នកស្នើសុំ ដើម្បីអាចដំណើរការ អាជីវកម្ម ពាណិជ្ជកម្ម សេវាកម្មរបស់ខ្លួន ។

**ប្រការ៦ :** ឧបករណ៍មាត្រាសាស្ត្រទាំងអស់ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ សម្រាប់ប្រើប្រាស់ក្នុងវិស័យដូចខាងក្រោម ត្រូវអនុម័តគំរូរួមមាន៖

ក. ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ ដែលបានបញ្ញត្តសម្រាប់ប្រើប្រាស់ក្នុងវិស័យសុខភាពសាធារណៈ

ខ. ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ ដែលបានបញ្ញត្តសម្រាប់ប្រើប្រាស់ក្នុងវិស័យសេវាកម្មប្រៃសណីយ៍

គ. ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ ដែលបានបញ្ញត្តសម្រាប់ប្រើប្រាស់ក្នុងវិស័យអគ្គិសនី ឧស្ម័ន និងទឹក

ឃ. ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ដែលបានបញ្ញត្ត សម្រាប់ប្រើប្រាស់ ក្នុងវិស័យឧស្សាហកម្ម វិស្វកកម្ម ពាណិជ្ជកម្ម កសិកម្ម ទេសចរណ៍ ឬវិស័យផ្សេងទៀត។

**ប្រការ៧ :** សុពលភាព នៃវិញ្ញាបនបត្រអនុម័តគំរូ កំណត់ដោយអនុលោមទៅតាមបទបញ្ញាបច្ចេកទេស វត្ថុធាតុផ្សំ រូបរាង និងលិខិតណែនាំ ឬកំណត់បង្ហាញ បច្ចេកទេស ឧបករណ៍ និងបទដ្ឋានបច្ចេកទេសរបស់ឧបករណ៍ ។

**ប្រការ៨ :** ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់ ដែលបានអនុម័តកន្លងមកហើយ ប្រសិនបើពិនិត្យលើកក្រោយ ឃើញថាមានភាពមិនត្រឹមត្រូវ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានសិទ្ធិលុបការអនុម័តពីមុននោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ម្ចាស់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ពុម្ព និងសំបកវេចខ្ចប់នោះ ។ ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃបន្ទាប់ពីការជូនដំណឹង ម្ចាស់គំរូអនុម័តមានសិទ្ធិតវ៉ា ដើម្បីស្នើសុំពិនិត្យបញ្ជាក់។ ផុតកំណត់តវ៉ានេះ ការលុបការអនុម័តគំរូ ត្រូវចាត់ទុកជាបានការតាមផ្លូវច្បាប់ ។

**ប្រការ៩ :** ការផ្ទេរសិទ្ធិ ម្ចាស់គំរូអនុម័ត ត្រូវធ្វើនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ ម្ចាស់ថ្មី នៃគំរូអនុម័តត្រូវដំណើរការធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម លើគំរូអនុម័ត ដោយគោរពតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកំណត់បង្ហាញរបាយការណ៍បច្ចេកទេស និងវិញ្ញាបនបត្រ អនុម័តគំរូដែលនៅមានសុពលភាពជាធរមាន។

**ប្រការ១០ :** ការបន្តវិញ្ញាបនបត្រអនុម័តគំរូត្រូវបានកំណត់ដូចតទៅ ៖

- អ្នកកាន់វិញ្ញាបនបត្រអនុម័តគំរូ បានអនុវត្តត្រឹមត្រូវ តាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យមាត្រាសាស្ត្រ
- អ្នកស្នើសុំត្រូវមកទំនាក់ទំនងស្នើសុំបន្តឲ្យបាន ៣០ ( សាមសិប ) ថ្ងៃ មុនថ្ងៃផុតសុពលភាព
- វិញ្ញាបនបត្រអនុម័តគំរូ ត្រូវបានបន្តឲ្យមុន ៩ (ប្រាំបួន)ថ្ងៃ ក្រោយថ្ងៃទទួលពាក្យស្នើសុំបន្ត ។

**ប្រការ១១ :** នៅពេលដែលម្ចាស់គំរូអនុម័តមានបំណងឈប់ដំណើរការធ្វើសេវាកម្ម ពាណិជ្ជកម្ម អាជីវកម្ម លើគំរូអនុម័ត ឬមានបំណងបោះបង់ចោលវិញ្ញាបនបត្រអនុម័តគំរូរបស់ខ្លួន ម្ចាស់គំរូអនុម័ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ បញ្ជាក់អំពីមូលហេតុមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវចេញលិខិតលុបគំរូអនុម័ត រួចជូនដំណឹងដល់ម្ចាស់គំរូអនុម័ត។ក្នុងករណីដែលម្ចាស់គំរូអនុម័តមិនបានជូនដំណឹងមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិទេនោះ ម្ចាស់គំរូអនុម័ត ត្រូវទទួលទោសតាមច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា។ គ្មានការសងវិញ

ទាំងស្រុង ឬចំណែកណាមួយ នៃកម្រៃវិញ្ញាបនបត្រអនុម័តគំរូ ដែលបានបង់បោះនោះឡើយ។ ការបោះបង់ចោល វិញ្ញាបនបត្រអនុម័តគំរូ ត្រូវចាត់ទុកជាការបញ្ឈប់ដំណើរការ សេវាកម្ម ពាណិជ្ជកម្ម អាជីវកម្មលើគំរូអនុម័ត។

**ប្រការ១២ :** ក្នុងករណី វិញ្ញាបនបត្រអនុម័តគំរូ ផុតសុពលភាព ហើយម្ចាស់គំរូអនុម័តមិនបានមកបន្តទៅតាមនីតិវិធីបានកំណត់ និងនៅតែបន្តធ្វើសេវាកម្ម ពាណិជ្ជកម្ម អាជីវកម្ម សេវាកម្មលើគំរូ ដែលវិញ្ញាបនបត្រអនុម័តគំរូអស់សុពលភាព ឬគ្មានត្រូវព្រមាន និងត្រូវពិន័យអន្តរការណ៍ ទៅតាមមាត្រា ៤២ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ។

**ប្រការ១៣ :** ការព្រមាន និងពិន័យអន្តរការណ៍ ដែលមានចែងក្នុងច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យ របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ ករណីជនល្មើស មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវបញ្ជូនសំណុំរឿង ទៅតុលាការ មានសមត្ថកិច្ច។

**ប្រការ១៤ :** រាល់ប្រកាសនិងសេចក្តីសម្រេចទាំងឡាយណា ដែលមានន័យផ្ទុយ នឹងខ្លឹមសារ នៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥ :** អគ្គាធិការនៃអគ្គធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ អគ្គនាយក គ្រប់អគ្គនាយកដ្ឋាន ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានមន្ទីរពិសោធន៍មាត្រាសាស្ត្រ មានភារកិច្ចអនុវត្ត ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ។

**ប្រការ១៦ :** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី..០៨...ខែ..កក្កដា......ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

**ស៊ុយ_សែម**

<u>**កន្លែងទទួល :**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- គ្រប់នាយកដ្ឋាន សេនាធិការ ក្រសួងឧ.រ.ថ
- គ្រប់សហគ្រាសសាធារណៈ ចំណុះក្រសួង ឧ.រ.ថ
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៧១ MIH / 2014

## ប្រកាស
## ស្តីពី
## ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត
## ជូនរដ្ឋបាលកណ្តាល នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ

-យោងប្រកាសរួមលេខ ១០០៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងប្រកាសរួមលេខ ១០០៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងសារាចរណែនាំលេខ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធី ផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ

-យោងលិខិតលេខ២០៧ សជណ.ឧស ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

## សម្រេច

**ប្រការ១** ៖ ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលកណ្តាល នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មដែលបំពេញភារកិច្ចគ្រប់គ្រងប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ និងការដាក់ពិន័យសម្រាប់ឧបត្ថម្ភជូនមន្ត្រីរាជការដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀតព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ ៨៥៥ ២៣ ២១១ ៧៦៥
ទូរសារលេខ ៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: min smicabinet@gmail.com

**ប្រការ២** ៖ ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តនេះត្រូវបានផ្តល់ជូនដោយផ្អែកលើមូលដ្ឋាននៃការបែងចែកភារកិច្ចក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយរដ្ឋបាលកណ្តាល នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣** ៖ អនុញ្ញាតឱ្យរដ្ឋបាលកណ្តាល នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្ត ដោយកាត់យកពីប្រាក់ចំណូលដែលប្រមូលបាន ផ្អែកតាមសមាមាត្រដែលកំណត់ដោយប្រកាសរួមលេខ១០០៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ចំណែកប្រាក់រង្វាន់នេះ ត្រូវចាត់ទុកថាជាប្រាក់បុរេប្រទានដែលបានបើកផ្តល់ដោយថវិកាជាតិ។

**ប្រការ៤** ៖ ការផ្តល់ប្រាក់រង្វាន់ជូនរដ្ឋបាលកណ្តាល នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបែងចែកដូចខាងក្រោម៖

ក.ចំពោះចំណូលពីកម្រៃសេវាសាធារណៈ

ក១.ចំណូលពីកម្រៃសេវាសាធារណៈ

-បង់ចូលថវិកាជាតិ ចំនួន៧០% នៃប្រាក់ចំណូលដែលប្រមូលបាន។

-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន១% នៃប្រាក់ចំណូលដែលប្រមូលបាន។

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំនួន២៩% នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖

+៧០%ប្រគល់ជូនរដ្ឋទេយ្យករចំណូលក្រសួង សម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តជូន ថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់នៅក្នុងក្រសួង។

+៣០% រក្សាទុកនៅរដ្ឋទេយ្យករចំណូលរង សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

ក២.ចំណូលពីការត្រួតពិនិត្យផ្ទៀងផ្ទាត់ប្រភេទឧបករណ៍មាត្រាសាស្ត្រ ដែលត្រូវបានប្រើសម្រាប់ធ្វើអាជីវកម្ម

-បង់ចូលថវិកាជាតិចំនួន៥០% នៃប្រាក់ចំណូលដែលប្រមូលបាន។

-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន១%នៃប្រាក់ចំណូលដែលប្រមូលបាន។

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំនួន៤៩% នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖

+៥០% ប្រគល់ជូនរដ្ឋទេយ្យករចំណូលក្រសួង សម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ក្នុងក្រសួង។

+៥០% រក្សាទុកនៅរដ្ឋទេយ្យករចំណូលរង សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

ខ.ចំណូលពីការពិន័យលើការឃើញយ៉ាវចំពោះការបង់កម្រៃប្រចាំឆ្នាំរយៈពេល៦ខែ

-បង់ចូលថវិកាជាតិចំនួន៥០% នៃប្រាក់ចំណូលដែលប្រមូលបាន។

-ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន១%នៃប្រាក់ចំណូលដែលប្រមូលបាន។

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំនួន៤៩%នៃប្រាក់ចំណូលដែលប្រមូលបាន ក្នុងនោះ៖

+៧០%ប្រគល់ជូនរដ្ឋទេយ្យករចំណូលក្រសួងសម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់ក្នុងក្រសួង។

+៣០% រក្សាទុកនៅរដ្ឋទេយ្យករចំណូលរង សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

គ.ចំណូលពីការអនុវត្តភារកិច្ចកិច្ចសន្យារបស់ភាគីជួលទីតាំងអចលនទ្រព្យក្នុងចន្លោះសមាមាត្រពី០,២%ដល់០,៤% នៃប្រាក់ចំណេញពិតប្រចាំឆ្នាំ ដែលមានចែងក្នុងកិច្ចសន្យា

-ជូនក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចំនួន១០០% នៃប្រាក់ចំណូលដែលប្រមូលបាន ដោយចែកជា១២ខែ សម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការទាំងអស់ក្នុងក្រសួងនៅតាមខែនីមួយៗ ក្នុងចំនួនទឹកប្រាក់ស្មើៗគ្នាក្នុងម្នាក់ៗបន្ថែមលើប្រាក់រង្វាន់លើកទឹកចិត្តពីការផ្តល់សេវាសាធារណៈ។

ឃ.គោលការណ៍បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត

ឃ១.ប្រាក់រង្វាន់លើកទឹកចិត្តសរុប

ប្រាក់រង្វាន់លើកទឹកចិត្តដែលប្រមូលបានទាំងអស់ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នឹងធ្វើការបែងចែកជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់តាមគោលការណ៍សមធម៌ និងប្រគល់ជូនជាកញ្ចប់ដល់គ្រប់អង្គភាពទាំងអស់ចំណុះទីស្តីការក្រសួង។

ឃ២.ប្រាក់រង្វាន់លើកទឹកចិត្តរបស់អង្គភាព

គ្រប់អង្គភាពចំណុះទីស្តីការក្រសួង ក្រោយពីទទួលបានកញ្ចប់ប្រាក់រង្វាន់លើកទឹកចិត្តពីនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុហើយត្រូវធ្វើការបែងចែកដោយឈរលើគោលការណ៍សមធម៌ ផ្អែកតាមគុណសម្បត្តិការងារនិងធានាបាននូវសាមគ្គីភាពផ្ទៃក្នុងរបស់អង្គភាពរៀងៗខ្លួនរួចធ្វើរបាយការណ៍នៃការចំណាយរួមមានចំណាយសម្រាប់ពង្រឹងយន្តការប្រមូលចំណូល និងចំណាយសម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តមន្ត្រីរាជការមកនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ត្រឹមថ្ងៃទី៥ នៃខែបន្ទាប់ ដើម្បីធ្វើរបាយការណ៍បូកសរុបទូទាត់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៥ ៖** គោលការណ៍នៃការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តខាងលើនេះ អាចនឹងប្រែប្រួលទៅតាមការចាំបាច់របស់ក្រសួង ដោយអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៦ ៖** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ តទៅ។

**ប្រការ៧ ៖** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨ ៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការដ្ឋាន ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៤

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ចម ប្រសិទ្ធ

**កន្លែងទទួល ៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

-អាជ្ញាធរសវនកម្មជាតិ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ និងនាយកដ្ឋានចំណូលសាធារណៈ)

-ដូចប្រការ ៨ (ដើម្បីអនុវត្ត)

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ០០៤២ ឧ.រ.ថ ន.ន២ - សរចណន .

# សារាចរណែនាំ

## ស្តីពី

## ការហាមឃាត់តម្លើងបន្ថែម និងប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច ឬកម្មវិធី Software ដែលមានគោលបញ្ជាកំណត់បរិមាណផ្គត់ផ្គង់ ចែកចាយប្រេងឥន្ធនៈ

<u>យោង :</u>

- ព្រះរាជក្រមលេខៈ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- អនុក្រឹត្យលេខៈ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សេចក្តីជូនដំណឹង ស្តីពី ការអនុវត្តន៍ច្បាប់មាត្រាសាស្ត្រកម្ពុជា លេខៈ ១៣២៤ ឧរថ.ម.ម.ជ. សជណ. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១
- ពិនិត្យតាមសំណូមពរការងារចាំបាច់លើការគ្រប់គ្រងវិស័យមាត្រាសាស្ត្រ។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពិនិត្យឃើញថាបច្ចុប្បន្ននេះ រូបវន្តបុគ្គល ឬនីតិបុគ្គលមួយចំនួនបានប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្របែងចែកប្រេង (Fuel Dispenser) ក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម ផ្គត់ផ្គង់ នៅតាមស្ថានីយ៍ចែកចាយប្រេងឥន្ធនៈ ដោយតម្លើងភ្ជាប់បន្ថែមនូវ ប្រព័ន្ធឧបករណ៍អគ្គិសនី ឬ ឧបករណ៍អេឡិចត្រូនិចដែលមានគោលបញ្ជាសម្រាប់កំណត់រង្វាស់រង្វាល់បរិមាណប្រេងឥន្ធនៈក្នុងការផ្គត់ផ្គង់ ចែកចាយ ដោយគ្មានការអនុញ្ញាត ពីសមត្ថកិច្ចគ្រប់គ្រងផ្នែកមាត្រាសាស្ត្រ និងផ្ទុយនឹងខ្លឹមសារក្នុងមាត្រា២៧ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាទាំងស្រុង មិនតែប៉ុណ្ណោះឧបករណ៍អេឡិចត្រូនិចនេះ ជាមូលហេតុបង្កឱ្យមានការកេងបន្លំបរិមាណប្រេងឥន្ធនៈ ក្នុងការផ្គត់ផ្គង់ ចែកចាយ ដល់អតិថិជនបានគ្រប់ពេល និង យ៉ាងងាយស្រួលបំផុត។

ដើម្បីធានានិរន្តភាពនៃការគ្រប់គ្រងផ្នែកមាត្រាសាស្ត្រ និងការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រដូចមានចែងក្នុងជំពូកទី៦ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ឲ្យបានត្រឹមត្រូវ និងដើម្បីរារាំងនិងទប់ស្កាត់ការកេងបន្លំបរិមាណ **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** សូមធ្វើការណែនាំដល់គ្រប់ រូបវន្តបុគ្គល និងនីតិបុគ្គល ដែលធ្វើសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម ផ្គត់ផ្គង់ ចែកចាយប្រេងឥន្ធនៈ ឬ ផ្តល់សេវាកម្មជួសជុល ឬ តម្លើងឧបករណ៍មាត្រាសាស្ត្របែងចែកប្រេងឥន្ធនៈនៅតាមស្ថានីយ៍ប្រេងឥន្ធនៈដែលបានកំពុង ឬ បម្រុងតម្លើងភ្ជាប់បន្ថែមនូវប្រព័ន្ធឧបករណ៍អគ្គិសនី ឬអេឡិចត្រូនិច ដែលមានគោលបញ្ជាកំណត់

បរិមាណប្រេងឥន្ធនៈក្នុងប្រព័ន្ធម៉ាស៊ីនផ្គត់ផ្គង់ចែកចាយប្រេងឥន្ធនៈដែលមានស្រាប់ត្រូវតែបញ្ឈប់ និង ហាមដាច់ខាតក្នុងការប្រើប្រាស់ ឬ ការតម្លើងបន្ថែមឧបករណ៍អគ្គិសនី ឬ អេឡិចត្រូនិចទាំងនោះ ។

ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនគោរពអនុវត្តតាមចរាចរណែនាំនេះ ក្រសួងនឹងចាត់វិធានការព្រមាន ឬពិន័យអន្តរការណ៍ ដូចមានចែងក្នុងជំពូកទី១០ "ទោសប្បញ្ញត្តិ" នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា។

ទទួលបានសារាចរណែនាំនេះ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ គ្រប់អគ្គនាយកដ្ឋាន វិទ្យាស្ថានស្តង់ដារកម្ពុជា នាយកខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ រូបវន្តបុគ្គល និង នីតិបុគ្គល ដែលធ្វើសកម្មភាពប្រើប្រាស់ ជួសជុល ឬ តម្លើងឧបករណ៍មាត្រាសាស្ត្រខាងលើត្រូវគោរពអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

ស៊ុយ សែម

<u>ចំលងជូនៈ</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- គ្រប់ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន-នាយកដ្ឋានក្រោមឱវាទក្រសួង ឧរថ "ដើម្បីជូនជ្រាប"
- គ្រប់សាលារាជធានី-ខេត្ត
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី-ខេត្ត "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ០៣៣៨ ឧរថ.មមជ.សជណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

# សេចក្តីជូនដំណឹង
# ស្តីពី
# ការនាំចូលឧបករណ៍ស្តង់ដារមាត្រាសាស្ត្រ និង ឧបករណ៍មាត្រាសាស្ត្រ

**យោង:**
- ព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី មាត្រាសាស្ត្រកម្ពុជា
- អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- ប្រកាសលេខ ៨៥៨ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- សេចក្តីជូនដំណឹងលេខ ១៣២៤ ឧរថ.ម.ម.ជ.សជណ ចុះថ្ងៃទី០១ ខែកក្កដាឆ្នាំ២០១១ ស្តីពី ការអនុវត្តន៍ច្បាប់មាត្រាសាស្ត្រកម្ពុជា

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានកិត្តិយស សូមជម្រាបជូន ដល់គ្រប់បណ្តាក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម ដែលកំពុងធ្វើការនាំចូលឧបករណ៍ស្តង់ដារមាត្រាសាស្ត្រ និងឧបករណ៍មាត្រាសាស្ត្រ សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្ម និងវិស័យផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា២៨ នៃច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា: ច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា បានកំណត់ថា រាល់ឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ អាចអនុញ្ញាតបានលុះត្រាតែ ឧបករណ៍ស្តង់ដារមាត្រាសាស្ត្រ និងឧបករណ៍មាត្រាសាស្ត្រ នោះ៖

- មានភាពត្រឹមត្រូវ និងសមមូល ឬស្របទៅតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចបានកំណត់ក្នុង **ឧបសម្ព័ន្ធទី១** និង **ឧបសម្ព័ន្ធទី២** នៃច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា
- មានការបញ្ជាក់សមត្ថភាព អប្បបរមា និងអតិបរមា អំពីទម្ងន់ និង/ឬ រង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រនោះ
- មានពាណិជ្ជសញ្ញា និងមានការបញ្ជាក់ពីការពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរបស់មន្ត្រីត្រួតពិនិត្យនៃ **ម.ម.ជ.**
- មានការអនុម័តគំរូលើឧបករណ៍មាត្រាសាស្ត្រ ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard. Khan Daun Penh. Phnom Penh. Phone : 855-23-211141, Fax : 855-23-428263

ដើម្បីជានានិរន្តភាពនៃការគ្រប់គ្រង និងអនុវត្តការងារនេះអោយមានប្រសិទ្ធភាពខ្ពស់ លើការនាំចូលឧបករណ៍ស្តង់ដារមាត្រាសាស្ត្រ និងឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សូមធ្វើការណែនាំ គ្រប់បណ្តា ក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម ដែលបំរុងបន្តធ្វើការនាំចូលរាល់ឧបករណ៍ស្តង់ដារមាត្រាសាស្ត្រ និងឧបករណ៍មាត្រាសាស្ត្រគ្រប់ប្រភេទទាំងអស់ ត្រូវមកបំពេញបែបបទពាក្យស្នើសុំលិខិតអនុញ្ញាតការនាំចូលឧបករណ៍មាត្រាសាស្ត្រ ឲ្យបានត្រឹមត្រូវ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលមានអាសយដ្ឋានៈ អគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ) ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម គ្រប់បណ្តា ក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម ចូលរួមសហការជាមួយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអនុវត្តតាមការណែនាំខាងលើ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១... ខែ[illegible] ឆ្នាំ២០១៤

**ស៊ុយ សែម**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួង - ស្ថាប័នជំនាញពាក់ព័ន្ធ
- សភាពាណិជ្ជកម្មកម្ពុជា
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- គ្រប់អគ្គនាយកដ្ឋាន-នាយកដ្ឋាន ក្រោមឱវាទក្រសួងឧរថ

  "ដើម្បីជូនជ្រាប"
- គ្រប់សាលារាជធានី - ខេត្ត
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី - ខេត្ត

  "ដើម្បីសហការអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ៤២១៧ MIH / 2015

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥

**ជម្រាបជូន**
**លោកឧកញ៉ា លោក-លោកស្រី ប្រធានក្រុមហ៊ុន**
**និងម្ចាស់ស្ថានីយ៍ ដេប៉ូចែកចាយប្រេងឥន្ធនៈ**

**កម្មវត្ថុៈ** អំពីប្រសិទ្ធភាពនៃការធានាសុក្រិតភាពនៃបរិមាណប្រេងឥន្ធនៈ ចែកចាយជូនអ្នកប្រើប្រាស់។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន លោកឧកញ៉ា លោក-លោកស្រី ប្រធានក្រុមហ៊ុន និងម្ចាស់ស្ថានីយ៍ ដេប៉ូចែកចាយប្រេងឥន្ធនៈ ទាំងអស់ជ្រាបថាៈ នាពេលកន្លងមក ឆ្លងតាមលទ្ធផលត្រួតពិនិត្យផ្ទៀងផ្ទាត់របស់មន្ត្រីត្រួតពិនិត្យផ្នែកប្រេងឥន្ធនៈ នៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបង្ហាញឲ្យឃើញថាផលិតផលប្រេងឥន្ធនៈ ដែលបាននឹងកំពុងចរាចរចែកចាយដោយស្ថានីយ៍ ក្រុមហ៊ុន ដេប៉ូចែកចាយភាគច្រើនគឺមានភាពអនុលោមតាមបរិមាណព្រមទាំងគោរពបានយ៉ាងពេញលេញតាមលក្ខខណ្ឌតម្រូវស្របតាមបញ្ញត្តិនៃច្បាប់ ប្រកបដោយស្មារតីទទួលខុសត្រូវគួរជាទីមោទនៈ។

ទន្ទឹមនឹងនោះលទ្ធផលក៏បានរកឃើញនូវភាពមិនប្រក្រតីដោយអន្លើ ដែលកើតចេញពីការបន្លំលើបរិមាណផ្គត់ផ្គង់ជូនអ្នកប្រើប្រាស់ មិនត្រឹមត្រូវតាមការប្រកាសរបស់ស្ថានីយ៍ និងដេប៉ូចែកចាយមួយចំនួន ដែលធ្វើឲ្យអ្នកប្រើប្រាស់ខាតបង់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ព្រមទាំងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សមធម៌នៃការធ្វើពាណិជ្ជកម្មទៀតផង។

ដូច្នេះ ដើម្បីកំណត់ឲ្យបានជាក់លាក់ អំពីបន្ទុកទទួលខុសត្រូវផ្នែកច្បាប់ ចំពោះភាពមិនប្រក្រតីខាងលើ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមធ្វើការដកស្រង់នូវខ្លឹមសារដែលមានចែងក្នុងបទដ្ឋានគតិយុត្តិមួយចំនួនជូន លោកឧកញ៉ា លោក-លោកស្រី ប្រធានក្រុមហ៊ុន និងម្ចាស់ស្ថានីយ៍ ដេប៉ូចែកចាយប្រេងឥន្ធនៈ ទាំងអស់ធ្វើការស្វែងយល់ និងចាត់ចែងអនុវត្ត ដូចខាងក្រោមៈ

១.បទបញ្ញត្តិនៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាៈ

មាត្រា ២២ ជំពូកទី៦ ការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រៈ "ឧបករណ៍មាត្រាសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវស្របតាមប្រពន្ធ័ឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចបានកំណត់ក្នុង ឧបសម្ព័នទី១ និងឧបសម្ព័នទី២"។

មាត្រា ២៣ ជំពូកទី៦ ការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រៈ "ឧបករណ៍មាត្រាសាស្ត្រ ដែលបានអនុញ្ញាតឲ្យប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្មបាន ត្រូវតែមានភាពត្រឹមត្រូវ"។

មាត្រា ២៦ ជំពូកទី៦ ការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រៈ "ថ្លឹងឬវាស់វាល់ទំនិញ ឬផលិតផលក្នុងហាង ឃ្លាំងទីផ្សារ ឬ កន្លែងសាធារណៈត្រូវថ្លឹង ឬ វាស់វាល់នៅចំពោះមុខអ្នកទិញ"។

**២.បទបញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវាៈ**

មាត្រា ១៩ ជំពូកទី៤ ការបង្ក្រាបការក្លែងបន្លំពាណិជ្ជកម្មៈ "ត្រូវហាមការរក្សាទុកនៅទីកន្លែងផលិត ទីកន្លែងសហគ្រាសកម្មាករណ៍ និងទីកន្លែងធ្វើពាណិជ្ជកម្មនូវផលិតផលក្លែងបន្លំ ផលិតផលឧបករណ៍សម្រាប់កិច្ចបន្លំ ឬក្លែងចំពោះទំនិញគ្រប់មុខ ការផលិតការប្រើប្រាស់ការធ្វើពាណិជ្ជកម្ម ការរក្សាទុកនូវរង្វាស់រង្វាល់ និងឧបករណ៍សម្រាប់វាស់វែង សម្រាប់វាល់ ឬ ថ្លឹងដែលខុស ឬ ពុំទៀងទាត់ក្នុងការប្រើប្រាស់សម្រាប់ផលិតកម្ម ឬ ពាណិជ្ជកម្មទំនិញ"។

មាត្រា ២០ ជំពូកទី ៤ ការបង្ក្រាបការក្លែងបន្លំពាណិជ្ជកម្មៈ " ត្រូវហាមឃាត់ការធ្វើពាណិជ្ជកម្មនូវបណ្តាផលិតផល និងឧបករណ៍ដែលសំដៅយកមកបំពេញកិច្ចបន្លំ ឬ ក្លែងមុខទំនិញទាំងឡាយ"។

ក្នុងករណីដែលល្មើសនឹងបណ្តាមាត្រាក្នុងបទបញ្ញត្តិខាងលើ នឹងត្រូវទទួលទោសទណ្ឌដែលមានចែងយ៉ាងច្បាស់ត្រង់ជំពូកទី ១០ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងត្រង់ជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា។

ដោយកាលៈទេសៈ និងស្ថានភាពបច្ចុប្បន្ន តម្រូវជាចាំបាច់ត្រូវធ្វើការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តច្បាប់ឲ្យបានម៉ឺងម៉ាត់ ព្រោះថាកិច្ចការពាក់ព័ន្ធនានាខាងលើ ពិសេសសកម្មភាពត្រួតពិនិត្យផ្ទៀងផ្ទាត់ម៉ាស៊ីនចែកចាយប្រេងជាក់ស្តែងធ្លាប់បានទទួលការអប់រំផ្សព្វផ្សាយជាច្រើនលើកច្រើនសារួចមកហើយ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម តម្រូវឲ្យគ្រប់ស្ថានីយ៍ និងដេប៉ូចែកចាយប្រេងឥន្ធនៈទាំងអស់ ត្រូវមានថូស្តង់ដាចំនួន ០១ កំប្លេ (០១លីត្រ,០២លីត្រ,០៥លីត្រ និង១០លីត្រ) ដាក់តាំងនៅកន្លែងលក់ ចែកចាយ សម្រាប់ជូនអ្នកប្រើប្រាស់ ឬ អតិថិជន អាចធ្វើការផ្ទៀងផ្ទាត់បរិមាណប្រេងឥន្ធនៈ ដែលពួកគាត់បានទិញនៅកន្លែងដោយផ្ទាល់ដើម្បីធានាការផ្គត់ផ្គង់បរិមាណប្រេងឥន្ធនៈ បានត្រឹមត្រូវជាប្រចាំតាមការប្រកាសរបស់ស្ថានីយ៍ និងដេប៉ូចែកចាយជូនអ្នកប្រើប្រាស់។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមទុករយៈពេលចំនួន ០៣ ខែ (បីខែ) ដោយគិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅដើម្បីឲ្យ លោកឧកញ៉ា លោក-លោកស្រី ប្រធានក្រុមហ៊ុន និងម្ចាស់ស្ថានីយ៍ ដេប៉ូចែកចាយប្រេងឥន្ធនៈទាំងអស់អាចបំពេញតាមការតម្រូវខាងលើនេះ និងកង្វះខាតផ្សេងៗរបស់ខ្លួនឲ្យបានសមស្រប។ ផុតកាលបរិច្ឆេទនៃការកំណត់នេះ អង្គភាពជំនាញរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មនឹងអនុវត្តនូវវិធានការទៅតាមនីតិវិធីក្រោមអណត្តិទទួលខុសត្រូវរបស់ខ្លួន ដូចមានចែងក្នុងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធជាធរមាន។

ខ្ញុំជឿជាក់ថា ការអនុវត្តទៅតាមបញ្ញត្តិដូចបានបញ្ជាក់ខាងលើ និងធ្វើឲ្យអ្នកប្រើប្រាស់ ឬ អតិថិជនកាន់តែមានទំនុកចិត្តគាំទ្រ ហើយថែមទាំងអាចធ្វើឲ្យកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនស្ថានីយ៍ ដេប៉ូចែកចាយរបស់លោកឧកញ៉ា លោក-លោកស្រី កាន់តែល្អនិងឈានទៅរកបរិយាកាសធុរៈកិច្ចកាន់តែប្រសើរឡើង។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំ លើការយកចិត្តទុកដាក់ប្រកបដោយស្មារតី ទទួលខុសត្រូវខ្ពស់របស់ លោកឧកញ៉ា លោក-លោកស្រី ប្រធានក្រុមហ៊ុន និងម្ចាស់ស្ថានីយ៍ ដេប៉ូចែកចាយប្រេងឥន្ធនៈ ទាំងអស់នឹង បន្តសហការល្អក្នុងការអនុវត្តន៍ការងារនេះឲ្យបានជោគជ័យ និងប្រសិទ្ធភាពជាក់ជាពុំខាន។

សូម លោកឧកញ៉ា លោក-លោកស្រី ទទួលនូវការរាប់អានអំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

ចម្លងជូន៖
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
-ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង**
-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងព័ត៌មាន
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion king

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry,Mines and Energy
№ ៤៤៣ ឧរថ.មស-សវណា

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ មិនា ឆ្នាំ២០០៣

# សេចក្តីជូនដំណឹង

## ដល់ម្ចាស់មធ្យោបាយដឹកជញ្ជូនផ្ទុកចំណុះវត្ថុធាតុរាវ
## ដែលប្រើប្រាស់ ក្នុងព្រះរាជាណាចក្រកម្ពុជា

យោង :
- អនុក្រឹត្យលេខ ៣៥អនក្រ.បក ចុះថ្ងៃទី២៦ ខែ០៤ ឆ្នាំ១៩៩៩ ស្តីអំពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- សារាចរណែនាំលេខ ០៣នប.ទរចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាគ្រប់គ្រងទម្ងន់ និងរង្វាស់រង្វាល់ ។
- សេចក្តីសំរេចលេខ ០៣មស.សសរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ ស្តីពីភារកិច្ចដឹកនាំគ្រប់គ្រងមាត្រាសាស្ត្រ ។

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មានកិត្តិយសសូមជំរាបជូនដល់ម្ចាស់មធ្យោបាយដឹកជញ្ជូនផ្ទុកចំណុះវត្ថុធាតុរាវទាំងអស់ដែលធ្វើអាជីវកម្មដឹកជញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមជ្រាបថា: ចាប់ពីពេលនេះតទៅ នាយកដ្ឋានមាត្រាសាស្ត្រនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នឹង ចាត់ចែងធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់នូវចំណុះនៃមធ្យោបាយដឹកជញ្ជូនវត្ថុធាតុរាវនិមួយៗ ដើម្បីបង្កើនការជឿជាក់ពីភាពត្រឹមត្រូវ រវាងអ្នកផ្គត់ផ្គង់ និងអ្នកទទួលប្រើប្រាស់ ។ ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់នាយកដ្ឋាននឹងមានកម្មវិធីដោយសហការនិងទំនាក់ទំនងជាមួយអស់លោក-លោកស្រីដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូនផ្ទុកចំណុះវត្ថុរាវនេះ តាមការជាក់ស្តែងជាបន្តបន្ទាប់ ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជាម្ចាស់មធ្យោបាយដឹកជញ្ជូនផ្ទុកចំណុះវត្ថុធាតុរាវទាំងអស់សហការអនុវត្តកិច្ចការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមសេចក្តីជូនដំណឹងនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សង្ឃឹមលើស្មារតីសហការពីអស់លោក-លោកស្រីដើម្បីអនុវត្តកិច្ចការនេះមានប្រសិទ្ធភាព ។

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ទីស្តីការក្រសួង - ស្ថាប័ន
- ផ្សព្វផ្សាយទូលំទូលាយ
- វិទ្យុ ទូរទស្សន៍ និង សារពត៌មាន (ឧបត្ថម្ភផ្សព្វផ្សាយ)

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ស៊ុយ-សែម

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ : (៨៥៥)២៣-៤២៨ ២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh (Cambodia) Tel/Fax (855) 23- 428 263

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខៈ ៤៤៥០ MIH / 2015

**សូមជម្រាបជូន**
**លោកឧកញ៉ា លោក លោកស្រី ប្រធានក្រុមហ៊ុន**
**ម្ចាស់ស្ថានីយ៍ និងម្ចាស់ដេប៉ូ លក់ ចែកចាយប្រេងឥន្ធនៈ**

**កម្មវត្ថុ** ៖ សេចក្តីណែនាំអំពីការចូលរួមសហការ ពង្រឹងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ។

**យោង** ៖ - ព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ

- ព្រះរាជក្រឹត្យលេខ នស/រកត/១១១៤/១២៩៨ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកំណត់ស្តង់ដារគោលជាតិលីត្រ
- ប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម លេខ ៧១៧ សហវ.ប្រក. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីកាផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកឧកញ៉ា លោក លោកស្រីជាប្រធានក្រុមហ៊ុន ម្ចាស់ស្ថានីយ៍ និងម្ចាស់ដេប៉ូដែលកំពុងប្រកបអាជីវកម្មលក់ ចែកចាយប្រេងឥន្ធនៈក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ៖ កន្លងមក ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានពិនិត្យឃើញថា មានក្រុមហ៊ុន ស្ថានីយ៍ ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈមួយចំនួន បានអនុវត្តត្រឹមត្រូវតាមច្បាប់ស្តីពីមាត្រាសាស្ត្រ ពិសេស ការចូលរួមគោរពបទដ្ឋានស្តង់ដារង្វាស់រង្វាល់ (លីត្រ) ដែលសបញ្ជាក់ឱ្យឃើញនូវការយកចិត្តទុកដាក់ក្នុងការគោរពអនុវត្តច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការចូលរួមកសាងនីតិរដ្ឋក្នុងសង្គមផងដែរ។ ការអនុវត្តបានល្អនូវច្បាប់ស្តីពីមាត្រាសាស្ត្រ នឹងនាំមកនូវផលប្រយោជន៍ ៖

- ធានាឱ្យការធ្វើពាណិជ្ជកម្ម មានភាពយុត្តិធម៌ ត្រឹមត្រូវ និងសុចរិត
- ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ផលិតផល ទំនិញ និងសេវាកម្ម
- ធានាបាននូវការធ្វើឱ្យប្រសើរឡើងនូវគុណភាព ផលិតផល ទំនិញ និងសេវាកម្ម និងការគ្រប់គ្រង
- ធ្វើឱ្យមានជំនឿ និងទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ (ឧបករណ៍ទម្ងន់ ឬរង្វាស់រង្វាល់) ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងទៀត ដើម្បីសុខភាព សុវត្ថិភាព និងបរិស្ថាន។

មិនតែប៉ុណ្ណោះ តាមរយៈការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រស្របតាមស្តង់ដាមាត្រាសាស្ត្រជាតិ តាមការកំណត់នៃច្បាប់ គឺជាកត្តាទាក់ទាញការគាំទ្រពីសំណាក់អតិថិជន មកលើអ្នកលក់ ផ្គត់ផ្គង់ផលិតផល ទំនិញ និងសេវាកម្ម ហើយអាចបង្កើនបាននូវថែមទៀតនូវសក្តានុពលសេដ្ឋកិច្ច សម្រាប់ក្រុមហ៊ុន ស្ថានីយ៍ និងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈរបស់ លោកឧកញ៉ា លោក លោកស្រី ក៏ដូចជាសម្រាប់សង្គមជាតិ។

ប៉ុន្តែទន្ទឹមនឹងនេះ ក្រសួងក៏បានសង្កេតឃើញដែរថា នៅមានក្រុមហ៊ុន ស្ថានីយ៍ និងដេប៉ូលក់ចែកចាយប្រេងឥន្ធនៈមួយចំនួន ពុំទាន់បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនស្របតាមច្បាប់ស្តីពីមាត្រាសាស្ត្រនៅឡើយ ដែលចាំបាច់ត្រូវបន្តពង្រឹង និងលើកកម្ពស់ការចូលរួមសហការអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរថែមទៀត ដើម្បីធានាបាន



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខៈ (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែលៈ mih.smcabinet@gmail.com

ផលប្រយោជន៍ទាំងសងខាង (ទាំងសាមីក្រុមហ៊ុន ស្ថានីយ៍ ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈ ទាំងប្រជាពលរដ្ឋដែលជាអតិថិជន និងសម្រាប់សង្គមទាំងមូលផងដែរ)។

ដូចនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមធ្វើការណែនាំដូចខាងក្រោម ៖

១- ឧបករណ៍មាត្រាសាស្ត្រដែលប្រើប្រាស់ជាឧបករណ៍វាស់វែង ត្រូវមានជាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ ដែលរួមមាន៖ សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ និងបន្ទាប់ពីការជួសជុល ឬការកែតម្រូវរួច (ក្នុងករណីមានការជួសជុល ឬកែតម្រូវឡើងវិញ) ដែលអនុវត្តដោយមន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

២- ប្រធានក្រុមហ៊ុន ម្ចាស់ស្ថានីយ៍ និងម្ចាស់ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈ ត្រូវមានការកិច្ចសហការល្អជាមួយមន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ ជាពិសេស ការត្រួតពិនិត្យ ពង្រឹង និងជំរុញការប្រើប្រាស់ឧបករណ៍វាស់វែង និងមធ្យោបាយដឹកជញ្ជូនប្រេងឥន្ធនៈស្របតាមស្តង់ដារមាត្រាសាស្ត្រ។

៣- ចំពោះកម្រៃសេវាសាធារណៈដែលមានការពាក់ព័ន្ធ នឹងត្រូវអនុវត្តដោយតម្លាភាព ស្របតាមប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម លេខ ៧១៧ សហវ.ប្រក. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

៤- ករណីមន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រ ដែលបំពេញមុខងារក្នុងនីតិសម្បទាជានគរបាលយុត្តិធម៌ ពិនិត្យឃើញថា ក្រុមហ៊ុន ស្ថានីយ៍ និងដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈណាមួយ នៅបន្តការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រនៅក្នុងការធ្វើអាជីវកម្មរបស់ខ្លួន ដែលមិនអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីមាត្រាសាស្ត្រ ក្រសួងនឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា លោកឧកញ៉ា លោក លោកស្រី ប្រធានក្រុមហ៊ុន ម្ចាស់ស្ថានីយ៍ និងម្ចាស់ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈ ចូលរួមអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រ និងការណែនាំខាងលើ ឱ្យមានប្រសិទ្ធភាព។

សូមលោកឧកញ៉ា លោក លោកស្រី ប្រធានក្រុមហ៊ុន ម្ចាស់ស្ថានីយ៍ និងម្ចាស់ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈទាំងអស់ ទទួលនូវការពេញអានដ៏ស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សភាពាណិជ្ជកម្មកម្ពុជា
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត
- បណ្តាញផ្សព្វផ្សាយព័ត៌មាន
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
Ministry fo Industry, Mines and Energy
មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
National Metrology Center
លេខ / No. ២៤៤៩ ន.ន.ម

# សេចក្តីជូនដំណឹង
## ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់

ច្បាប់ស្តីពីមាត្រាសាស្ត្រ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ក្នុងគោលបំណងធានាឲ្យការធ្វើពាណិជ្ជកម្ម មានភាពយុត្តិធម៌ និងត្រឹមត្រូវ បង្កឲ្យការវេចខ្ចប់ផលិតផលទំនិញប្រកបដោយភាពត្រឹមត្រូវ សុចរិត ធានាផលប្រយោជន៍រវាងអ្នកប្រើប្រាស់ ផលិតផលទំនិញ និងសេវាកម្ម ធ្វើឲ្យប្រសើរ ឡើងនូវគុណភាពផលិតផលទំនិញ សេវាកម្មនិងការគ្រប់គ្រង ដើម្បីភាពរីកចំរើននៃ សេដ្ឋកិច្ច និងសុខដុមនីយកម្មក្នុង សកម្មភាព ពាណិជ្ជកម្ម ឧស្សាហកម្ម អាជីវកម្ម សេវាកម្ម លើវិស័យ មាត្រាសាស្ត្រ។

ច្បាប់ស្តីពីមាត្រាសាស្ត្រ បានចូលជាធរមានអស់រយៈពេល៣ឆ្នាំមកហើយ។ ក្នុងរយៈពេលកន្លងមកនេះ **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** នៅតែសង្កេតឃើញថាបណ្តា ក្រុមហ៊ុន សហគ្រាស សិប្បកម្ម មណ្ឌលពាណិជ្ជកម្ម អាជីវករ និងពាណិជ្ជករ មួយចំនួននៅបន្តធ្វើការលក់ដូរទំនិញផលិតនិងទំនិញវេចខ្ចប់ពុំមានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងធ្វើការអនុម័តគំរូពីទម្ងន់ និងវង្វាស់វង្វាល់ឲ្យបានត្រឹមត្រូវដោយមន្ត្រីមានសមត្ថកិច្ចរបស់ **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** នៅឡើយ។ ដើម្បីពង្រឹងលើកកំពស់ការគ្រប់គ្រងវិស័យមាត្រាសាស្ត្រ និងជំរុញការអនុវត្តច្បាប់នេះក្នុងគោលបំណងធានាការពារផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** មានកិត្តិយសជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អង្គភាពសេដ្ឋកិច្ច នាយកក្រុមហ៊ុន សហគ្រិន អាជីវករ និងពាណិជ្ជករ *ដែលកំពុងតាំងលក់រាល់ទំនិញផលិត និង ទំនិញវេចខ្ចប់ក្នុងស្រុក និងនាំចូលសំរាប់លក់ ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងស្រប តាមឯកតាណាមួយ នៃប្រពន្ធ័ឯកតាមាត្រាសាស្ត្រ ជាតិស្របច្បាប់ ដែលបានអនុញ្ញាតដូចមានចែងក្នុង ឧបសម្ព័ន្ធទីI និង ឧបសម្ព័ន្ធទីII នៃច្បាប់ស្តីពីមាត្រាសាស្ត្រ។ រាល់ទំនិញផលិត និងទំនិញវេចខ្ចប់ ត្រូវបញ្ជាក់ពីបរិមាណសុទ្ធ និងធានាភាពត្រឹមត្រូវនៃទម្ងន់ និងវង្វាស់វង្វាល់នៅលើសម្ភារៈ*

*វេចខ្ចប់ទំនិញនោះ ហើយត្រូវធ្វើ វីរៀបចំឡើងតាមការបញ្ជាក់ជាលក្ខណៈដើមនៃគំរូដែលបានអនុម័តពីទម្ងន់ និងរង្វាស់រង្វាល់ ឲ្យបានត្រឹមត្រូវដោយត្រូវបញ្ជាក់ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកផលិត ឬ អ្នកវេចខ្ចប់ ឬ ពាណិជ្ជសញ្ញាដើម្បីធានាភាពច្បាស់លាស់។*

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីមាត្រាសាស្ត្រ **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** សូម *កំណត់រយៈពេលបីខែ បន្ថែមដោយគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងនេះ។* ក្រោយរយៈពេលបីខែ នៃការទទួលបានសេចក្តីជូនដំណឹងនេះ រូបវន្តបុគ្គល ឬនីតិបុគ្គលពុំបានបំពេញបែបបទស្នើសុំ ឬពុំបានទំនាក់ទំនងជាលាយលក្ខអក្សរមក **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** ត្រូវចាត់ទុកថាមិនគោរពតាមបទប្បញ្ញត្តិមាត្រា៤៦ មាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩ នៃច្បាប់ស្តីពីមាត្រាសាស្ត្រហើយមជ្ឈមណ្ឌលមាត្រសាស្ត្រជាតិ នឹងអនុវត្តធ្វើការពិន័យអន្តរការណ៍តាមទោសប្បញ្ញត្តិនៃច្បាប់នេះ។ *ជនណាដែលរារាំង ឬបដិសេធមិនឲ្យមន្ត្រីត្រួតពិនិត្យអនុវត្តសិទ្ធិក្នុងប្រតិបត្តិការដែលមានចែងក្នុងច្បាប់នេះត្រូវព្រមាន ឬពិន័យអន្តរការណ៍ ដែលមានចែងក្នុងមាត្រា៥០ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ។*

សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាយកក្រុមហ៊ុន សហគ្រិន អាជីវករ និងពាណិជ្ជករ មកទំនាក់ទំនង **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** ដែលមានអាស័យដ្ឋាន អាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឬសាខារបស់ **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** រាជធានី-ខេត្តទាំង២៤។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមអង្គភាពសេដ្ឋកិច្ច ក្រុមហ៊ុន សហគ្រាស អាជីវករ ពាណិជ្ជករ និងប្រជាពលរដ្ឋទាំងអស់ជ្រាបជាព័ត៌មាន ដើម្បីចូលរួមសហការជាមួយ **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** នៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល អនុវត្តការងារនេះឲ្យមានប្រសិទ្ធភាពខ្ពស់ជូនប្រជាជនយើងទាំងអស់គ្នា។

រាជធានីភ្នំពេញ ថ្ងៃទី១៧ខែ ធ្នូ ឆ្នាំ២០១២

**ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

**បណ្ឌិត. ឡាំ គឹមឡេង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
Ministry fo Industry, Mines and Energy
**មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**
National Metrology Center
លេខ / No. ៨៤២៧ . ម.ម.ជ

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១២

# សេចក្តីជូនដំណឹងរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
## ស្តីពី
## ការលក់ ឬការដាក់តាំងសម្រាប់លក់ និងការកាន់កាប់ប្រើប្រាស់ ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាពពាណិជ្ជកម្ម សេវាកម្ម និងវិស័យផ្សេងទៀត ត្រូវមានការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងនិងការត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់

ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ក្នុងគោលបំណងសំដៅធានាឲ្យការធ្វើពាណិជ្ជកម្មមានភាពយុត្តិធម៌ និងត្រឹមត្រូវ បង្កឲ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រដោយត្រឹមត្រូវសុចរិត ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ផលិតផលទំនិញ និងសេវាកម្ម និងធានាធ្វើឲ្យប្រសើរឡើងនូវគុណភាពទំនិញ ផលិតផល សេវាកម្ម និងការគ្រប់គ្រង ដើម្បីភាពរីកចំរើននៃសេដ្ឋកិច្ច និងសុខដុមនីយកម្មក្នុងសកម្មភាពពាណិជ្ជកម្មលើវិស័យនីត្យានុកូលមាត្រាសាស្ត្រ ។

ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាបានចូលជាធរមានអស់រយៈពេល ៣ឆ្នាំ មកហើយ។ ក្នុងរយៈពេលកន្លងមកនេះ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៅតែសង្កេតឃើញថា តាមបណ្តាស្ថាប័ន អង្គភាពសេដ្ឋកិច្ច ក្រុមហ៊ុន សហគ្រាស អាជីវករ និងពាណិជ្ជករមួយចំនួន នៅបន្តប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រក្នុងសកម្មភាពពាណិជ្ជកម្ម ដោយពុំបានត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវដោយមន្ត្រីត្រួតពិនិត្យរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៅឡើយ។ ដើម្បីពង្រឹង លើកកំពស់ការគ្រប់គ្រងវិស័យមាត្រាសាស្ត្រ និងជំរុញការអនុវត្តច្បាប់នេះក្នុងគោលបំណងធានាការពារផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ មានកិត្តិយសជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាប្រធានស្ថាប័ន អង្គភាពសេដ្ឋកិច្ច នាយកក្រុមហ៊ុន សហគ្រិន អាជីវករ និងពាណិជ្ជករ *ដែលកំពុងដាក់លក់ ដាក់តាំងដើម្បីលក់ ដើម្បីចែកចាយ ដើម្បីជួល ឬកាន់កាប់ប្រើប្រាស់នូវរាល់ឧបករណ៍មាត្រាសាស្ត្រ ក្នុងសកម្មភាពពាណិជ្ជកម្ម សេវាកម្ម អាជីវកម្ម ដោយពុំទាន់បានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ គ្មានពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា គ្មានសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ដំបូងរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ឬក៏រូបវន្តបុគ្គល និងនីតិបុគ្គលដែលផ្តល់សេវាទាក់ទងនឹងការផលិត ការជួសជុលនូវឧបករណ៍មាត្រាសាស្ត្រ ត្រូវមក*

លេខ ២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ, ទូរសារ : ៨៥៥-២៣ ៤២៦ ៦០៣ អ៊ីម៉ែល : Cambodia_nmc@camintel.com
No 205, National road No 5, Sangkat Km 6 Khan Russey Keo, Phnom Penh, Cambodia
Tel / Fax: 855-23 426 603 E-mail: Cambodia-nmc@camintel.com

បំពេញបែបបទស្នើសុំ អាជ្ញាប័ណ្ណផលិត-ជួសជុល និងអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា។ សំខាន់ទៀតនោះ រូបវន្តបុគ្គល និងនីតិបុគ្គល កំពុងកាន់កាប់ប្រើប្រាស់ លក់ ឬដាក់តាំងលក់នូវរាល់ឧបករណ៍មាត្រាសាស្ត្រ ស្តង់ដារមាត្រាសាស្ត្រ ត្រូវមកបំពេញបែបបទស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ នៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលមានអាសយដ្ឋានអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឬសាខារបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ រាជធានី-ខេត្តទាំង២៤។

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ) សូមកំណត់រយៈពេល បីខែ បន្ថែមដោយគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងនេះ។ ក្រោយរយៈពេល បីខែ នៃការទទួលបានសេចក្តីជូនដំណឹងនេះ រូបវន្តបុគ្គល ឬនីតិបុគ្គល ពុំបានបំពេញបែបបទស្នើសុំ ឬពុំបានទំនាក់ទំនងជាលាយលក្ខណ៍អក្សរមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវចាត់ទុកជាមិនគោរពតាមបទប្បញ្ញត្តិមាត្រា២៥ និងមាត្រា៥៦ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ហើយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនឹងអនុវត្តធ្វើការពិន័យអន្តរការណ៍ បញ្ឈប់លែងឲ្យប្រើប្រាស់ ឬដាក់តាំងលក់ទៅតាមទោសប្បញ្ញត្តិនៃច្បាប់នេះ។

ជាមួយនេះដែរ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ គោរពស្នើសុំប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ ឬអ្នកទិញផលិតផលទំនិញនៅតាមទីផ្សារ និងកន្លែងលក់ដូរផ្សេងៗ សូមពិនិត្យរកមើលផ្លាកសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិដែលសំគាល់ភាពត្រឹមត្រូវរបស់ឧបករណ៍ទម្ងន់ និង រង្វាស់រង្វាល់ ដែលប្រើសម្រាប់ ថ្លឹង វាស់ វាល់ ផលិតផលទំនិញមុននឹងទទួលយកទំនិញទាំងនោះ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមស្ថាប័ន អង្គភាពសេដ្ឋកិច្ច ក្រុមហ៊ុន សហគ្រាស អាជីវករ ពាណិជ្ជករ និងប្រជាពលរដ្ឋទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមសហការជាមួយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាពខ្ពស់។ ៚

ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

បណ្ឌិត. ឡាំ-គីមឆ្លេង

**ចម្លងជូន:**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧរថ
- គ្រប់នាយកដ្ឋានជំនាញពាក់ព័ន្ធ
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

លេខៈ ១៥៦....NMC / 2014

NATIONAL METROLOGY CENTER

នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
ចូល លេខ 324 ......
ថ្ងៃទី 18 ខែ 11 ឆ្នាំ 2014
ម៉ោង..........

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ.តុលា.... ឆ្នាំ២០១៤

## សេចក្តីណែនាំ
## ស្តីពី
## ការបង្កើនការទទួលខុសត្រូវក្នុងការអនុវត្តន៍ ច្បាប់មាត្រាសាស្ត្រកម្ពុជា

ក្រោមការដឹកនាំ ណែនាំ បញ្ជា របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គួបផ្សំជាមួយនឹងការខិតខំប្រឹងប្រែងបំពេញការកិច្ចប្រកបដោយការទទួលខុសត្រូវរបស់សមត្ថកិច្ចគ្រប់គ្រងមាត្រាសាស្ត្រ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីអនុវត្តច្បាប់មាត្រាសាស្ត្រផ្សេងៗទៀត តាមរយៈការតែបន្តឹង អនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា បានជំរុញឱ្យស្ថានភាពការលក់ ឬ ដាក់តាំងលក់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត ទំនិញវេចខ្ចប់ និងការកាន់កាប់ប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ មានការប្រែប្រួលជាវិជ្ជមាន ហើយបាននឹងកំពុងបន្តនិរន្តរភាព សំដៅបង្កើតវប្បធម៌គោរពប្រតិបត្តិច្បាប់មាត្រាសាស្ត្រក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា ទម្លាប់ធ្វើតេស្តពិនិត្យពីដំណើរការរបស់ឧបករណ៍ ដោយប្រើស្តង់ដាមាត្រាសាស្ត្រមុននឹងចាប់ផ្តើមប្រើប្រាស់ឧបករណ៍នេះ ក្នុងពេលទិញស្តង់ដាមាត្រាសាស្ត្រ ឬ ឧបករណ៍មាត្រាសាស្ត្រ ឬ ទិញទំនិញផ្សេងៗ ទម្លាប់ពិនិត្យសួររកសញ្ញាត្រួតពិនិត្យ ព្យាសកម្ម ឬ ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជារបស់ឧបករណ៍ ឬ ទំនិញទាំងនេះ និងម្ចាស់តែងតែបញ្ជូនឧបករណ៍មាត្រាសាស្ត្ររបស់ខ្លួនមកធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ ឬ ព្យាសកម្ម ជាប្រចាំតាមការកំណត់នៃបច្ចេកទេស។ល។

ទន្ទឹមនោះ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ.) ក៏ពិនិត្យឃើញមានភាពអវិជ្ជមានមួយចំនួន ក្នុងដំណើរការអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ក្នុងនោះមាន ការងារព្យាសកម្ម និងត្រួតពិនិត្យផ្ទៀងផ្ទាត់ ពេលខ្លះអនុវត្តគ្មានប្រកាសស្តីពីបទប្បញ្ញត្តិបច្ចេកទេសដែលកំណត់ដោយរដ្ឋមន្ត្រី ជាមួយនេះដៃគោគច្រើនពុំបានប្រើប្រាស់ស្តង់ដាមាត្រាសាស្ត្រដើម្បីអនុវត្តការងារទាំងនេះ ពុំអនុវត្តតាមនីតិវិធី ឬវិធីសាស្ត្រឱ្យបានពេញលេញ ការទុកដាក់ថែទាំស្តង់ដាមាត្រាសាស្ត្រពុំបានត្រឹមត្រូវល្អ តាមការណែនាំ ឬ ខ្វះការទុកដាក់ថែទាំ ទីតាំងកន្លែងសម្រាប់អនុវត្តការងារពុំបានសមស្របតាមលក្ខណៈតម្រូវនៃបច្ចេកទេស ក្នុងពេលប្រតិបត្តិការងារពុំបានប្រើប្រាស់ឯកសណ្ឋានការពារសុវត្ថិភាព ឬ ឯកសណ្ឋានដែលបានកំណត់ ករណីទាំងនេះជាបច្ច័យមិនល្អ ដល់លទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ ព្យាសកម្ម។ ការទប់ស្កាត់កាត់បន្ថយបទល្មើសមាត្រាសាស្ត្រ ការងារនាំចូលឧបករណ៍មាត្រាសាស្ត្រ ស្តង់ដាមាត្រាសាស្ត្រ ការងារអនុម័តគំរូ ការងាររៀបចំប្រព័ន្ធឯកតាសមមូលក្រៅពីប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ឃើញថាពុំទាន់មានសកម្មភាពនៅឡើយ។ ការងារផ្សព្វផ្សាយ អប់រំ ណែនាំ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងមាត្រាសាស្ត្រនៅមានកំរិត។ ក្នុងការអនុវត្តន៍ការងារទៀតសោត ក៏មានមន្ត្រីត្រួតពិនិត្យ និងមន្ត្រីអនុវត្តច្បាប់មាត្រាសាស្ត្រផ្សេងៗទៀតខ្លះ បានសំដែងអាកប្បកិរិយា ឬ ប្រើពាក្យសំដីមិនសមរម្យ ខ្វះសុជីវធម៌ ឬ ខ្វះភាពក្លាហានម៉ឺងម៉ាត់។ ភាពអវិជ្ជមានទាំងអស់ខាងលើនេះ បានជះឥទ្ធិពលមិនល្អដល់ សង្គម និងប្រជាពលរដ្ឋ តាមរយៈលទ្ធផលនៃការអនុវត្តន៍ការងារកន្លងមកមិនសុក្រឹត មិនត្រឹមត្រូវ មិនច្បាស់លាស់ មិនអាចយកជាផ្លូវការបានតាមលក្ខណៈតម្រូវនៃច្បាប់ និងបច្ចេកទេស ធ្វើឱ្យប៉ះពាល់ដល់ កិត្តិយស និងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ អតិថិជន ចំពោះមន្ត្រីត្រួតពិនិត្យ មន្ត្រីអនុវត្តច្បាប់មាត្រាសាស្ត្រផ្សេងៗទៀត និងសមត្ថកិច្ចគ្រប់គ្រងមាត្រាសាស្ត្រ។

ដើម្បីពង្រឹងស្មារតីទទួលខុសត្រូវ ក្នុងការអនុវត្តន៍ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ម.ម.ជ. សូមណែនាំដល់ លោកអនុប្រធាន ម.ម.ជ. លោកប្រធាននាយកដ្ឋានចំណុះ ម.ម.ជ. លោកប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត មន្ត្រីត្រួតពិនិត្យ និងមន្ត្រីអនុវត្តច្បាប់មាត្រាសាស្ត្រផ្សេងៗទៀត ត្រូវចាត់វិធានការមួយចំនួន ដូចខាងក្រោម៖



២០៩ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២៣ ០២ ១១
ទូរសារលេខ (៨៥៥) ២៣ ២៣ ០២ ១១
អ៊ីម៉ែល: nmccambodia13@gmail.com

១. ត្រូវខិតខំអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ ឬ ព្យាសកម្មដោយប្រើប្រាស់តែស្តង់ដាមាត្រាសាស្ត្រដែលបានកំណត់ ទទួលស្គាល់ត្រឹមត្រូវដោយប្រកាស ឬ វិញ្ញាបនប័ត្រ ហើយប្រតិបត្តិការការងារទាំងនេះទៅតាមវិធីសាស្ត្រ ឬ បទប្បញ្ញត្តិបច្ចេកទេសឲ្យបានពេញលេញម៉ឺងម៉ាត់ខ្ជាប់ខ្ជួន។

២. ត្រូវអនុវត្តច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព តម្លាភាព និង ម៉ឺងម៉ាត់ស្របតាមបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ "ដូចមានឧបសម្ព័ន្ធជូនភ្ជាប់សេចក្តីណែនាំនេះ" និងត្រូវលុបបំបាត់ភាពអសកម្មទាំងឡាយជាដាច់ខាត។

៣. ត្រូវបង្កើនការអប់រំ រឹតបន្តឹងការអនុវត្តន៍ វិន័យ សីលធម៌ និងត្រូវចាត់វិធានការត្រួតពិនិត្យវិនិច្ឆ័យទាន់ពេលវេលាចំពោះមន្ត្រីអសកម្ម ព្រមជាមួយនោះត្រូវលើកសរសើរទាន់ពេលចំពោះមន្ត្រីមានស្នាដៃក្នុងការបំពេញភារកិច្ច។

៤. ត្រូវធានាដោះស្រាយគោលនយោបាយឲ្យបានដល់ដៃមន្ត្រីត្រួតពិនិត្យ និងមន្ត្រីអនុវត្តច្បាប់មាត្រាសាស្ត្រផ្សេងៗទៀតនៅថ្នាក់ក្រោម ដូចជាប្រាក់រង្វាន់លើកទឹកចិត្តពីការផាកពិន័យអន្តរការណ៍ ប្រាក់ឧបត្ថម្ភប្រតិបត្តិការ និងត្រូវម្ចាស់ការគិតគូរដោះស្រាយបំពាក់សំភារៈ និងស្តង់ដាមាត្រាសាស្ត្រចាំបាច់បំរើដល់កិច្ចប្រតិបត្តិការ។

៥. ក្នុងពេលចុះបំពេញភារកិច្ចជំនាញ និងការផ្តល់សេវាសាធារណៈគឺជាមន្ត្រីជួរក្រោយ ហើយត្រូវមានលិខិតបេសកកម្ម លិខិតគតិយុត្តពាក់ព័ន្ធផ្សេងៗជាប់ខ្លួន និងត្រូវស្លៀកពាក់ឯកសណ្ឋាន ជាមួយនឹងប្រតិបត្តិការការងារឲ្យបានសមស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិបច្ចេកទេសដែលមានជាធរមាន ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ជាប្រចាំ។

ទទួលបានសេចក្តីណែនាំនេះ លោកអនុប្រធាន ម.ម.ជ. លោកប្រធាននាយកដ្ឋានចំណុះ ម.ម.ជ. លោកប្រធានមន្ទីរ ឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត មន្ត្រីត្រួតពិនិត្យ និងមន្ត្រីអនុវត្តច្បាប់មាត្រាសាស្ត្រផ្សេងៗទៀត ត្រូវចាត់អនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

បណ្ឌិត. ឡាំ_គីមឡេង

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- លោកជំទាវរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក
- គ្រប់អគ្គនាយកដ្ឋាន និងថ្នាក់ស្មើ
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង

  "ដើម្បីជូនជ្រាប"
- អនុប្រធានម.ម.ជ.
- គ្រប់នាយកដ្ឋានចំណុះម.ម.ជ.
- គ្រប់មន្ទីរឧ.ស.រាជធានី-ខេត្ត

  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ



២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទលេខ (៨៥៥) ២៣ ២៣ ០២ ១១
ទូរសារលេខ (៨៥៥) ២៣ ២៣ ០២ ១១
អ៊ីម៉ែល: nmccambodia13@gmail.com

## គ. ពិន័យអន្តរការណ៍ដោយមន្ត្រីត្រួតពិនិត្យ

| បទល្មើសថ្នាក់លេខ១ (មាត្រា៣៩,៤១,៤៩) | ពិន័យជាប្រាក់ |
|---|---|
| - ប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្មនូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនមាន ពាណិជ្ជសញ្ញា<br>- ប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាព ពាណិជ្ជកម្ម ឬ លក់ ដាក់តាំងដើម្បីលក់ ឬ ដើម្បីចែកចាយ នូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនមានដាក់សញ្ញាត្រួតពិនិត្យ ដោយមន្ត្រីត្រួតពិនិត្យ<br>- លក់ ឬ ដាក់លក់នូវទំនិញវេចខ្ចប់ ដែលមិនមានដាក់ចំនួន ទម្ងន់ ឬ រង្វាស់រង្វាល់លើសម្ភារៈវេចខ្ចប់ នូវឯកតា ដែលមានចែងក្នុងឧបសម្ព័ន្ធទី១ និង ឧបសម្ព័ន្ធទី២ | - ជញ្ជីងមិនស្វ័យប្រវត្តិចាប់ពី១០០គីឡូក្រាមចុះ និងទំនិញវេចខ្ចប់ចាប់ពី ៥០ kg ឬ ៥០ លីត្រចុះ ចំនួន ១៥.០០០៛/គ្រឿង ធុង ឬ កញ្ចប់<br>- ជញ្ជីងមិនស្វ័យប្រវត្តិលើសពី១០០គីឡូក្រាម ដល់១ តោន ដៃវែវប្ចូមប្រេង កុងទ័រទឹក កុងទ័រ អគ្គិសនី និងទំនិញវេចខ្ចប់លើសពី ៥០ kg ឬ ៥០ លីត្រ ចំនួន ៣០.០០០៛/គ្រឿង ធុង ឬកញ្ចប់<br>- ជញ្ជីងមិនស្វ័យប្រវត្តិលើសពី១ តោន ដល់ ៥ តោន ទំនិញវេចខ្ចប់លើសពី ១០០ kg ឬ ១០០ លីត្រ ចំនួន ៦០.០០០៛/គ្រឿង ធុង ឬ កញ្ចប់<br>- ជញ្ជីងមិនស្វ័យប្រវត្តិ លើសពី ៥តោន ដល់ ១០តោន ស៊ីទែនរថយន្តប្រេង ចំណុះលើសពី ៥០០លីត្រ ដៃបាញ់ប្រេងតាមស្ថានីយ កុងទ័រតាក់ស៊ី ជញ្ជីងឌីជីថលចាប់ពី១០ តោនចុះ និង ឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យ ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ចំនួន ១២០.០០០៛/គ្រឿង<br>- ជញ្ជីងឌីជីថលចាប់ពី១០ តោន ដល់៤០ តោន ឬ ស៊ីទែនរថយន្តប្រេងចំណុះចាប់ពី៣០.០០០ លីត្រ ឡើង និងឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យសុខភាពសាធារណៈ ចំនួន ២៤០.០០០៛/គ្រឿង<br>- ជញ្ជីងឌីជីថលលើសពី៤០ តោន ឬ ស៊ីទែនរថយន្តប្រេងចំណុះលើសពី ៣៨.០០០ លីត្រ និងឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យអគ្គិសនី ឧស្ម័ន ទឹក មន្ទីរពិសោធន៍ និងសេវាកម្មប្រៃសណីយ៍ ចំនួន ៥០០.០០០៛/គ្រឿង |



៧០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ៦៣ ០២ ១១
ទូរសារលេខ (៨៥៥) ២៣ ៦៣ ០២ ១១
អ៊ីម៉ែល: nmocambodia13@gmail.com

| | |
|---|---|
| | - ឧបករណ៍មាត្រាសាស្ត្រផ្សេងៗ ដែលមានតម្លៃចាប់ពី ២០$ (ម្ភៃដុល្លាអាម៉េរិក)ចុះ ទំនិញផលិត និងទំនិញវេចខ្ចប់ផ្សេងៗចាប់ពី ១គីឡូក្រាម ចុះ ចំនួន ១០.០០០៛/គ្រឿង ដើម ឬកញ្ចប់ |
| **បទល្មើសហុជ្ជាក់លេខ២ (មាត្រា៤០)** | **ពិន័យជាប្រាក់** |
| - លក់ ដាក់តាំងដើម្បីលក់ ដើម្បីចែកចាយ ឬ ដើម្បីជួល នូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនមានពាណិជ្ជសញ្ញា | - ជញ្ជីងមិនស្វ័យប្រវត្តិចាប់ពី១០០គីឡូក្រាមចុះ និងឧបករណ៍មាត្រាសាស្ត្រផ្សេងៗ ដែលមានតម្លៃចាប់ពី ២០$ (ម្ភៃដុល្លាអាម៉េរិក) ចំនួន ៥០.០០០៛/គ្រឿង<br>- ជញ្ជីងមិនស្វ័យប្រវត្តិលើសពី១០០គីឡូក្រាម ដល់១ តោន ដៃវៃរបូមប្រេង កុងទ័រទឹក កុងទ័រអគ្គីសនី ចំនួន ៦០.០០០៛/គ្រឿង<br>- ជញ្ជីងមិនស្វ័យប្រវត្តិលើសពី១ តោន ដល់ ៥ តោន ចំនួន ១០០.០០០៛/គ្រឿង<br>- ជញ្ជីងមិនស្វ័យប្រវត្តិ លើសពី ៥តោន ដល់ ១០តោន ស៊ីទែនរថយន្តប្រេង ចំណុះលើសពី ៥០០លីត្រ ដៃបាញ់ប្រេងតាមស្ថានីយ កុងទ័រតាក់ស៊ី ជញ្ជីងឌីជីថលចាប់ពី១០ តោនចុះ និងឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យ ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ចំនួន ៤០០.០០០៛/គ្រឿង<br>- ជញ្ជីងឌីជីថលចាប់ពី១០ តោន ដល់៤០ តោន ឬ ស៊ីទែនរថយន្តប្រេងចំណុះចាប់ពី៣០.០០០ លីត្រ ឡើង និងឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យសុខភាពសាធារណៈ ចំនួន ៨០០.០០០៛/គ្រឿង<br>- ជញ្ជីងឌីជីថលលើសពី៤០ តោន ឬ ស៊ីទែនរថយន្តប្រេងចំណុះលើសពី ៣៨.០០០ លីត្រ និងឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យអគ្គីសនី ឧស្ម័ន ទឹក មន្ទីរពិសោធន៍ និងសេវាកម្មប្រៃសណីយ៍ ចំនួន ១.០០០.០០០៛/គ្រឿង |
| **បទល្មើសហុជ្ជាក់លេខ៣ (មាត្រា៤២,៤៤,៤៨,៥០)** | **ពិន័យជាប្រាក់** |
| - នាំចូល និង/ឬ ផលិតឧបករណ៍មាត្រាសាស្ត្រ | - ជញ្ជីងមិនស្វ័យប្រវត្តិចាប់ពី១០០គីឡូក្រាមចុះ |



២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២៣ ០២ ១១
ទូរសារលេខ (៨៥៥) ២៣ ២៣ ០២ ១១
អ៊ីម៉ែល: nmocambodia13@gmail.com

| | |
|---|---|
| ដោយមិន អនុវត្តតាមគំរូដែលអនុម័តពី ទម្ងន់ និងរង្វាស់រង្វាល់ ឬ គ្មានការអនុម័តគំរូ<br>- ផលិត និង/ឬ ជួសជុលឧបករណ៍មាត្រាសាស្ត្រ ដែលគ្មានអាជ្ញាប័ណ្ណ ដែលចេញដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ<br>- កាន់អាជ្ញាប័ណ្ណ តែបំពានលើលក្ខខណ្ឌ ដែលមានចែងក្នុង អាជ្ញាប័ណ្ណ<br>- ប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាព ពាណិជ្ជកម្ម ឬ លក់ ដាក់តាំងដើម្បីលក់ ឬ ដើម្បីចែកចាយ នូវឧបករណ៍មាត្រាសាស្ត្រ ដែលមានពាណិជ្ជសញ្ញា ដែលខ្លួនបានដឹងថា ជាពាណិជ្ជសញ្ញាក្លែងក្លាយ<br>- ដកចេញ ឬ ប្តូរសញ្ញាត្រួតពិនិត្យ ដែលបានដាក់ដោយ មន្ត្រីត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រ ហើយដាក់បញ្ចូល សញ្ញានោះលើឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត<br>- នាំចូល ឬ វេចខ្ចប់ទំនិញជាកញ្ចប់ផ្ទុយនឹងការតម្រូវនៃកថាខណ្ឌ ក នៃមាត្រា៣៣ នៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា<br>- ខកខានមិនបានដាក់សញ្ញាជាឯកតា ដែលអនុញ្ញាតនៅលើ សម្ភារៈវេចខ្ចប់រួចនូវចំនួនទម្ងន់សុទ្ធ ឬ រង្វាស់រង្វាល់ ដែលមាន បញ្ជាក់លើសម្ភារៈវេចខ្ចប់នៅក្នុងកញ្ចប់នោះ<br>- ខកខានមិនបានបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់អ្នកផលិត ឬ អ្នកនាំចូល ឬ សញ្ញាសម្គាល់សម្រាប់កំណត់អត្តសញ្ញាណនៃឈ្មោះអាសយដ្ឋាន<br>- រារាំង ឬ បដិសេធមិនឱ្យមន្ត្រីត្រួតពិនិត្យអនុវត្តសិទ្ធិក្នុងប្រតិបត្តិការ ដែលមានចែងក្នុងច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា | និងទំនិញវេចខ្ចប់ចាប់ពី ៥០ kg ឬ ៥០ លីត្រចុះ ចំនួន ២.០០០.០០០៛<br>- ជញ្ជីងមិនស្វ័យប្រវត្តិលើសពី១០០គីឡូក្រាម ដល់១ តោន ដៃវែបូមប្រេង កុងទ័រទឹក កុងទ័រអគ្គីសនី និងទំនិញវេចខ្ចប់លើសពី ៥០ kg ឬ ៥០ លីត្រ ចំនួន ៣.០០០.០០០៛<br>- ជញ្ជីងមិនស្វ័យប្រវត្តិ លើសពី ១តោន ដល់ ១០តោន ជញ្ជីងឌីជីថលចាប់ពី១០ តោន ចុះ ស៊ីទែន រថយន្តប្រេង ចំណុះលើសពី៥០០លីត្រ ដៃបាញ់ប្រេងតាមស្ថានីយ កុងទ័រតាក់ស៊ី និងឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យ ឧស្សាហកម្ម សិប្បកម្ម សេវាកម្ម ចំនួន ៤.០០០.០០០៛<br>- ជញ្ជីងឌីជីថលលើសពី១០ តោន ឬ ស៊ីទែនរថយន្តប្រេងចំណុះលើសពី៣០.០០០ លីត្រ ឡើង និងឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត ដែលប្រើក្នុងវិស័យ សុខភាពសាធារណៈ អគ្គីសនី ឧស្ម័ន ទឹក មន្ទីរពិសោធន៍ និងសេវាកម្មប្រៃសណីយ៍ ចំនួន ៥.០០០.០០០៛<br>- ឧបករណ៍មាត្រាសាស្ត្រផ្សេងៗ ដែលមានតម្លៃចាប់ពី ២០$ (ដុល្លាអាម៉េរិក)ចុះ ទំនិញផលិត និងទំនិញវេចខ្ចប់ផ្សេងៗចាប់ពី ១គីឡូក្រាម ចុះ ចំនួន ១.០០០.០០០៛ |

- ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង។
- ក្នុងករណីដែលជនល្មើសមិនបានបង់ប្រាក់ពិន័យ ក្នុងរយៈពេល 60 ថ្ងៃ គិតពីថ្ងៃដែលបានទទួលប័ណ្ណពិន័យ ចំនួនទឹកប្រាក់ពិន័យនេះនឹងត្រូវតម្លើង ២% ក្នុង១ខែលើចំនួនទឹកប្រាក់ពិន័យដែលពុំទាន់បានទូទាត់ជូនរដ្ឋ។ បើផុតរយៈពេល ៩០ថ្ងៃ មន្ត្រីត្រួតពិនិត្យ ត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅតុលាការ។



មជ្ឈមណ្ឌល មាត្រាសាស្ត្រជាតិ

២០៥ ផ្លូវជាតិលេខ ៤ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ...
ទូរសារលេខ (៨៥៥) ២៣ ២០ ០២ ១១
អ៊ីម៉ែល: nmccambodia13@gmail.com

## ខ. ករណីដាក់ពន្ធនាគារ ឬ/និង ពិន័យជាប្រាក់ដោយតុលាការ

| ករណីល្មើស (មាត្រា៤៣,៤៥,៤៦,៤៧) | ផ្តន្ទាទោស |
|---|---|
| - នាំចូល និង/ឬ ផលិតឧបករណ៍មាត្រាសាស្ត្រ ដោយប្រើពាណិជ្ជសញ្ញាក្លែងក្លាយ<br>- បង្កើន បន្ថយ ឬ បន្លំ ទម្ងន់ ឬ រង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រ ដែលបានដាក់សញ្ញាត្រួតពិនិត្យរួច<br>- ប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬ លក់ ដាក់តាំងដើម្បីលក់ ឬ ដើម្បីចែកចាយ នូវឧបករណ៍មាត្រាសាស្ត្រ ដែលខ្លួនបានដឹងថាបាន បង្កើន បន្ថយ ឬ បន្លំ<br>- ធ្វើសេចក្តីបញ្ជាក់ដោយក្លែងបន្លំ មិនត្រឹមត្រូវ ឬ មិនពិតអំពីលេខ បរិមាណ រង្វាស់រង្វាល់ ឬ គណនាថ្លៃសេវាកម្ម ដែលខ្លួនត្រូវផ្តល់ទៅតាមទម្ងន់ ឬ រង្វាស់រង្វាល់ ដែលបានព្រមព្រៀងគ្នា<br>- លក់ ឬ ប្រគល់ទំនិញទៅឱ្យអ្នកទិញដោយមានបរិមាណ ឬ រង្វាស់រង្វាល់តិចជាងបរិមាណ ដែលបានព្រមព្រៀងគ្នា<br>- ផ្គត់ផ្គង់ លក់ ឬ ដាក់តាំងលក់នូវទំនិញវេចខ្ចប់ ដែលបំភាន់អំពីលក្ខណៈទម្ងន់ ឬ រង្វាស់រង្វាល់។ | ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ថ្ងៃ ទៅ ១(មួយ) ខែ និង/ឬ ពិន័យជាប្រាក់ពី ១.០០០.០០០៛ ទៅ ៥.០០០.០០០៛ |

## គ. ករណីមន្ត្រីមានសមត្ថកិច្ចប្រព្រឹត្តល្មើស

| ករណីល្មើស | ផ្តន្ទាទោស |
|---|---|
| មាត្រា៥១៖ មន្ត្រីត្រួតពិនិត្យណាដែលបំពានលើមាត្រាណាមួយនៃច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា ជាអាទ៍លើបទប្បញ្ញត្តិទាក់ទងនឹងការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ឬ សេវាមាត្រាសាស្ត្រ។ | ត្រូវទទួលទណ្ឌកម្មខាងវិន័យ តាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។<br>ទណ្ឌកម្មខាងវិន័យនេះ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។ |



២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២៣ ០២ ១១
ទូរសារលេខ (៨៥៥) ២៣ ២៣ ០២ ១១
អ៊ីម៉ែល: nmccambodia13@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
National Metrology Center
លេខ:..៤៧០.....NMC / 2014

រាជធានីភ្នំពេញ, ថ្ងៃទី២៨. ខែសីហា ឆ្នាំ២០១៤

# លិខិតបង្គាប់ការ
# ស្តីពី
# ការផ្ទេរសិទ្ធចុះហត្ថលេខាជូនអនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

**យោង៖** - អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ដើម្បីសុខដុមនីយកម្មការងារ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤

- កំណត់ចាត់ការផ្ទៃក្នុងលេខ១០០ NMC/2014 ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- ស្មារតីអង្គប្រជុំផ្ទៃក្នុងមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤
- សំណូមពរការងារចាំបាច់របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

## <u>សម្រេច</u>

**ប្រការ១** ៖ ត្រូវបានផ្ទេរសិទ្ធចុះហត្ថលេខា លើឯកសារការងារទាំងឡាយណា ដែលទទួលពីច្រកចេញ-ចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជូនអនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ តាមការបែងចែកបន្ទុកការងារនៃកំណត់ចាត់ការផ្ទៃក្នុងលេខ ១០០ NMC/2014 ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ជាអ្នកអនុវត្តន៍។ ប៉ុន្តែពល់ឯកសារការងារដែលចាំបាច់ ត្រូវសុំមតិពីប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**ប្រការ២** ៖ ពល់ឯកសារនៃការស្នើសុំសម្ភារៈការិយាល័យតាមនាយកដ្ឋាន និងបញ្ជីវត្តមានដែលត្រូវចុះហត្ថលេខាបញ្ជូនទៅក្រសួង ត្រូវបានផ្ទេរសិទ្ធជូនអនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ តាមការបែងចែកបន្ទុកការងារនៃកំណត់ចាត់ការផ្ទៃក្នុងលេខ១០០ NMC/2014 ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ជាអ្នកអនុវត្តន៍។



២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២៣ ០២ ១១
ទូរសារលេខ (៨៥៥) ២៣ ២៣ ០២ ១១
អ៊ីម៉ែល: nmccambodia13@gmail.com

**ប្រការ៣** ៖ រាល់ឯកសារនៃការស្នើសុំចំណាយថវិការពង្រឹងយន្តការ ដែលត្រូវចុះហត្ថលេខាបញ្ជូនទៅថ្នាក់ដឹកនាំក្រសួង ដើម្បីសុំការពិនិត្យសម្រេច ឬរបាយការណ៍ចំណូល-ចំណាយ និងឯកសារផ្សេងៗពាក់ព័ន្ធការងារគណនេយ្យហិរញ្ញវត្ថុ ឬថវិកា ត្រូវបានផ្ទេរសិទ្ធចុះហត្ថលេខា ជូន **លោក កែ សារី**។

**ប្រការ៤៖** រាល់កិច្ចការដែលប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិបានផ្ទេរសិទ្ធចុះហត្ថលេខា អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដែលបានទទួលសិទ្ធនេះ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារទាំងនេះ ជូនប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនូវរាល់ពីរ (០២) សប្តាហ៍ម្តងរៀងរាល់ថ្ងៃសុក្រ។

**ប្រការ៥** ៖ អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ ប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ ត្រូវអនុវត្តលិខិតបង្គាប់ការនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

មជ្ឈមណ្ឌល មាត្រាសាស្ត្រជាតិ

**បណ្ឌិត. ឡាំ គឹមឡេង**

<u>**កន្លែងទទួល៖**</u>

- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- លោកជំទាវរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក
- គ្រប់អគ្គនាយកដ្ឋាន និងថ្នាក់ស្មើ
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
  ''ដើម្បីជូនជ្រាប''
- ដូចប្រការ៥ "ដើម្បីអនុវត្ត''
- ឯកសារ-កាលប្បវត្តិ



២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២៣ ០២ ១១
ទូរសារលេខ (៨៥៥) ២៣ ២៣ ០២ ១១
អ៊ីមែល: nmccambodia13@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
National Metrology Center
លេខ ១០០ NMC/2014

# កំណត់ចាត់ការផ្ទៃក្នុង

## ស្តីពី
## ការកំណត់របៀបរបបការងារ និង
## ការបែងចែកភារកិច្ចថ្នាក់ដឹកនាំមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨០៩/០១៦ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម ១២១៣/០១៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៣១១ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការតែងតាំងឯកឧត្តម ឡាំ គីមឡេង ជាប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ថ្នាក់ស្មើអគ្គនាយក
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងស្មារតីអង្គប្រជុំ និងអនុសាសន៍ចាត់តាំងមន្ត្រីរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ចុះថ្ងៃទី ០៦ខែកុម្ភៈឆ្នាំ ២០១៤
- យោងតាមសំណូមពរការងារចាំបាច់របស់ ម.ម.ជ

## សម្រេច

**ប្រការ១** ៖ កំណត់របៀបរបបការងារ និងបែងចែកបន្ទុកការងារជូនថ្នាក់ដឹកនាំមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដូចខាងក្រោម ៖

១- ឯកឧត្តម **ឡាំ គីមឡេង** ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ទទួលខុសត្រូវរួមរាល់កិច្ចការទូទៅរបស់ ម.ម.ជ និងទទួលដឹកនាំគ្រប់គ្រងផ្ទាល់លើការងារ ៖

- “ ច្រកចេញ-ចូលតែមួយ ” នៃ ម.ម.ជ
- និងបំពេញភារកិច្ចដទៃទៀតដែលក្រសួងប្រគល់ជូនបន្ថែម ។

២- លោក **ទិច សុមិត្ត** អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ជំនួយការឯកឧត្តមបណ្ឌិត ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ទទួលបន្ទុកលើការងារដែលពាក់ព័ន្ធនឹង ៖

- នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ (D/LGM)
- និងបំពេញភារកិច្ចមួយចំនួនទៀត ដែលប្រធាន ម.ម.ជ ប្រគល់ជូន។

៣- លោក **គឹម ចន្ទតារា** អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ជំនួយការឯកឧត្តមបណ្ឌិត ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ទទួលបន្ទុកលើការងារដែលពាក់ព័ន្ធនឹង ៖

- នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ (D/MSC)
- និងបំពេញភារកិច្ចមួយចំនួនទៀត ដែលប្រធាន ម.ម.ជ ប្រគល់ជូន។

៤- លោក **កែ សារី** អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ជំនួយការឯកឧត្តមបណ្ឌិត ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ទទួលបន្ទុកលើការងារដែលពាក់ព័ន្ធនឹង ៖

- នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ (D/MLA)
- និងបំពេញភារកិច្ចមួយចំនួនទៀត ដែលប្រធាន ម.ម.ជ ប្រគល់ជូន។

៥- លោក **គង់ សាំងហេង** អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ជំនួយការឯកឧត្តមបណ្ឌិត ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ទទួលបន្ទុកលើការងារដែលពាក់ព័ន្ធនឹង ៖

- នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម (D/INM)
- និងបំពេញភារកិច្ចមួយចំនួនទៀត ដែលប្រធាន ម.ម.ជ ប្រគល់ជូន។

**ប្រការ២** ៖ ក្នុងករណីអវត្តមានថ្នាក់ដឹកនាំទទួលបន្ទុក ចរន្តឯកសារដែលត្រូវលើកយោបល់ជូនក្រសួងពិនិត្យ និងសម្រេច ឬជូនប្រធាន ម.ម.ជ អាចបញ្ជូនបន្តទៅឋានានុក្រមខ្ពស់បន្ទាប់ ដោយកត់សម្គាល់នូវមូលហេតុអវត្តមាននៅលើកំណត់បង្ហាញ ។

**ប្រការ៣** ៖ កំណត់ចាត់ការផ្ទៃក្នុងរបស់ ម.ម.ជ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងកំណត់ចាត់ការនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤៖** ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ ប្រធាននាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ ប្រធានច្រកចេញចូលតែមួយនៃ ម.ម.ជ និងសាមីខ្លួនដូចក្នុងប្រការ១ ត្រូវអនុវត្តចំណាត់ចាត់ការផ្ទៃក្នុងនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤

**ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

**បណ្ឌិត. ឡាំ គឹមឡេង**

<u>កន្លែងទទួល</u>៖

- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម រដ្ឋលេខាធិការ ទទួលបន្ទុក
- លោកជំទាវ រដ្ឋលេខាធិការ ទទួលបន្ទុក
- ឯកឧត្តម អនុរដ្ឋលេខាធិការ ទទួលបន្ទុក
- អគ្គនាយករដ្ឋបាលកិច្ចការទូទៅ
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
  “ដើម្បីជូនជ្រាប”
- ដូចប្រការ៤ “ដើម្បីអនុវត្ត”
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈយោគយល់

រវាង

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍
នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

ជាមួយនិង

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម

លើ

## យន្តការសុក្រឹតភាពនៃជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្ត

ប្រតិភូគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ បានជួបជាមួយប្រតិភូនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៅក្រសួងសាធារណការ និងដឹកជញ្ជូន កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ដើម្បីជជែកពិភាក្សាអំពី "យន្តការសុក្រឹតភាពនៃជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្ត" ប្រើប្រាស់ក្នុងការថ្លឹងត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិបានយល់ពីគោលបំណងប្រកបដោយសុឆន្ទៈរបស់គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ បានស្វាគមន៍ និងបានជួបពិភាក្សាយ៉ាងផុលផុស។

ជាលទ្ធផល ភាគីទាំងពីរបានឯកភាពគ្នាលើ "យន្តការសុក្រឹតភាពនៃជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្ត" ដោយរួមគ្នាអនុវត្តទៅតាមលក្ខខណ្ឌដែលភ្ជាប់ជាមួយនេះនិងមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើ និងចុះហត្ថលេខា នៅ ភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៤

លឹម ស៊ីដេនិន

| | |
|---|---|
| **ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**<br>**នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម** | **រដ្ឋលេខាធិការ**<br>**ក្រសួងសាធារណការ និងដឹកជញ្ជូន និងជា**<br>**ប្រធានគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍** |

# បណ្ដាលក្ខខណ្ឌ
# យន្តការសុក្រឹតភាពនៃជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្ត

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ បានព្រមព្រៀងគ្នាកសាងនូវយន្តការសុក្រឹតភាពនៃជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្តដោយតម្រូវឲ្យភាគីទាំងពីរអនុវត្តនូវបណ្ដាលក្ខខណ្ឌដូចខាងក្រោម៖

**ក**-លក្ខខណ្ឌទូទៅ:

១-ជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្តទាំងអស់(ទាំងជញ្ជីងចល័ត និងអចល័ត) ត្រូវចុះបញ្ជីមាត្រាសាស្ត្រ

២-ជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្តទាំងអស់(ទាំងជញ្ជីងចល័តនិងអចល័ត) ត្រូវធ្វើការត្រួតផ្ទៀងផ្ទាត់ទៅតាមកាលកំណត់របស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

**ខ**-លក្ខខណ្ឌចំពោះមុខ:

១-ជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្តទាំងអស់ ត្រូវមានវិញ្ញាបនបត្រព្យាសកម្ម (Certificate of Calibration) មុននឹងប្រើប្រាស់ និងក្រោយពេលជួសជុលកែតម្រូវរួច។

២-ជញ្ជីងអចល័តត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់បួនខែម្តង និងជញ្ជីងចល័តត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់មួយឆ្នាំម្តង ពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។ ក្នុងករណីមានមន្ទិលថាមានភាពមិនប្រក្រតី ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញជាចាំបាច់។

៣-គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ត្រូវមានដៃគូរផ្តល់សេវាកម្ម ថែទាំ ជួសជុល និងតម្លើង ដែលដៃគូរនោះមានអាជ្ញាប័ណ្ណពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

៤-រាល់ការផ្តល់សេវាកម្មជួសជុល ថែទាំជញ្ជីងត្រួតពិនិត្យទម្ងន់យានយន្ត អ្នកផ្តល់សេវាកម្មត្រូវអញ្ជើញមន្ត្រីបច្ចេកទេសរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ដើម្បីចូលរួមក្នុងការផ្តល់សេវាកម្មនេះ

៥-ក្នុងករណីមានបណ្តឹងតវ៉ាពីអតិថិជន ពីភាពមិនប្រក្រតីរបស់ជញ្ជីង មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិជាអាជ្ញាកណ្តាល។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
Ministry fo Industry, Mines and Energy
មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
National Metrology Center
លេខ / No...១៣៣៨...ឆ.ខ.៨

# សេចក្តីណែនាំស្តីពី
# បច្ចេកទេសក្នុងការប្រើប្រាស់កូនទម្ងន់គំរូដើម្បី
# ថ្លឹងលោហៈធាតុ និង វត្ថុមានតម្លៃដូចជាមាស ពេជ្រ ប្រាក់ ត្បូង

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានកិត្តិយសសូមជូនដំណឹង ដល់លោក លោកស្រី ដែលជាអាជីវករ លក់ដូរ លោហៈធាតុ និងវត្ថុមានតម្លៃដោយប្រើកូនទម្ងន់គំរូ ជាមួយជញ្ជីងថាស ទាំងអស់ឲ្យបានជ្រាបថា៖ ដើម្បីអោយស្របទៅតាមលក្ខណៈបច្ចេកទេសផ្នែកមាត្រាសាស្ត្រ នៃការថ្លឹង និងវាស់វាល់ ទម្ងន់សម្រាប់ជញ្ជីងថ្លឹងលោហៈធាតុ និងវត្ថុមានតំលៃ គឺត្រូវគោរពតាមបទបញ្ជាណែនាំដូចខាងក្រោម៖

១. កូនទម្ងន់ដែលប្រើប្រាស់សំរាប់ថ្លឹង ត្រូវមានវិញ្ញាបនបត្រ បញ្ជាក់ទម្ងន់ អតិបរមា និង អប្បបរមាពីមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ



២. កូនទម្ងន់ ត្រូវរក្សាទុកក្នុងប្រអប់ ឬគេះបិទជិតជៀសវាងនូវការប៉ះនឹង ខ្យល់សំណើមបរិយាកាសជាដើម ដែលបណ្តាលឲ្យកូនទម្ងន់ងាយខូចទ្រង់ទ្រាយ។

៣. ពេលថ្លឹង ឬ វាស់វាល់ ត្រូវ ប្រើប្រាស់ស្រោមដៃ ឬដង្កៀបដើម្បីចាប់ កូនទម្ងន់ (ហាមដាច់ខាតមិនចាប់ផ្ទាល់នឹងដៃ) ដែលអាចបណ្តាលឲ្យច្រេះ ឬ ផុះស្នឹម ដែលប៉ះពាល់ដល់កំរិតលំអៀង នៃកូនទម្ងន់។







៤. កូនទម្ងន់គំរូដែលប្រើប្រាស់សម្រាប់ថ្លឹងវត្ថុមានតម្លៃទាំងអស់ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសក្នុង ០១(មួយ)ឆ្នាំម្តងជាកំណត់។

៥. ចំពោះអាជីវករដែលប្រើប្រាស់កូនទម្ងន់គំរូខុសលក្ខណៈបច្ចេកទេសដូចបានរៀបរាប់ខាងលើ បង្កឲ្យមានការកេងបន្លំក្នុងការលក់ដូរវត្ថុមានតម្លៃ មជ្ឈមណ្ឌលមាត្រាសាស្ត្រកម្ពុជា នឹងមានវិធានការដាក់ពិន័យស្របតាមច្បាប់ស្តីពី មាត្រាសាស្ត្រកម្ពុជា។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ សង្ឃឹម និង ជឿជាក់លើស្មារតីទទួលខុសត្រូវរបស់ លោក លោកស្រីដែលជាអាជីវករក្នុងការចូលរួមអនុវត្តច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាប្រកបដោយប្រសិទ្ធភាពខ្ពស់។ ✓

រាជធានីភ្នំពេញ ថ្ងៃទី ... ខែកក្កដា..ឆ្នាំ២០១២
ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ

បណ្ឌិត. ស៊្បាំ គីមឡេង

លេខ ២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ, ទូរសារ : ៨៥៥-២៣ ៤២៦ ៦០៣ អ៊ីម៉ែល : Cambodia_nmc@camintel.com
No 205, National road No 5, Sangkat Km 6 Khan Russey Keo, Phnom Penh, Cambodia
Tel / Fax: 855-23 426 603 E-mail: Cambodia-nmc@camintel.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
លេខ:១៣៦/១៣ ម.ម.ជ / អសម

# គោលការណ៍ណែនាំ
## ស្តីពី
## យន្តការពង្រឹងការងារ លើការចុះបញ្ជីមាត្រាសាស្ត្រ និងអាជ្ញាប័ណ្ណ ប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា

យោង៖- ព្រះរាជក្រមលេខ នស/រកម/០៩០៨/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ដែលប្រកាសអោយប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា

- អនុក្រឹត្យ លេខ ១៨៣អនក្រ.បកចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- ប្រកាសលេខ៨៥៧ ឧរថ.បល.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអភិវឌ្ឍន៍ និងសហប្រតិបត្តិការមាត្រាសាស្ត្រ
- ប្រកាសលេខ៩៩២ ឧរថ.អសម.ប្រក ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១២ ស្តីពីពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា
- ប្រកាសលេខ១៣៩ ឧរថ.ម.ម.ជ.ប្រក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីនិតិវិធី និងបែបបទនៃការចុះបញ្ជីមាត្រាសាស្ត្រ និងការផ្តល់អាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សូមជម្រាបជូនអស់លោកជាប្រធានមន្ទីរឧរថ រាជធានី-ខេត្ត អោយបានជ្រាបថា: ដើម្បីអនុវត្តន៍ការងារដែលពាក់ព័ន្ធនឹងផ្នែកមាត្រាសាស្ត្រ ក្នុងឆ្នាំ២០១៣លើការងារចុះបញ្ជីមាត្រាសាស្ត្រ និងអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា អោយបានរលូន និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ចូលរួមទប់ស្កាត់បាតុភាពផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុលើការងារដឹកនាំគ្រប់គ្រងរបស់ ម.ម.ជ និងមន្ទីរ ឧរថ រាជធានី-ខេត្ត ឈរលើគោលការណ៍កិច្ចសហប្រតិបត្តិការ និងការផ្តល់ពត៌មានគ្រប់ករណីបានទាន់ពេលវេលាពីការអនុវត្តតួនាទី និងភារកិច្ចរបស់មន្ត្រី ម.ម.ជ និងមន្ត្រីសាខា ម.ម.ជនៃមន្ទីរឧរថ រាជធានី-ខេត្ត អោយកាន់តែមានភាពត្រឹមត្រូវ និងទទួលខុសត្រូវខ្ពស់ស្របទៅតាមគោលការណ៍ច្បាប់ និងបទប្បញ្ញត្តិនានាបានកំណត់។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សូមធ្វើការដាក់ចេញនូវគោលការណ៍មួយចំនួនដូចខាងក្រោម៖

១.បន្តជំរុញផ្សព្វផ្សាយអំពីអត្ថប្រយោជន៍ការចុះបញ្ជីមាត្រាសាស្ត្រ និងអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាអោយបានទូលំទូលាយដល់បណ្តារោងចក្រ សហគ្រាស សិប្បកម្មដែល កំពុងធ្វើពាណិជ្ជកម្មអាជីវកម្មពាក់ព័ន្ធទៅនឹងការងារមាត្រាសាស្ត្រ។

២.ការបំពេញទម្រង់បែបបទពាក្យស្នើសុំចុះបញ្ជីមាត្រាសាស្ត្រ និងអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ត្រូវមានលក្ខណៈត្រឹមត្រូវ និងគ្រប់គ្រាន់ទៅតាមនីតិវិធីបានកំណត់។

៣.ការបំពេញតារាងបច្ចេកទេសលើឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ត្រូវអនុវត្តតាមការណែនាំរបស់នាយកដ្ឋានអភិវឌ្ឍន៍ និងសហប្រតិបត្តិការមាត្រាសាស្ត្រ។

៤.អ្នកស្នើសុំប្រើប្រាស់ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាត្រូវមកចុះកិច្ចព្រមព្រៀងជាមួយ ម.ម.ជ មុននិងទទួលបានអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា។

៥.ត្រូវមានការសហការ និងផ្តល់ព័ត៌មានអោយបានទាន់ពេលវេលា រាល់សកម្មភាពផ្សេងៗ ដែលកើតមានឡើងដោយថាហេតុណាមួយ ពីការចុះបំពេញបេសកម្មរបស់មន្ត្រី ម.ម.ជ ឬ មន្ត្រីសាខា ម.ម.ជ នៃមន្ទីរឧរថ រាជធានី-ខេត្ត ដែលបានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនខុសពីគោលការណ៍ណែនាំរបស់ម.ម.ជបានកំណត់និងត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ជាធរមាន។

៦.មន្ត្រី ម.ម.ជ ឬ មន្ត្រីសាខា ម.ម.ជ នៃមន្ទីរឧរថ រាជធានី-ខេត្ត ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងបទប្បញ្ញត្តិនានាដែលបានចូលជាធរមាន ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដោយឈរលើឆន្ទៈបំរើសេវាជូនអតិថិជនអោយបានល្អប្រសើរ និងមានសេចក្តីថ្លៃថ្នូរជៀសវាងការប្រើសិទ្ធិអំណាចណាមួយផ្ទុយពីគោលការណ៍បានកំណត់។

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានសេចក្តីសង្ឃឹមទុកជាមុនថាក្រោយពីទទួលបានគោលការណ៍ណែនាំខាងលើនេះ អស់លោកជាប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានី-ខេត្តនឹងចូលរួមសហការអនុវត្តតាមគោលការណ៍ណែនាំនេះអោយបានសម្រេចលទ្ធផលល្អ និងមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៩១៨.៤

រាជធានីភ្នំពេញ, ថ្ងៃទី១៨ខែមករាឆ្នាំ២០១៣

**ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

**បណ្ឌិត. ឡាំ គឹមឡេង**

<u>ចម្លងជូន:</u>

- ខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី
- រដ្ឋលេខាធិការទទួលបន្ទុក
- លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុក
- អនុប្រធាន ម.ម.ជ
- នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- នាយកដ្ឋានមន្ទីរពិសោធន៍មាត្រាសាស្ត្រ
- នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

"ដើម្បីជូនជ្រាប"

- ឯកសារ- កាលប្បវត្តិ